# ប្រវត្តិសាស្ត្រខ្មែរ

## ពាក្យកាព្យរបស់ ឡឿ វ៉ាន់



ព្រះបាទ នរោត្តម សុរាម្រិត (១៨៩៦-១៩៦០)

ចងក្រងដោយ បណ្ឌិត មីសែល ត្រាណេ

២០០៤

ទទួលបានពីលោក ខ្មៅ ឈុនសុីវ៉ាន ផ្ដល់ការណាខ្មែរ
ដើម្បីតំកល់ក្នុង eLibrary of Cambodia
កក្កដា 2015

សូមពួកទេវតា
រក្សាមហាក្សត្រយើង
អោយបានរុងរឿង
ដោយជ័យមង្គល សិរីសួស្ដី
យើងខ្ញុំព្រះអង្គ
សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី
វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ
បុរាណថ្កើងថ្កាន ។

ប្រាសាទសិលា
កំបាំងកណ្ដាលព្រៃ
គួរអោយស្រមៃ
នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម
គង់វង្សនៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ
ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន
យូរអង្វែងហើយ ។

គ្រប់វត្តអារាម
ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ
រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក
ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេវតា
នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ
ជាមហានគរ ។

(ភ្លេងគោរពជាតិ នៃព្រះរាជាណាចក្រកម្ពុជា)

# ឧទ្ទិសកថា

វត្ថុបំណងចម្បងនៃការបោះពុម្ពឯកសារនេះគឺ ដើម្បីអបអរ-សាទរចំពោះការយាងគ្រងរាជ្យសម្បត្តិរបស់ ព្រះករុណា ព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤ ត្រូវនឹងថ្ងៃ សុក្រ ១រោច ខែ អស្សុជ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ។

សូមព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងមានព្រះពលានុ-ភាពខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីទ្រង់ប្រថាប់ក្នុងព្រះសិរីរាជសម្បត្តិដ៏ត្រជាក់ត្រជុំ ដល់ប្រជានុរាស្ត្ររស់ក្នុងសុខ សន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដី និងចំរុងចំរើនថ្កុំថ្កើន-រុងរឿងតរៀងទៅ ដូចសម័យសង្គមរាស្ត្រនិយម ដែលដឹកនាំដោយ ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាវីរក្សត្រ ព្រះបិតាឯករាជ្យជាតិ ។

# អារម្ភកថា

បន្ទាប់ពីបានរៀនសូត្រយ៉ាងជ្រៅជ្រះនូវវប្បធម៌ អារ្យធម៌ខ្មែរមក លោក ឡើ វ៉ាន់ បានសរសេរច្បាប់ពង្សាវតានៃប្រទេសកម្ពុជា នៅ ឆ្នាំ១៩៥១ ដើម្បីដាស់សតិសម្បជញ្ញៈ កូនខ្មែរជំនាន់ក្រោយឲ្យចងចាំនូវព្រឹត្តិការណ៍នានាក្នុងសង្គមរបស់ខ្លួនឡើងវិញ ។

ថ្វីត្បិតតែឯកសារនេះសរសេរជាពាក្យកាព្យ ប៉ុន្តែបញ្ហាសំខាន់ដែលជាមូលដ្ឋានគ្រឹះរបស់សតិសម្បជញ្ញៈ ត្រូវបានលើកឡើងយ៉ាងក្បោះក្បាយក្នុងអត្ថបទរបស់អ្នកនិពន្ធ ។ នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលមានការចងក្រងទំព័រប្រវត្តិសាស្ត្រជាតិជាពាក្យកាព្យឃ្លោង ហើយទង្វើនេះ សបញ្ជាក់នូវកម្រិតចេះដឹងស៊ីជម្រៅរបស់លោក ឡើ វ៉ាន់ ក្នុងវិស័យកាព្យសាស្ត្រ និងប្រវត្តិសាស្ត្រខ្មែរ ។ ហេតុនេះហើយបានជាយើងយកច្បាប់ដើមសរសេរជាអក្សរដៃ ដែលតម្កល់សព្វថ្ងៃនៅបណ្ណាល័យជាតិរបស់សាលាបារាំងមជ្ឈឹមបូព៌ា នៅទីក្រុងប៉ារីសមកផ្សព្វផ្សាយជូនមិត្តអ្នកអានជា ទីមេត្រី ។

ស្មារតីនៃអត្ថបទពង្សាវតានៃប្រទេសកម្ពុជានេះ ត្រូវបានយើងទទួលស្គាល់ដោយកក់ក្តៅថា មានសារៈសំខាន់សម្រាប់ជនជាតិខ្មែរគ្រប់រូប ។ អត្ថប្រយោជន៍ខាងលើនេះ គឺមិនគ្រាន់តែបានជំរុញឲ្យខ្មែរស្វែងយល់អំពី ការកកើតនូវមាតុភូមិដីពិសិដ្ឋរបស់ខ្លួនតែប៉ុណ្ណោះទេ គឺថែមទាំងធ្វើឲ្យទៅដល់មោទនភាពជាតិដ៏ឧត្តុង្គឧត្តម ពោលគឺអ្វីដែលគេហៅថា ព្រលឹងជាតិ ។

រួមសេចក្តីមកដោយសារតែយើងយល់ថា ការបាត់បង់ប្រវត្តិសាស្ត្រ គឺជាការបាត់បង់នូវអត្តសញ្ញាណជាតិដែលកើតចេញពីការចងចាំ រួមរបស់ជនជាតិខ្មែរទាំងមូល ទើបយើងបានយកឯកសារនេះមកបង្ហាញដល់លោកអ្នកជាទីគោរព ។

ឆ្លៀតយកឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំក៏មានសេចក្តីរីករាយជាអនេកប្បការនឹងសូមភ្ជាប់មកជាមួយច្បាប់ប្រវត្តិសាស្ត្រខ្មែរ ច្បាប់ថ្មីនេះ នូវផែនទីបុរាណមួយចំនួន និងព្រះឆាយាលក្ខណ៍ នៃព្រះមហាក្សត្រ និង ព្រះមហាក្សត្រិយានីខ្មែរសំខាន់ៗដែលបានគ

ពូជពង្សវង្សត្រកូលពីព្រះមហាវីរៈក្សត្រនាសម័យបុរេអង្គរ និង អង្គរ ដ៏មហារុងរឿង ថ្កើងថ្កានកប់កំពូលដើម្បីទុកជាការចងចាំទូទៅនៃជនជាតិខ្មែរយើងក្នុងប្រវត្តិសាស្ត្ររបស់ ខ្លួន ។

ដូចនេះយើងជឿជាក់យ៉ាងមុតមាំថា តាមរយៈភស្តុតាងរូបភាពទាំងនោះ ប្រជាជនខ្មែរយើង អាចនឹងយល់ដឹងយ៉ាងច្បាស់ថា ព្រះបាទសម្តេចព្រះបរមនាថ ព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ ជាទីគោរពសក្ការៈនៃយើងទាំងអស់គ្នា ដែលជាព្រះរាជបុត្រដ៏ធ្នើមរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន និង សម្តេចព្រះរាជអគ្គមហេសី នរោត្តមមុនិនាថ សីហនុ ទ្រង់ពិតជាបានត-វង្សត្រកូលពីព្រះមហាវីរៈក្សត្រខ្មែរនា សម័យមុនៗមែនដែលបានកសាង/ស្ថាបនាគាំពារ ការពារទឹកដី មាតុភូមិកម្ពុជាដ៏ពិសិដ្ឋនេះឲ្យបានគង់វង្ស រហូតដល់សព្វថ្ងៃដោយបានធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងអស់ ។

ក្នុងនាមយើងជាកូនខ្មែររាល់រូប គប្បីយើងត្រូវមានកាតព្វកិច្ចថែរក្សាអោយបានគង់វង្សនូវទំព័រប្រវត្តិសាស្ត្រយើង ព្រោះយើងជាជាតិមួយប្រកបដោយ វឌ្ឍភាពដ៏ខ្ពង់ខ្ពស់អស្ចារ្យក្នុងអតីតកាលដ៏យូរលង់ជាពិសេសនាសម័យមហានគរដ៏បវរ ។

ជាអវសាន យើងសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅដល់បណ្ណាល័យសាលាបារាំងសែសមជ្ឈឹមបូព៌ា ដែលបានអនុញ្ញាតឲ្យយើងចម្លងឯកសារដ៏កម្រនេះ ដើម្បីបោះពុម្ពផ្សាយជូនខេមរជន ។

ជយោ ! ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ តុលា ឆ្នាំ ២០០៤

**បណ្ឌិត មីសែល ត្រាណេ**

អតីត អនុរដ្ឋមន្ត្រី នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

(រាជរដ្ឋាភិបាលបណ្ដោះអាសន្ន)

# ប្រវត្តិសាស្ត្រខ្មែរ

ខ្ញុំឈ្មោះ ឡឿ វ៉ាន់ ជាតិខ្មែរ ភូមិនៅជិតក្បែរប្រឞវត្ត
នាមអង្គពន្លឺប្រាកដ សន្ធតឃុំហៅភ្នំកុង ។
តំបន់ប៉ុស្តិ៍ឈ្មោះតានី នាទីរាជការក្រៅក្រុង
ទល់ព្រំនឹងឃុំសន្លុង នៅក្នុងស្រុកបន្ទាយមាស ។
រួមខេត្តកំពតជាក់ស្តែង ខ្លួនខ្ញុំនេះឯងជាតិរាស្ត្រ
កាញ្ចគិតគំនិតវាងវាត តែពុំសូវឈ្លាសកាព្យា ។
សូមថ្លែងប្រវត្តិសាស្ត្រសែ ជាតិខ្មែរក្រុងកម្ពុជា
ទុកគដិណភាវា ជូនជាតិរាល់គ្នាដឹងជាក់ ។
ដឹងជាតិកំណើតខ្លួនឯង មែនស្តែងប្រាកដខេមរៈ
សង្ខេបសេចក្តីខ្លីជាក់ គ្រប់វត្តក្នុងពង្សាវតា ។
ផ្ចិតផ្ចង់ដកស្រង់តម្រូវ អំពីសៀវភៅសិក្សា
គ្រប់វត្តកំណត់សាលា សម្រាប់កុមារប្រុសស្រី ។
ក្នុងដែនក្រុងកម្ពុជា វេទ្យារៀនដឹងសេចក្តី
ប្រវត្តិសាស្ត្រជាតិចាស់ថ្មី គប្បីដឹងច្បាស់បុព្វហេតុ ។
ដឹងដើមកំណើតទឹកដី ប្រុសស្រីគួរតុំបណ្តែត
មើលក្បួននឹងឃើញក្រឡេត ឃើចិត្តឆ្អិតឆ្អែតស្តាយក្រោយ ។
ស្តាយក្រុងកំឡុងជាន់ដើម ឫទ្ធិសម្បើមមិនខ្សោយ
ខ្មែរមានរបៀបរៀបរយ ទទឹងបណ្តោយធានី ។

ធំណាស់សាសន៍យើងជាងនោះ ពីរោះគេរ្កីឈ្មោះគ្មានពីរ
ល្បីល្បាញក្នុងទ្វីបអាស៊ី សាសន៍សព្វទិសទីកោតក្រែង ។
សម័យសម្ដេចសោយរជ្ជ នៅអង្គរវត្តជាក់ស្ដែង
ប្រាសាទស្អាងស្អាតចិញ្ចែង ល្អក្រៃងលើសលែងក្នុងភព ។
ខ្ញុំឃើញប្រវត្តិសាស្ត្រខ្មែរ ជាតិខ្លាំងពូកែលើសលប់
ព្យាយាមទាំងថ្ងៃទាំងយប់ ប្រារព្ធចម្លងសេចក្ដី ។
ជាពាក្យកំណាព្យកាព្យឃ្លោង យិតយោងយឿងយ៉ាងថ្មី
ទុកតតំណបូរី ប្រុសស្រីមើលដឹងគ្រប់ប្រាណ ។
តែងក្នុងសករាជសាសនា អតិកន្តាប្រមាណ
ពីរពាន់បួនរយប៉ែតបាន ប្រាំបីអវសានកំណត់ ។
ក្នុងឆ្នាំកោនព្វសក វស្សន្តជៀងជាក់ប្រាកដ
ប្រកបរបរបែបបទ ច្បាប់លោកសន្មតទុកមក ។
ចារឹកអក្សរថ្វជា ខេមរាជាតិផងគន់រក
មើលគិតរំពៃលៃលក រាវរកចាណាំលក្ខណ៍ថាន ។
រីមួយជាន់ដើមមហាក្សត្រ សោយរាជ្យសម្បត្តិប៉ុន្មាន
នៅក្នុងបូរីដែនដាន ក្សត្រក្សាន្តមានឫទ្ធិបារមី ។
មានភោគសម្បត្តិស្ដុកស្ដម្ភ មួនមាំក្នុងទ្វីបលោកិយ
ស្ញប់ស្ញែងរឹទ្ធិព្ទល្បី ប្រុសស្រីប្រទេសទាំងឡាយ ។
កាត់មករកមើលអង្គរ កិត្តិស័ព្ទខ្ពរវែងឆ្ងាយ
កោតស្ញើចសរសើរស្មុះសាយ រៀងរាល់រូបកាយប្លែកៗ ។
ចារឹកទូវថ្មសប្រាប់ នាមស្ដេចចំណាប់ឯកៗ
តៗតំណដោយឡែក លេខាចារចែកប្រាប់ឈ្មោះ ។

គេមើលអក្សរបូរាណ នោះបានឃើញពិតចំពោះ
នឹងថាស្តេចខ្មែរមានយស ពីព្រោះឃើញមានប្រាសាទ ។
ប្រសើរធំខ្ពស់ល្អៗ ប្រក់ព្រំសឹងថ្មស្អាត
តម្រូវត្រឹមត្រូវក្បូនខ្នាត វៃឆ្លាតជាងចេះរចនា ។
ខ្លះថាប្រាសាទទាំងនោះ ចំពោះមិនគឺមនុស្សា
ធ្វើបានចំណានអស្ចារ្យ គឺជាទេវតានិមិត្ត ។
ជញ្ជាំងគ្រប់ជ្រុងកំផែង ស្ងប់ស្ញែងដៃជាងចេះគិត
គួរឆ្លាក់ហាក់គ្រឿងមាសពិត ធ្វើដោយពិនិត្យហ្មត់ចត់ ។
ក្នុងប្រាង្គសាងរូបល្អៗ សុទ្ធធ្វើពីថ្មប្រាកដ
ច្រើនឥតគណនាកំណត់ សឹងមានបែបបទដោយយ៉ាង ។
រូបព្រះសូត្រាប្រធាន ព្រះព្រហ្មមែនមានតំណាង
ឥស្សរនរាយណ៍ជាយខាង ជញ្ជាំងព្រះប្រាង្គបែបបទ ។
ឆ្លាក់ជាអក្សរបូរាណ មើលបានដឹងរឿងប្រវត្តិ
សាស្ត្រខ្មែរជាតិកម្ពុជរដ្ឋ មានឫទ្ធិអំណាត់យូរយារ ។
មិនតែប៉ុណ្ណោះឡើយនែ ប្រាសាទដទៃនានា
ច្រើនណាស់ក្នុងដែនភារា សាងបែបវិហារក្តីណា ។
បែបប្រាង្គមានកំពូលស្រួច ខ្ពង់ខ្ពស់ត្រដូចអស្ចារ្យ
បណ្តុះជីវាដងក្ការ សាងបែបចេត្យាបួនជ្រុង ។
បែបមូលកំពូលមុខបួន ល្អល្អះសមសួនត្រទុង
ទទឹងបណ្តោយល្អល្អុង បែបជាទីក្រុងបូរាណ ។
សាងធ្វើពីថ្មពីឥដ្ឋ វិចិត្រក្បាច់ក្បូររូបហាន
ប្រាសាទសាងស្អាតប៉ុន្មាន ច្រើននៅទីឋានអង្គរ ។

មិនគឺទេព្កានិមិត្ត បើតាមគេគិតវុករក៏
ឃើញពង្សាវតានគរ ស្តេចខ្មែរសាទរសាងទុក ។
ព្រះកេរដំណែលស្រុកខ្មែរ កាលគ្មានភាន់ប្រែកលយុគ
មានជ័យជំនះគ្រប់មុខ ទំនុកដំណមិនយូរ ។
រវាងជាងមួយពាន់ឆ្នាំ ស្តេចខ្មែរប្រចាំគិតគូរ
សាងនគរវត្តយ៉ាងស៊ូ ទុកជាគំរូបុញ្ញឫទ្ធិ ។
រាជវាំងព្រះប្រាង្គយ៉ាងល្អ កសាងពីថ្មពិត១
នៅអង្គរវត្តកត់ពិត ពិនិត្យឃើញពង្សាវតារ ។
និងអង្គរធំជាតាង ស្តេចសាងក្នុងគ្រិះសាសនា
រវាងប្រាំបីរយហា លុះគ្រារៀងដល់មួយពាន់ ។
ពីររយហាសិបជាក់ស្តែង នៅស្វែងរហូតគ្រប់គ្រាន់
ល្បីល្បាញរន្ទឺព្ទលាន់ គ្រប់ទីតំបន់ក្នុងលោក ។
មិនត្រឹមតែទ្វីបអាស៊ី អាសោចជាទីស្មោកគ្រោក
សាសន៍ជាតិធ្លាប់មានជ័យជោគ ច្រើនក្រែកគោកឧរ៉ាល់ ។
អឺរ៉ុបភ្អែកសភ្អែកលឿង ភ្អែកក្រហមព្រឿងទុយគាល់
ជិះយានចក្រមានដង្កាល់ នាវាកប៉ាល់តូចធំ ។
ឆ្លងកាត់សមុទ្រទឹកខ្មៅ ទឹកខៀវសំដៅវាងភ្នំ
វាងកោះចន្លោះដែនព្រំ ដែនប្របនិគមអារ៉ាប់ ។
ទូរគីរុស្ស៊ីចិនក្លិង្គ ខំប្រឹងរូតរះប្រញាប់
ឡើងឥណ្ឌូស៊ីនឆាប់១ ប្រថុយរស់ស្លាប់មិនថា ។
ឱ្យតែបានដល់អង្គរ ឡើងមើលវីវរត្រៀបត្រា
កោតស្តែងក្រែងព្រះចេស្តា ស្តេចជាតិខេមរារៀងខ្លួន ។

ទីពីរវិធីអធិប្បាយ　　បរិយាយពន្យល់តាមក្បួន
សាវតារដោយការសមសួន　　កែតាមពាក្យជូនអំពី ។
កកើតទឹកដីស្រុកខ្មែរ　　តម្រែតម្រូវសញ្ញី
កន្លែងឈ្មូងជាធានី　　នាទីហៅកម្ពុជា ។
អង្វែងច្រើនពាន់ឆ្នាំហើយ　　ដើមឡើយសុទ្ធសឹងជលសារ
សមុទ្រធំណាស់គណនា　　ឈូងជាខាងលិចទល់ភ្នំ ។
កំចាយខាងជើងដោយឡែក　　ទល់ភ្នំដងរែកជាព្រំ
ខាងកើតឈូងសមុទ្រធំ　　ទៅទល់នឹងភ្នំស្រុកយួន ។
ហើយសឹងមានកោះដាច់ៗ　　មិនបាច់រៀបរាប់ចំនួន
ដំណឹងដឹងតិចតាមក្បួន　　នៅពុំទាន់សួនដោយឡែក ។
វស្សានរដូវខាងជើង　　ទំនើងទឹកជន់ហូរចែក
ហូរចុះពីភ្នំដងរែក　　ច្រើនក្រៃអនេកគណនា ។
និងហូរពីភ្នំដងទៃ　　ស្ទឹងអូរក្នុងព្រៃអធ្វា
ហូរចុះទន្លេគង្គា　　នាមាមេគង្គនេះឯង ។
ទន្លេនេះធំពេកពិត　　បើតាមពិនិត្យឱ្យស្តែង
ពីលាវក្រចេះស្ទឹងត្រែង　　យូរយារអង្វែងឆ្នាំណាស់ ។
គេអាចកំណត់មិនកើត　　កំណើតទន្លេបឹងស្រះ
សមុទ្រឬភ្នំថ្មីចាស់　　កើតមកប្រទះឃើញនៅ ។
ទន្លេសាបសោតធំបំផុត　　ប្រហែលសមុទ្រទឹកជ្រៅ
ក្នុងស្រុកខ្មែរមានឃើញនៅ　　កប៉ាល់សំពៅបើកបាន ។
ផែនទីអាស៊ីទិសបូពិ　　មើលដឹងហែហូរមិនខាន
ទន្លេសមុទ្រប៉ុន្មាន　　ស្ទឹងព្រៃចំណាននានា ។

ម្យ៉ាងទៀតទន្លេមេគង្គ ទឹកហូរផុង១ចាក់ធា
ហូរជ្រោះបាក់ច្រាំងគង្គា នាំនាដីល្បាប់ភក់ជ្រាំ ។
នាំដីកណ្តេងដីខ្សាច់ រំកាច់ឈើព្រៃស្លែព្រាំ
រលំរលើងខ្ទេចខ្ទាំ ខ្សែទឹកគួចនាំទាំងដើម ។
សណ្តកទាំងឫសទាំងគល់ ជោរជល់ជនយ៉ាងសម្បើម
ទីនោះទីទាបជ្រាបសើម ទន្លេនេះឆ្នើមណាស់ដែរ ។
ចេះពាំនាំយកប្រថពី ពីទីដទៃកាន់ខែ
កាន់ខួបរដូវហូរហែ រសាត់តាមខ្សែទឹកជន់ ។
ហូរកាត់ឈូងសមុទ្រ ច្រើនក្រៃបំផុតពេកពន់
ទន្លេនេះមានគុណធ្ងន់ ជួយបណ្តាជនជាតិខ្មែរ ។
ចេះសាងនគរថ្វាយស្តេច ខោសខ្សាច់ដីដុះហូរហែ
ជាច្រើនពាន់ឆ្នាំខួបខែ រឿង១បន្ថែមមិនដាច់ ។
ដីដុះចុះដេញទឹកប្រែ ថយក្រោយឆាប់ក្រៃកើតខ្សាច់
កើតគ្រួសរវ៉ានមានស្រេច កោះដែរដាច់១ពីគ្នា ។
នៅក្នុងឈូងសមុទ្រនោះ គេសន្មតឈ្មោះហៅថា
ភ្នំ១ទៅវិញតាមក្រ ដីកម្ពុជាកើតមាន ។
តាំងតែពីនោះមក តាមតម្រាលោកនិទាន
ក្នុងរបាក្សត្រឫវ៉ាន ចាស់ហ៊ានប្រកាសថ្មី១ ។
ថាស្រុកខ្មែរកើតមុនគេ យួនវៀតណាមនោះក្តី
កូសាំងស៊ីនផងជាបី ដែនដីដុះជាតំណ ។
បន្ទាប់ក្រោយកម្ពុជា ចាស់ព្រឹទ្ធាព្យាករណ៍
ប្រាប់កូនប្រាប់ចៅខ្មៅស ដឹងតរឿង១រាល់ប្រាណ ។

ទន្លេមេគង្គនោះណា ទុកដូចទេវតាសួគ៌ឋាន
ទំនុកបម្រុងដែនដាន ខ្មែរយូនមិនខានដឹងគុណ ។
សព្វថ្ងៃទន្លេមេគង្គ នៅនាំភក់ផុងដូចមុន
រដូវភ្លៀងទម្ងន់ ហូរជន់ចាក់ដីគ្មានខាន ។
កាលបើមានដីដុះ មិនជាយូរឡើយប៉ុន្មាន
មានមនុស្សពួកមួយចូលថ្កាន មកនៅដែនដានដីដុះ ។
ជាតិថ្វាសម្បុរសជ្រះ មានក្មេងមានចាស់ស្រីប្រុស
ប្រហែលសាសន៍ចាមមិនខ្វះ ចូលទៅកោះនោះបឋម ។
លុះយូរលង់មកលេចភ្លាម មនុស្សជាតិថ្វាព្រាហ្មណ៍ខ្មៅសម
មកពីស្រុកថ្វានានាំ គ្រួសារចូលចំមកកោះ ។
ចូលនៅលាយឡំផងគ្នា កើតជាកូនចៅខ្មៅស្រស់
ប្លែកៗដោយយ៉ាងទាំងអស់ មិនស្មោះជាខ្មៅឬស ។
អ្នកស្រុកប្រកាន់ត្រកូល ខ្លះពុំព្រមចូលអបអរ
នឹងថ្វាព្រាហ្មណ៍ឡើយក៏ ឈូនរុកទៅពឹងពួន ។
ក្នុងភ្នំដទៃនានា ក្លាយជាតិដើមថ្វារៀងខ្លួន
ត្រឡប់បានឈ្មោះបីបួន រៀបរាប់ចំនួនពិស្តារ ។
ប្រហែលមនុស្សព្រៃច្រាកដ សន្ធតគឺក្នុងស្មៀងខា
ឬ កួយ សំរែ ក្តីណា យកព្រៃព្រឹក្សាពឹងពាក់ ។
ក្រោយមកដល់សាសនាគ្រឹះ បួនរយឆ្នាំនេះជឿងជាក់
មានមនុស្សសម្បុរកាកល័ក្ខ ខ្មៅៗស្មើរស្មាក់ជាតិក្លិង្គ ។
កាត់មកពីស្រុកឥណ្ឌា ចិត្តមុតមហិមារបឹង
ចូលពីពាយព្យជាន់ហ្នឹង គ្មានភ័យព្រួយប្រឹងកាញ់ភ្លេ ។

ក្នុងក្រុមមនុស្សក្រោយរយពាន់ ពូកមួយសំខាន់ជាងគេ
មានមនុស្សសាងពីបុព្វេ នាមេក្នុងក្បួនប្រវត្តិ ។
គឺមនុស្សសាសន៍កម្ពុជា មានវិទ្ធសម្ភារប្រាកដ
បំបាក់អ្នកស្រុកបានបទ មនុស្សកម្ពុជារដ្ឋប៉ុន្មាន ។
កាត់កើតកូនចៅត១ តំណរៀង១រាល់ប្រាណ
ពូជដើមឆ្នើមជាតិក្លាហាន លំអានដូចបានថ្លែងមក ។
ទីបីបូរីខេមរា ពីដើមហៅថាគោកធ្លក
ជាឈូងសមុទ្រញោចញក ដុះកើតដើមធ្លកមុនគេ ។
ចិនហៅនគរហ្វូណាន់ តំបន់ប្រសប់ទន្លេ
ហូរនាំល្បាប់ភក់ផុកផ្សេរ ពុំខានទំនេរឆ្នាំណា ។
នគរហ្វូណានធំណាស់ ចិនបានប្រទះឃើញថា
ធំជាងសព្វថ្ងៃអស្ចារ្យ ខាងបត្តពាទិសទី ។
ទល់នឹងស្រុកយួនតុងកឹង ជាន់ហ្នឹងធំណាស់ធានី
បច្ចិមទិសប្រថពី វារីទន្លេនាមឈ្មោះ ។
មេណាមនៅក្នុងស្រុកថៃ ឬសៀមសព្វថ្ងៃចំពោះ
ហ្វូណាន់លេចឡើងថ្កើងយស សង្គ្រោះក្នុងរឿងប្រវត្តិ ។
ជាតិដើមបំផុតពូជថ្លា ពណ៌នាតាមគោលកំណត់
កំណើតខ្មែរកម្ពុជារដ្ឋ ជនបទខាងត្បូងលិចទឹក ។
លិចទួលទំនួលខ្ពស់ទាប ទឹកជ្រាបជោរនាចយប់ព្រឹក
អ្នកស្រុកធ្វើទូកសន្ទឹក ចតនៅលើទឹកធម្មតា ។
នៅតែលើទូកតាងផ្ទះ អ្នកស្រុកក្មេងចាស់ចេះការ
ធ្វើទូកធ្វើចែវច្រវា ចាប់ជាតិមច្ឆាអាស្រ័យ ។

ឯមនុស្សអ្នកស្រុកហ្វូណន់ ពុំទាន់ចេះត្បាញរវៃ
ស្រាតខ្លួនទទេគ្មានភ័យ ខ្មាសគ្នាដទៃទៅមក ។
មនុស្សជាតិហ្វូណន់នេះនៃ ប្រហែលមនុស្សព្រៃក្នុងលោក
ខ្លួនប្រាណក្រវាំមស្អាមព្រោក ទឹកខ្មៅរត់ជោកជាំសាច់ ។
ប្រុស១សាក់ពេញទាំងខ្លួន ចិត្តមុតមាំមួនបួរផ្តាច់
ឈ្មោះណាទោសធ្ងន់សម្រេច ជីវិតមិនបាច់កាប់ចាក់ ។
គេយកមនុស្សទោសនោះឯង លើកបោះក្រវែងទម្លាក់
ក្នុងទឹកទន្លេជ្រៅរាក់ ក្រពើត្របាក់ខាំស៊ី ។
ឬយកទៅដាក់ទ្រុងខ្លា ឱ្យជាអាហារព្យគ្ឃី
វាខាំចិញ្ច្រាំខ្ទេចខ្ទី មិនថាស្រីញីបុរស ។
មនុស្សណាមានទោសឧក្រិដ្ឋ មិនស្និតដាក់គុកទាំងអស់
មិនយកទៅប្រោសក្នុងកោះ មិនតិរទេសសោះដល់ម្តង ។
ជិរះរកទោសឧក្រិដ្ឋ គេធ្វើប្រៀនប្រិតកន្លង
បួងសួងសច្ចាហើយហោង គេឱ្យមនុស្សផងត្រូវចោទ ។
លូកយកពងមាន់ក្នុងទឹក ដែលពុះក្រឹក១ពិសោធ
បើវៀចឱ្យក្តៅច្រឡោត ដូចគេចាក់ដោតខ្លោចផ្សា ។
បើត្រង់សុចរិតឥតក្តៅ ទំពារស្រូវនៅបានការ
ពុំមានមុតដាច់ជីវ្ហា បើវៀចរអារឈាមមាត់ ។
រីឯនគរហ្វូណន់ តំបន់រាត់រាយជនបទ
ពុំមូលត្រកូលឡើងទាត់ ក្នុងភារាដ្ឋមួយទេ ។
បែកស្រុកជាច្រើនកន្លែង ត្រួតត្រាគ្នាឯងដោយមេ
លើកគ្នាជាស្តេចពួកគេ គំនិតរិះរេរៀងខ្លួន ។

ឯស្រុកផ្តុំគ្នាមួយនោះ នាមឈ្មោះសំខាន់មាំមួន
កម្ពុងក្នុងទិសទាំងបួន មិនតិចចំនួនប៉ុណ្ណា ។
គឺស្រុកពាមទន្លេធំ ប្រសប់ដែនព្រំជលសា
សមុទ្រខាងកើតរដ្ឋា ទីក្រុងសីមាកំណត់ ។
នៅចំទន្លេបាសាក់ មាត់ជ្រូកជ្រៀងជាក់ប្រាកដ
នាវាសំពៅបើកបត់ ចេញចូលទៀងទាត់រាល់ថ្ងៃ ។
ក្នុងគ្រិស្តសករាជប្រចាំ មុនមួយរយឆ្នាំក្រុងក្រៃ
ស្តេចស្រុកហ្វូណន់អន់ដៃ មានក្សត្រីថ្លៃមួយអង្គ ។
ព្រះនាងលីវយីសោយរាជ្យ ព្រីកល្ងាចសុចរិតពិតត្រង់
ព្រះទ័យអាសូរផ្សូរផង់ ទ្រង់ចង់អោយសុខជនា ។
ក្រោយមកថ្វាព្រាហ្មណ៍ចូលលក់ លីវយីកើតទុក្ខមហិមា
លើកទ័ពទៅតតាំងគ្នា រាំងរាសត្រូវនោះឯង ។
ទ័ពខាងព្រះនាងលីវយី ច្បាំងទប់គ្រប់ទីកន្លែង
ទ័ពខាងថ្វាព្រាហ្មណ៍ភ្លាមផ្លែង ផ្ទួសរសសែងអស្ចារ្យ ។
ទ័ពខាងព្រះនាងលីវយី ស្លុតស្លាប់ខ្ទេចខ្ទីគ្រៀបគ្រា
បាក់ទ័ពត្រឡប់បរា ជ័យចាញ់ចេស្តា ហ៊ុន ទៀន ។
ជានាយចៅហ្វាយថ្វាព្រាហ្មណ៍ ចូលភ្លាមដល់ច្រកកោះគៀន
ប្រព្រឹត្តភ្លេចគិតខ្មាសអៀន ញាំបញ្ចៀនសម្ផស្សកាមគុណ ។
ហ៊ុន ទៀនយកនាងលីវយី ធ្វើជាទេពីជាមុន
ថ្កុំថ្កើងឫកឡើងយីអ៊ុន អស៊ុនឥតអ្វីប្រៀបបាន ។
ហ៊ុន ទៀន បានឡើងជាស្តេច សម្រេចភូមិភពដែនដាន
អ្នកស្រុកហ្វូណាន់ប៉ុន្មាន រាប់អានស្រឡាញ់ព្រះអង្គ ។

ព្រះបាទ ហ៊ុន ទៀន ចក្រី ប្រកាសសេចក្តីតម្រង់
តម្រូវឱ្យបានត្រូវត្រង់ ព្រះទ័យព្រះអង្គរាប់អាន ។
ឱ្យរាស្ត្រទាំងអស់ស្រឡាញ់ ព្រហ្មញ្ញសាសនាគ្រប់ប្រាណ
ប្រយ័ត្នបដិបត្តិឱ្យបាន ក្សត្រក្សាន្តដាក់ក្រិត្យបញ្ជា ។
វង្សស្តេច ហ៊ុន ទៀន តំណ សោយរាជ្យត។រៀងគ្នា
ជួបចប់រៀបរាប់វេលា យូរយារបីរយឆ្នាំគិត ។
ស្តេចដែលល្បីនាមសំខាន់ ព្រះនាមហ្វាន់ច័នមែនពិត
និងហ្វាន់ស៊ីយុនទ្រង់រិទ្ធិ ពិនិត្យរៀបចំផែនដី ។
ឱ្យបានពូកែមាំមួន ថែធួនរក្សាបូរី
ថ្កុំថ្កើងរុងរឿងរង្សី លេចឡើងឮល្បីនាមឈ្មោះ ។
នាំសារទៅមកមិនភ្លេច ថ្វាយស្តេចក្រុងចិនចំពោះ
និងស្តេចឥណ្ឌាគ្មានលោះ ពីព្រោះចងស្ពានមេត្រី ។
ស្តេចធំនគរទាំងពីរ ជាទីស្មោះស្ម័គ្រភក្តី
ក្នុងរាជ ហ៊ុន ទៀនចក្រី មហាជនប្រុសស្រីប៉ុន្មាន ។
ចេះស្លៀកសំពត់ពាក់អាវ មានក្នុងមានក្រៅគ្រប់ប្រាណ
ចេះខ្មាសអៀនខ្លះមិនហ៊ាន ស្រាតដូចបុរាណសម័យ ។
ទីបួនសំនួនពណ៌នា ពីកម្ពុជាជាតិថ្លៃ
គឺសាសន៍ខ្មែរយើងសព្វថ្ងៃ ដែលនៅអាស្រ័យហ្វូណន់ ។
មកពីឥណ្ឌាប្រទេស ប្រទិនទេសមហន្ត
មហានគរតំបន់ អនេកអនន្តអស្ចារ្យ ។
ពាក់កណ្តាលឆ្នាំព្រះគ្រិស្ត បួនរយក្រោយនេះថ្លែងថា
មានមនុស្សខ្មៅជាតិព្រាហ្មណា ឫសន្ទតថាក្លីង្គក្លាយ ។

| | |
|---|---|
| ចូលពីពាពយ្យទិសទី | មកដល់ធានីខ្មែរឱ្យ |
| ត្រេកអរសាទរសប្បាយ | ឯនាយចៅហ្វាយនាមឈ្មោះ ។ |
| កោណ្ឌញ្ញជ័យវរ៉្មន | សំខាន់មានឫទ្ធិក្លៀវក្លា |
| ស្ដេចច្បាំងឈ្នះចាមអស្ចារ្យ | និងស្ដេចសីមាជិតខាង ។ |
| នៅនាទិសបូពិហ្វូណន់ | ក្សត្រថ្លៃសោភ័ណចមប្រាង្គ |
| ទ្រង់យកស្ដេចចិនជាអាង | ជាមិត្តជួយសាងបុរី ។ |
| ទើបស្ដេចចេញធ្វើសង្គ្រាម | មានជ័យភ្លាមៗដូចក្ដី |
| ព្រះរាជបំណងចក្រី | ឥតបីទើសទាស់ឡើយណា ។ |
| នគរហ្វូណន់ធំណាស់ | មិនបានប្រទះឃើញថា |
| គេបំបែកស្រុកត្រួតត្រា | អនេកប្បការដោយឡែក ។ |
| មិនចុះចំណុះគ្នាសោះ | ទាំងអស់តែឥតប្រកែក |
| នាំសួយទៅថ្វាយស្ដេចឯក | ចំណែកគឺស្ដេចហ្វូណន់ ។ |
| ឯមនុស្សដែលមកអំពី | ធានីឥណ្ឌាមហន្ត |
| មហាប្រទេសតំបន់ | ក្នុងជាន់កោណ្ឌញ្ញព្រាហ្មណ៍ស្ដេច។ |
| ជាតិមួយក្លាខ្លាំងពូកែ | សម្បើមណាស់ដែរប្តូរផ្ដាច់ |
| ជាងជាតិដទៃសម្រេច | មិនបាច់រៀបរាប់សេចក្ដី ។ |
| មនុស្សនោះជាតិកម្ពុជា | ចូលមកភារាជែនដី |
| ដល់ស្រុកហ្វូណន់បុរី | ចេញស្ដីត្រួតត្រាខេត្តខ័ណ្ឌ ។ |
| អ្នកស្រុកបាក់បបខ្លបខ្លាច | ពុំអាចអាងអួតប្រកាន់ |
| ទាំងប្រុសទាំងស្រីខ្ចីខ្ចាន់ | កំណាន់ទទួលបង្គាប់ ។ |
| ប្រមូលបរិវេណធានី | ជាតិចំណែករៀបរាប់ |
| ដូចមានខាងក្រោមគ្រប់សព្វ | លប់លើសទម្លាប់ធម្មតា ។ |

ស្រុកមួយខាងជើងសោតសល់ ទឹកលិចមិនដល់ឡើយណា
ទីក្រុងសម្ភុបុរា ហៅថាសម្បូណ៌សព្វថ្ងៃ ។
ស្រុកមួយខាងត្បូងទឹកលិច រាល់ឆ្នាំជានិច្ចច្រើនក្រៃ
អ្នកស្រុកគ្មានផ្ទះអាស្រ័យ នៅទូកប៉ុកចៃនាវា ។
វ្យាធបុរាទីក្រុង កម្ពង់រមខេត្តនាមា
តាកែវមែនពិតជិតគ្នា សព្វថ្ងៃជនាគេហៅ ។
ថាស្រុកអង្គរបុរី ជំរែលផែនដីព្រះចៅ
ជាតិកម្ពុជាក្នុងសៅ វិតាសំណៅទុកត ។
លុះយូរលង់មកគេចាំ បានមួយរយឆ្នាំជំណ
មានស្តេចមួយទ្រង់រូបល្អ កាន់ទសពិធធម៌នាមា ។
ព្រះបាទភវវរ្ម័ន សំខាន់ជាម្ចាស់ភារា
សោយរាជ្យក្រុងកម្ពុជា ប៉ែកទក្ខិណាទិសទី ។
ទ្រង់ខ្លាំងពូកែបំផុត ប្រយុទ្ធប្រយោជន៍ធានី
វាយស្រុកតូចៗខេត្តខ្មី ខ្ចប់ខ្ចាចបុរីព្រះអង្គ ។
កន្លងបូនដប់វស្សា ក្សត្រាសោយរាជ្យតម្រង់
នគរហ្វូណន់ឱ្យត្រង់ ត្រឹមត្រូវចំណង់ព្រះទ័យ ។
លុបឈ្មោះនគរហ្វូណន់ ជានាមឈ្មោះអន់ជោគជ័យ
ហៅកម្ពុជាវិញវៃ តាមជាតិប្រពៃស្តេចស្តែង ។
ព្រះបាទភវវរ្ម័ន សំខាន់ល្បីល្បាញស្ញប់ស្ញែង
តាំងឈ្មោះនគរច្នេះឯង នាទីតាំងស្រុកខ្មែរ ។
ធ្វើសឹកសង្គ្រាមនិរភ័យ ឈ្នះឈ្នាន់មានជ័យហូរហែ
វាយយកស្រុកនៅក្បែរៗ បានច្រើនណាស់ដែរខេត្តដែន ។

ខាងជើងទល់ភ្នំដងរែក និងជួរខ័ណ្ឌចែកបត់បែន
ចម្រើនសួយសារម៉ឺនសែនវែវក្វែន វែវក្វែនក្បួនសឹកថ្មីកណាស់ ។
ឯស្តេចដែលសោយរាជ្យត តំណសឹងមានតេជៈ
ជាតិចិនបានជួបប្រទះ ឃើញច្បាស់ហើយកត់ទុកថា ។
ក្រុងធំព្រះមហាក្សត្រក្សាន្ត គ្រឹះស្ថានមានប្រើអស្ចារ្យ
ចំនួនពីរម៉ឺនគេហា ក្នុងកាលនោះណាមហាក្សត្រ ។
ទ្រង់ព្រះភូសាក្រហម ទីកដបរលោងល្អក្អាត់
អាវជរជាផ្កាភ្ញីកាត់ ព្រះកាមាក្សត្រសចាំង ។
ទ្រង់ព្រះរយាមាសសុទ្ធ ព្រះកេសទ្រង់មកុដស្រួចស្រាង
ដាំពេជ្រមុក្តាគ្រប់យ៉ាង ប្រឫបខាងព្រះអង្គធម្មតា ។
មានមនុស្សអង្គុយឱនទ្រោប ដុតឈើក្រអូបអស្ចារ្យ
សុទ្ធសឹងខ្លឹមច័ន្ទក្រស្នា ក្នុងជើងសុវណ្ណរាល់ថ្ងៃ ។
ទីប្រាំបីបណ្ដាំសាវតារ ក្នុងដែនរដ្ឋាថ្លាថ្លៃ
ជាហេតុគ្រោះកាចចង្រៃ ក្រុងក្រៃចាញ់ដៃសាសន៍ថៃ ។
កាលក្នុងសាសនាព្រះគ្រិស្ត ប្រាំពីររយនេះភារា
បែកពួកពីរទៀតផ្សេងគ្នា ដល់មកក្នុងគ្រាសាសនា ។
ប្រាំពីររយប៉ែតសិបប្រាំពីរ សាសន៍ជ្វាមកពីរដ្ឋា
ស្រុកជ្វាគ្នាច្រើនអស្ចារ្យ ចូលឡោមសីមាខេមរៈ ។
ខេមរៈច្បាំងទប់មិនឈ្នះ ចាញ់ជ្វាស្រឡះព្រមដាក់
គ្រឿងយុទ្ធអាវុធទម្លាក់ ដែនកម្ពុជៈរដ្ឋា ។
ចំណុះជាតិជ្វាមហាម៉ាត់ នាំសួយសារកាត់ជលសា
ទៅថ្វាយស្ដេចជ្វាធម្មតា មកពីខេមរាលោភយស ។

| | |
|---|---|
| ដណ្ដើមអំណាចតតាំង | ច្បាំងនឹងគ្នាឯងគ្មានលោះ |
| គ្មានលើកស្ទួយជាតិឱ្យខ្ពស់ | ពីព្រោះគ្មានធម៌សាមគ្គី ។ |
| កាន់ចិត្តច្រណែនឈ្នានីស | ដល់មកក្នុងសាសន៍ |
| រវាងប្រាំបីរយពីរ | សំភីមើលក្បួនឃើញថា ។ |
| មានស្ដេចខ្មែរមួយព្រះអង្គ | លះបង់បូរីរដ្ឋា |
| កាលជ្វាលុកលុយសីមា | បច្ចាមិត្តចាប់ព្រះអង្គ ។ |
| ទៅធ្វើជាឈ្លើយយូរយារ | វាជាមានព្រះបំណង |
| ប្រើនយោបាយតម្រង់ | តម្រូវត្រូវត្រង់ដកឃ្លា ។ |
| ស្រុកខ្មែរដែលកើតវិបត្តិ | ចំណុះមហាម៉ាត់យូរយារ |
| ស្ដេចវិលត្រឡប់ភារា | ក្រុងកម្ពុជាធិបតី ។ |
| ព្រះអង្គមានឫទ្ធិតេជៈ | មានជ័យជំនះត្រឹរ៉ី |
| បានឡើងសោយរាជ្យជាថ្មី | ចក្រីទ្រង់ព្រះនាមា ។ |
| ហៅព្រះបាទជ័យវរ្ម័ន | ទីពីរសំខាន់ឫទ្ធា |
| ទ្រង់ឈប់នាំសួយនានា | ទៅថ្វាយស្ដេចជ្វានោះឯង ។ |
| ប្រយោជន៍នឹងសំដែងឫទ្ធិ | អំណាចបពិតតម្កែង |
| ឱ្យគេគោរពកោតក្រែង | គូព្រះអង្គឯងប្រាកដ ។ |
| ដូចជាព្រះសូគិាល័យ | ត្រាស់វៃឱង្ការកំណត់ |
| ឱ្យសាងព្រះរូបបែបបទ | ដូចព្រះចក្រពត្រសុទ្ធសាធ ។ |
| ព្រះនាមសូគិារាជា | បើស្ដេចលីលាព្រះបាទ |
| ឬគង់ក្នុងប្រាង្គស្អាងស្អាត | ចេញក្រៅប្រាសាទក្ដីណា ។ |
| ឱ្យគេយកព្រះរូបនោះ | ទៅដាក់ចំពោះទីមស្នា |
| ព្រាហ្មណ៍បុរោហិតចាត់ការ | ថ្វាយព្រះចេស្ដាបួនទាក់ ។ |

សម្រាប់ធ្វើពិធីបុណ្យ រក្សាព្រះខ័ន្ធទ្រង់លក្ខណ៍
បម្រុងនៅក្នុងដំណាក់ ប្រសើរសមសក្តិពេកក្រៃ ។
ព្រាហ្មណ៍បុរោហិតព្រិទ្ធី នៅក្នុងប្រង្គមុនីសព្វថ្ងៃ
ហើយនិងព្រះខ័ន្ធថ្លាថ្លៃ សម្រាប់ភូវណៃស្តេចខ្មែរ ។
មានតាំងពីកាលនោះមក ប្រសិទ្ធីជោគហូរហែ
តគ្នាជាប់ជាក្រសែ នៅខ្លាំងពូកែដោយយ៉ាង ។
ព្រះបាទភវវរ្ម័ន កំណាន់ស្មោះសកសាង
ប្រាសាទព្រះខ័ន្ធនៅខាង អង្គរភស្តុតាងទុកត ។
ប្រាសាទស្ពានស្អាតអស្ចារ្យ នៅបន្ទាយផ្លារឧត្តរ
ក្រុងបាត់ដំបងក៏ល្អ ស្តេចនេះនាំកមុនគេ ។
ព្រះមហាក្សត្រនេះឯង ខ្នះខ្នែងមិនសល់ទំនេរ
តែងច្បាប់ទុកជាព្រះកេរ្តិ៍ រិះរេរៀបចំជាថ្មី ។
ហើយនិងរៀបចំសាសនា ទ្រង់លើកវ័យធាបូរី
ទៅគង់ក្បែរក្រុងមួយថ្មី នាមនៃហៅបាត់ដំបង ។
ទី ៦ ខ្ញុំសូមកែ ប្រវត្តិសាស្ត្រខ្មែរយើងហោង
អស់ស្តេចដែលសោយរាជ្យស្នង ត១មកផងគណនា ។
សឹងតែវង្សស្តេចវរ្ម័ន សំខាន់បំផុតទ្វជា
ស្តេចសឹកសង្គ្រាមដូចគ្នា ច្បាំងយកស្រុកគ្រាក្រោយមក ។
កាលណាបើច្បាំងមានជ័យ ឈ្នះជាតិដទៃរឹបយក
សម្បត្តិធនទ្រព្យរិះរក លៃលកចាប់ឈ្លើយមកប្រើ ។
ឱ្យសាងប្រាសាទធំ១ ប្រក់ព្រំសឹងថ្មប្រសើរ
ជាន់នោះស្រុកខ្មែរគ្រាន់បើ ថ្កុំថ្កើងណាស់តើបូរី ។

| | |
|---|---|
| ប៉ុន្តែជាតិចាមកំណាច | ខូចកាចចិត្តទ្រស្តអប្រិយ៍ |
| ចូលច្បាំងល្បងព្រះបារមី | នឹងស្តេចផែនដីស្រុកខ្មែរ ។ |
| ម្តង១បំណាងយ៉ាងយូរ | តស៊ូចង់ដឹងឫទ្ធិដៃ |
| ស្តេចយើងច្រើនខ្លាំងពូកែ | ចាមច្បាំងច្រើនតែចាញ់ដៃ ។ |
| ស្តេចខ្មែរដែលល្បីនាមឈ្មោះ | ចំពោះទូទៅក្រុងត្រៃ |
| ចិនចាមលាងយួនសៀមថៃ | ក្សត្រថ្លៃទាំងនោះគឺព្រះ ។ |
| ឥន្ទ្រាវរ្ម័នទីមួយ | រាស្ត្រគ្មានភ័យព្រួយសុខណាស់ |
| ហើយនិងក្សត្រថ្លៃអម្ចាស់ | ព្រះបាទយសោវរ្ម័ន ។ |
| ទាំងពីរព្រះអង្គឯងអាច | មានឫទ្ធិអំណាចសំខាន់ |
| ធមិ១០ប្រការស្តេចកាន់ | កំណាន់ជាប់ជាអលជី ។ |
| ក្នុងគ្រិស្តសករាជកំហិត | ប្រាំបីរយចិតប្រាំពីរ |
| ឥន្ទ្រាវរ្ម័នភូមី | បានទីអភិសេកជាស្តេច ។ |
| រួចទ្រង់បានសាងប្រាសាទ | ប្រសើរស្អាងស្អាតសម្រេច |
| ផុតគេផុតឯងល្អដាច់ | ប្រភពក្បូរក្បាច់រចនា ។ |
| ប្រាសាទបាគោបាគង | កុង្សីផងទ្រង់ចាត់ការ |
| សាងប្រាសាទមួយហៅថា | បាយ័នមានស្នាដៃដែរ ។ |
| អក្សរចារឹកផ្ទថា | ស្តេចនេះក្លៀវក្លាពូកែ |
| ធ្វើសឹកសង្គ្រាមហូរហែ | ប៉ុន្តែមិនពិតប្រាកដ ។ |
| ជាស្តេចច្បាំងនឹងសាសន៍ណា | គេចារសារតាប្រវត្តិ |
| គ្រង់នេះហាក់មិនទៀងទាត់ | កំណត់ជឿពុំស៊ុបសួន ។ |
| ដល់គ្រិស្តសករាជជាហេតុ | ប្រាំបីរយប៉ែតប្រាំបួន |
| ស្តេចមួយព្រះអង្គមាំមួន | ជួបជួនសំណាងយ៉ាងធំ ។ |

ព្រះនាមយសោវរ្ម័ន សំខាន់ល្បីគ្រប់និគម
កប់ព្រះលក្ខិណានិគម សោយរាជ្យប្រក់ព្រាំបូរី ។
ចារឹកអក្សរថ្មថា ក្សត្រាទ្រង់ឆោមពិសី
ល្អឯកចម្លែកប្រុសស្រី ក្នុងទ្វីបផែនដីលោកា ។
ស្តេចនេះពូកែស្ទប់ស្ទែង មានឫទ្ធីស្តែងអស្ចារ្យ
កាប់មួយព្រះខ័ន្ធពេជ្រថ្លា សិរទ្ធក្តីណាឬដែក ។
ដាច់ទៅជាបីកំណាត់ យសោមហាក្សត្រស្តេចឯក
បញ្ញាវៀងវៃចម្លែក អនេកលើសប្រាជ្ញទាំងពួង ។
កាលស្តេចបានស្វេតច្ឆ័ត្រ មានក្សត្រមួយអង្គហែងហួង
ប្រជែងដណ្តើមក្រសួង រាជប្រាង្គពីហ្លួងម៉ឺងម៉ាត់ ។
កើតហេតុតតាំងច្បាំងគ្នា យ៉ាងធំមហិមាពេកក្តាត់
យសោវរ្ម័នមហាក្សត្រ ស្តេចកើតវិបត្តិអស្ចារ្យ ។
ហៀបនឹងចាញ់គេទៅហើយ តែពុំយូរឡើយសេនា
ព្រះអង្គប្អូនទាក់ហានក្លា រងការជួសគាងព្រះអង្គ ។
ស្តេចប្រែមានជ័យរំពេច កម្ទេចសត្រូវជាផង់
ជាផេះធូលីសូន្យបង់ ដូចព្រះបំណងប្រាថ្នា ។
ក្រោយទៀតមហាក្សត្រសេង្ហ ស្តេចច្បាំងនឹងចាមច្រើនសា
ជាតិចាមច្រណែនឫស្យា ខឹងថាស្តេចខ្មែរមានទ្រព្យ ។
មានឫទ្ធិចេស្តាបារមី វាតដែនបូរីតភ្ជាប់
បានធំទូលាយសាយសព្វ ក្រែងគ្របដណ្តប់អាស៊ី ។
ស្តេចចាមប្រាមប្រាប់មន្ត្រី ឱ្យកេណ្ឌសេនីមូលមី
លើកទ័ពឆ្លងកាត់ជលធីរ គម្ពីសមុទ្រសាគរ ។

| | |
|---|---|
| ចូលលុកក្រុងកម្ពុជា | ច្រើនក្រៃមហិមាខ្លាខ្លរ |
| បង្កើតភ្លុកភ្លឺករីករវរ | ក្សត្រថ្លៃភូធរវរ្ម័ន ។ |
| ស្ដេចលើកទ័ពទៅទល់ទប់ | គ្រាន់គ្រប់កន្លែងខេត្តខ័ណ្ឌ |
| ទ័ពចាមត្បិតខ្ពិខ្ពាន់ | ផងក្រោយវន្លាន់រកចក្រ ។ |
| ទ័ពខាងស្ដេចខ្មែរដេញតាម | ទ័ពចាមភារុញកុញកក |
| ចាក់កាប់សម្លាប់ទៅមក | ទាយបកដោះយករួចខ្លួន ។ |
| ទ័ពខ្មែរវាយខ្លាំងឃាំងស្កាត់ | មុខជាប់កាប់ចាក់ថែមធួន |
| ចាមស្លាប់ឆាប់ស្លុតរត់ពួន | ច្រើនក្រៃចំនួនម៉ឺនសែន ។ |
| ទ័ពខ្មែរទ័ព្វជាប់ចាប់ខ្លាំង | ឃុំឃាំងប្រើតាងកំណែន |
| ទ័ពចាមគេចដោះចាកដែន | ទ័ពខ្មែរវៃក្លែនក្បួនសឹក ។ |
| ចាប់ឈ្លើយបានច្រើនអស្ចារ្យ | ប្រើការរែកពុនតត្រឹក |
| តគ្រាក់ញើសធ្លាក់តឹកៗ | ទ័ពចាមមិនថ្នឹកចាញ់ដៃ ។ |
| ច្រើនដងពន្លឹកញ៉ឹកញយ | គ្រាក្រោយព្រះបាទភូវណៃ |
| យសោវរ្ម័នក្សត្រថ្លៃ | ស្ដេចហៀបនឹងក្ស័យព្រះជន្ម ។ |
| ដោយសត្រូវចាប់ប្រហារ | កុំបានសេនាអត់ធន |
| ចូលរ៉ាប់រងឆាប់ពេកពន់ | ទ័ពចាមចាញ់មន្តវិជ្ជា ។ |
| បរាជ័យមួយរំពេច | រត់គេចចាកទីម្ទីម្នា |
| ទ័ពខ្មែរដេញចាប់កាប់វា | ធ្លាក់ក្នុងជលធាទឹកប្រៃ ។ |
| បានជាអាហារចំណី | ពួកត្រីអណ្ដើកក្រសៃ |
| ឆាមម្ដងក្រពើច្រើនក្រៃ | ខ្លះរស់ពុំក្ស័យជន្មា ។ |
| ចុះទូករត់ទៅឆាប់ៗ | ប្រញាប់វន្លាន់គ្រប់គ្នា |
| ទ័ពចាមចាលចាញ់ឫទ្ធា | ក្សត្រថ្លៃរាជាខេមរា ។ |

ដល់គ្រិស្តសាសនាចំនួន ប្រាំបួនរយរៀងតាមថ្នាក់
យសោវរ្ម័នទ្រង់លក្ខណ៍ ប្រសើរសមសក្តិសេដ្ឋា ។
កាលក្រោយស្តេចច្បាំងមានជ័យ ឈ្នះចាមហើយនៃក្សត្រា
ទ្រង់ព្រះតម្រិះចិន្តា ធ្វើបន្ទាយការពូកខ្លាំង ។
កំផែងខ្ពាត់ខ្ជែងមាំល្អ សុទ្ធថ្មធំៗផ្ទាំងក្រាស់ៗ
គ្របលើរាជវាំង ប្រក់ព្រំបិទបាំងស៊ីងថ្ម ។
ស្តេចសាងអង្គរនេះឯង គេមើលកោតក្រែងនាម្ករ
មនុស្សជាតិសម័យកម្រ ធ្វើបានមាំល្អចំពោះ ។
ក្នុងរាជយសោវរ្ម័ន ស្តេចរំលាងខ័ន្ធទៅនោះ
នគរខ្មែរយើងថ្កើងយស ល្បីល្បាញកេរ្តិ៍ឈ្មោះប្រាកដ ។
ចំណែកឧត្តរធានី ផែនទីសាវតាប្រវត្តិ
ទល់នគរមិនទៀងទាត់ កំណត់បច្ចឹមទិសា ។
ទល់នឹងទន្លេមួយត្រង់ សាលូអង្គពិតណា
ក្នុងស្រុកមនុស្សជាតិកូឡា ធំយ៉ាងអស្ចារ្យអនេក ។
ព្រះបាទយសោឧត្តម ស្តេចចេះរៀបចំពន់ពេក
គ្រួតគ្រានគរក្រោមមេឃ ភ្លឺផ្លេករុងរឿងរដ្ឋា ។
កែប្រែរបៀបរៀបរយ មិនឱ្យស្រោលធ្ងន់ពន្ធដា
ប្រែច្បាប់សម្រាប់អាជ្ញា ធ្វើទោសប្រហារជីវិត ។
មជ្ឈឹមឧក្រិដ្ឋធ្ងន់ៗ ពួកជាចោរកាចទុច្ចរិត
ចាក់កាប់សម្លាប់គេពិត ទ្រង់រិទ្ធគ្មានគ្រាប្រណី ។

# ពាក្យ៧

ទី៧ខ្ញុំសូមថ្លាថ្លែង សម្តែងប្រវត្តិកត់សេចក្តី
ពីស្តេចសោយរាជ្យក្នុងបូរី ក្រោយព្រះចក្រីយសោវ័រ្ម័ន ។
ព្រះអង្គស្តេចទីវង្គត់ទៅ កម្ពុជានៅថ្កើងសំខាន់
ស្តេចក្រោយសោយរាជ្យតែងប្រកាន់ កំណាន់កសាងប្រាង្គប្រាសាទ ។
ត១មកដើរតែក្នុងស្រុក មានកើតកលយុគក្តីប្រមាទ
ច្បាំងនឹងគ្នាឯងស្វែងហួសខ្នាត មិនស្អាតចាក់កាប់សម្លាប់គ្នា ។
បង្កសឹកសាមសង្គ្រាមជ័យ ទើបសាសន៍ដទៃហ៊ានពាធា
ជាតិចាមនិងយួនកូនផ្តន្ទា ពុះពារគ្រប់ច្រកចូលមកច្បាំង ។
កាលគ្រិស្តសាសនាប្រាំបួនរយ សាមសិបគ្រាក្រោយដោយសច្ចំ
ប្រហែលព្រោះសឹកសង្គ្រាមខ្លាំង តតាំងយូរយារនឹងគ្នាឯង ។
បានជាព្រះបាទជ័យវ័រ្ម័ន ទីបួនរន្ទាន់ចោលកន្លែង
ក្រុងអង្គរធំល្អស្ងប់ស្ងែង ស្តេចស្វែងទៅគង់ឯគោកខែ ។
គ្រិស្តស័កប្រាំបួនរយសែសិបប្រាំ គេចាំកត់ទុកមកហូរហែរ
រឿង១ទាត់ទៀងតាមក្រសែ ស្រាប់តែឃើញក្នុងប្រវត្តិថា ។
ព្រះបាទរាជិន្ទ្រាវ័រ្ម័ន ទីមួយខ្ជីខ្ជាន់យាងយាត្រា
ត្រឡប់ទៅគង់អង្គរ៉ា ក្សត្រារៀបចំឡើងជាថ្មី ។
ព្រះអង្គព្រះឱសព្រះអវតាន អោយជាងប៉ុន្មានក្នុងបូរី
ធ្វើប្រាង្គសាងជាគ្រិក្តីហាក្តី ក្នុងរាជចក្រីថែមចំនួន ។
ស្តេចនេះទ្រង់បានធ្វើចម្បាំង នឹងចាមយ៉ាងខ្លាំងត្រួតផ្ទួន១
ច្រើនដងបំណងវាយរុកគួន គាប់ជួនជាតិចាមចាញ់ថ្វីដៃ ។

ទ្រង់បង្គាប់ចាមអោយចំណុះ នាំសួយឡើងចុះមហាក្សត្រថ្លៃ
ស្តេចមហាអំណាចអង់អាចក្រៃ ជាមហែខេមរិនពិនធានី ។
ព្រះបាទរាជិន្ទ្រាវរ្ម័ននេះឯង ឫទ្ធីស្តែងគ្របលើទ្វីបអាស៊ី
កាលទ្រង់វង្គត់ផុតសញ្ជី ទៅនោះធានីស្រុកខេមរា ។
មានស្រុកចំណុះហុកសិបផ្កាយ រន្ទឺឮឆ្ងាយល្បីអស្ចារ្យ
សត្រូវកំណាចខ្លាចរអា ឫទ្ធីចេស្តាស្តេចស្រុកខ្មែរ ។
គ្រានោះព្រះពុទ្ធសាសនា មានគេគ្រូវការគោរពដែរ
ស្តេចគ្រប់ព្រះអង្គទ្រង់នៅតែ មិនប្រែចោលព្រហ្មញ្ញសាសនា ។
ក្នុងរាជិន្ទ្រាស្តេចវរ្ម័ន សំខាន់ឃើញក្នុងប្រវត្តិថា
មានកុង្សីម្នាក់ចាត់ចែងការ សាងព្រះបដិមាករច្រើនណាស់ ។
តម្កល់ទុកក្នុងអង្គរធំ បង្គំលំអុតបរិសុទ្ធសាសន៍
សេនាបតីនោះជឿច្បាស់ ចំពោះគុណព្រះប្រសើរសិទ្ធ ។
ដល់រាជព្រះបាទជ័យវរ្ម័ន ទីប្រាំសំខាន់បុរោហិត
ដែលធ្លាប់គោរពគពជាប់ចិត្ត ក្បែកកិតសាសនាព្រះសូគិា ។
កែប្រែត្រឡប់កាន់សាសនា នៃព្រះសម្មាសម្ពុទ្ធា
ព្រហ្មញ្ញសាសនាជាមួយគ្នា សោភាសរណស្មើជីវិត ។
ដល់ត្រិស្តសករាជមួយពាន់ពីរ ក្សត្រថ្លៃភូមីទ្រើសទ្រង់ឫទ្ធិ
សុរិយោវរ្ម័នទីមួយពិត ជាតិជាបណ្ឌិតក្នុងសាសនា ។
សោយរាជ្យសម្បត្តិក្នុងធានី បានតែប្រាំពីរវស្សា
ប៉ុន្តែទម្រាំបានរាជប្រា ក្សត្រាស្តេចទ្រង់ធ្វើចម្បាំង ។
រវាងបីឆ្នាំជាកំណត់ ប្រយោជន៍សង្កត់ស្តេចក្បត់ខ្លាំង
ចំណុះព្រះអង្គចង់ប្រណាំង ដែលបះបោខ្លាំងតាមជួរភ្នំ ។

ដងវែកមួយបែកទៀតទៅតាម ទន្លេមេណាមជាប់ជួរព្រំ
ជួរព្រៃដើមវែកំទ័ពធំ លើកមករំលំកម្ពុជា ។
ទ្រង់ចងចំណងស្ពានមេត្រី នឹងស្ដេចដែនដីជិតជាប់គ្នា
គឺចិននិងចាមតាមទ័យា ដើម្បីការពារជាតិយួនផង ។
ត្បិតយួនគុំកួននឹងលើកទ័ព ប្រសប់លុកចូលច្បាំងច្រើនដង
វាយចូលស្រុកខ្មែរតែបំណង វាប៉ងខុសខូចមិនដូចចិត្ត ។
ព្រះបាទសុរិសោវរ្ម័នទីមួយ ប្រកាន់ធម៌សុចរិត
ព្រះពុទ្ធសាសនាចិន្តាស្និត ផ្ដេកផ្ដិតជឿជាក់ព្រះរតនត្រ័យ ។
ក្រោយស្ដេចទ្រង់ទីវង្គត់ភ្លាម គេថ្វាយព្រះនាមមហាក្សត្រថ្លៃ
ខ្ពង់ខ្ពស់ពីរោះពន់ពេកក្រៃ ភូវណៃព្រះបាទនិព្វានបាទ ។
ស្ដេចព្រះអង្គនេះបានកសាង ភស្តុតាងសព្វថ្ងៃគឺប្រាសាទ
នៅភ្នំជីសូរវរោធាតុ ហើយនិងប្រាសាទភ្នំសណ្ដក់ ។
ទីប្រាំបីបែរប្រែអធិប្បាយ បរិយាយប្រវត្តិកំណត់ជាក់
តាមក្បួនសាវតាស្ដេចខេមរៈ កាលក្នុងគ្រិស្តសករាជសាសនា ។
មួយពាន់សែសិបប្រាំបួនឆ្នាំ គេចាំស្ដេចមួយមាននាមថា
ព្រះបាទឧទ័យាទិត្យា វរ្ម័នក្សត្រាសោយសម្បត្តិ ។
ក្នុងរាជស្ដេចនេះកើតចម្បាំង នឹងគ្នាឯងខ្លាំងពន់ពេកក្កាត់
យូរឆ្នាំរងកម្មមិនស្ងប់ស្ងាត់ មហាក្សត្រហៀបខ្សោយវិលាលៃ ។
ចាញ់ខ្មាំងទៅហើយមិនឡើយទេ ប៉ុន្តែមានមេសង្គ្រាមជ័យ
ម្នាក់ខ្លាំងពូកែបែរបកវៃ គឿនពលទីទៃចូលប្រចាក់ ។
ប្រកាប់សម្លាប់ពួកអាក្បត់ សង្កត់វាយខ្ចប់ជឿនគ្រប់ថ្នាក់
ស្ដេចមានជ័យវិញពេញរយៈ ពួកខ្មាំងបែកបាក់ទ័ពអន្តរាយ ។

កាលនៅក្នុងរាជស្តេចជាន់ក្រោយ　តមកបណ្តោយយូរវែងឆ្ងាយ
ស្តេចខ្មែរពូកែឈ្លីសុះសាយ　ដល់ស្រុកទាំងឡាយជិត១ខាង ។
គឺស្រុកចិនចាមអណ្ណាមក្តី　កោតខ្លាចបារមីព្រះចមប្រាង្គ
ឃើញព័ត៌មានមួយជាភស្តុតាង　តួយ៉ាងអម្បាលស្តេចក្រុងចិន ។
ក៏មកពឹងស្តេចកម្ពុជា　អោយលើកយោធាពូកែប៉ិន
នឹងនគរចាមជួយតាមកិន　ជួយទប់យួនសិនដោយមេត្រី ។
ព្រោះយួនលុកចិនសង្កិនជាប់　លើកទ័ពប្រមូលចូលបូរី
ខ្មែរចាមព្រមជួយមិនថាអ្វី　កែនសេនីទៅជួយច្បាំង ។
ស្តេចចិនកិនយួនជួនគ្រោះថ្នាក់　អប្បលក្ខណ៍ចាញ់យួន១កម្លាំង
ទប់ទល់ពុំបានខានតតាំង　វិលមករាជវាំងទេវនិមិត្ត ។
លុះគ្រិស្តសករាជតមកក្រោយ　មួយពាន់មួយរយដប់ពីរពិត
ស្តេចមួយព្រះអង្គទ្រើសទ្រង់រិទ្ធិ　ពិនិត្យឃើញនាមក្នុងប្រវត្តិ ។
ព្រះបាទសុរិយោវរ្ម័ន　ទីពីរសំខាន់ពិតប្រាកដ
ក្នុងរាជស្តេចនេះគេកំណត់　ទៀងទាត់ហេតុភេទកម្ពុជា ។
កើតច្បាំងតតាំងនឹងគ្នាឯង　ជាយូរអង្វែងក្រែមហិមា
មានភពមណ្ឌលក្នុងភារា　ស្លាប់ពលយោធាច្រើនអនេក ។
កាលណោះបើស្រុកសាន្តត្រាណហើយ　ក្សត្រាគ្រានត្រើយគ្មានអល់អែក
លើកទ័ពប្រសប់វាយបំបែក　ស្តេចចាមចាញ់តេជៈបារមី ។
ចាមលើកនគរថ្វាយស្តេចខ្មែរ　សូមតែសណ្តោសប្រោសប្រណី
ស្តេចខ្មែរអំណត់អត់ខន្តី　ទទួលបុរីកូឡូនី ។
រួចស្តេចខ្មែរមួយព្រះអង្គ　តាមក្តីបំណងព្រះភូមី
អោយសោយរាជ្យក្នុងកំឡុងទី　ស្រុកចាមតាំងពីគ្រិស្តសាសនា ។

មួយពាន់មួយរយសែសិបប្រាំ ចំណែចំណែកពង្សាវតារ
ក្នុងកម្ពុជៈរាជរដ្ឋា ថ្កុំថ្កើងអស្ចារ្យខេមរាវង្ស ។
អក្សរចារឹកនៅថ្មថា ក្សត្រាអង្គឫទ្ធីខ្ពស់ខ្ពង់
ចាមចាញ់ចេស្តាបារមីទ្រង់ នៅក្រោមម្លប់ទង់ជ័យខេមរៈ ។
ស្រុកខ្មែរស្គាល់តែពីស្រុកសាន្ត សម្បូណ៌ធនធានគ្រឿងស្លៀកពាក់
សម្បូណ៌ភោគទ្រព្យសព្វមាសប្រាក់ ជំនួញជួញដាក់សព្វសារពើ ។
ស្តេចនេះបានសាងនគរវត្ត ល្អមេប្រាកដគ្មានគ្រឿងឈើ
សុទ្ធសឹងតែថ្មល្អគ្មានស្មើរ ក្រោមលើលើសលប់ភពផែនដី ។
ឯស្តេចសោយរាជ្យក្រោយៗ តំណហែហូរក្នុងបុរី
គេពុំសូវដឹងដំណឹងអ្វី ច្បាស់លាស់សេចក្តីប៉ុន្មានទេ ។
អក្សរនៅថ្មចារឹកថា លង់មកសីមាពុំស្ថិតស្ថេរ
ចាមលុកលុយជុំពុំទំនេរ សងព្យេរវេរវៀគ្នាទៅមក ។
មិនយូរប៉ុន្មានខ្មែរបានវាយ នគរចាមធ្លាយធ្លុះគ្រប់ច្រក
កងទ័ពប្រសប់ចូលកុញ្ជរកក វាយបកឡោមជាប់សព្វកន្លែង ។
ចាមទ្រាំពុំបានខានប្រយុទ្ធ ទម្លាក់អាវុធពីដៃឯង
ទ័ពខ្មែរនៅតែបាញ់បែកផ្សេង ទ័ពចាមសំដែងអាការៈ ។
លើកដៃឡើងច្រូងហ្វូងយោធី ផ្ទឹមជើងទាំងពីរទ្រឹងនៅជាក់
ទ័ពខ្មែរឃើញខ្មាំងរាំងដៃជាក់ ដើរចូលស្ទុះស្ទាក់រាំងមុខទ័ព ។
ប្រមូលអាវុធគរដូចភ្នំ និយមស្តេចខ្មែរប្រែបង្គាប់
ឱ្យចាមចំណុះចុះចាញ់សព្វ រៀបរាប់រវាងសាមសិបឆ្នាំ ។
ម្យ៉ាងទៀតឆ្មៀតមានរបាក្សត្រ ស្រុកចិនថែងចាត់ជាបណ្តាំ
ទុកតមកផងគេចងចាំ ពិតដូចចំណាំពង្សាវតារ ។

គឺស្ដេចស្រុកចិនឱ្យនាំសួយ សារមករង្វាយថ្វាយក្សត្រា
ព្រះចៅស្រុកខ្មែរតែធម្មតា ដោយសារអំណរអរព្រះគុណ ។
នៃស្ដេចស្រុកខ្មែរបានជួយច្បាំង បង្ក្រាបពួកខ្មាំងពីជាន់មុន
គឺពួកបះបោរចោរចូលស៊ុន ចិនភ័យស្ទើរគ្រុនខ្លាចចាញ់គេ ។
កុំបានស្ដេចខ្មែរជួយដេញខ្មាំង កុំអីចោលវាំងនៅទំនេរ
ស្លាប់ទៅជាខ្មោចអសោចកេរ្តិ៍ នេះហៅបុញ្ញខ្មែរមានឫទ្ធិ ។
ប្រហែលក្នុងគ្រិស្តសករាជក្រោយ មួយពាន់មួយរយប្រាំបីពិត
ខ្មែរច្បាំងនឹងយួនគួនចូលជិត ប្រព្រឹត្តលុកឡោមនគរខ្មែរ ។
ស្ដេចខ្មែរពូកែក្លៀវក្លាហាន វាយច្រានទ័ពយួនផ្ទួនៗដែរ
យួនបរាជ័យភ័យរត់ហែ ខ្ញុំម៉ែខ្មែរគ្មានខ្លាចយួនសោះ ។
កាលនោះនគរកម្ពុជា ស្ដេចមានឫទ្ធាខ្លាំងទាំងអស់
អាស៊ីទ្វីបទិនមិនចន្លោះ កេរ្តិ៍កោះអង្គរជាភស្តុតាង ។
ព្រះជ័យវរ្ម័នទីប្រាំពិល ស្អាតចាកមន្ទិលល្អគ្រប់យ៉ាង
ព្រះអង្គជាមូលកំពូលប្រាង្គ សោយរាជ្យតំណាងគ្រិស្តសាសនា ។
មួយពាន់មួយរយហុកសិបបី ចក្រីនៅមានឫទ្ធិអស្ចារ្យ
ពុំទាន់រាប់អោនព្រះចេស្ដា នៅទ្វីបអាស៊ីយ៉ាដែនដីអាយ ។
ទីប្រាំបួនបែរប្រែកំណត់ គួចកត់ប្រវត្តិវែងឆ្ងាយ
នឹងថ្លែងសំដែងបទបរិយាយ ឡែបខាយទម្រង់ពង្សាវតារ ។
អំពីភេទស្រុកកម្ពុជា ក្នុងគ្រាវង្សស្ដេចវរ្ម័នា
ប្រហែលសព្វថ្ងៃជ្រប់ប្រការ ចរិយាមិនប្លែកគ្នាប៉ុន្មាន ។
គេឃើញមានវាលវែងធំៗ ហើយនិងព្រៃភ្នំព្រឹក្សាសាន្ត
ក្រាស់ៗជិតៗព្រំដែនដាន ប៉ុន្តែភូមិឋានគ្មានជិតគាំ ។

ដូចស្រុកសម័យសព្វថ្ងៃនេះ តាមមាត់ទន្លេគេឃើញចាំ
សុទ្ធតែឫស្សីព្រៃសាំញ៉ាំ ក្រាស់ជិតឆ្វេងស្តាំត្រើយសង្ខាង ។
នៅទីឯទៀតអ្នកដំណើរ គ្មានផ្លូវថ្នល់ដើរស្អាតដូចយ៉ាង
សម័យសព្វថ្ងៃឃើញភស្តុតាង រាជការស្ថិតស្ថាងគ្រប់កន្លែង ។
លើកតែខាងជើងទៅដរាប ក្បែរទន្លេសាបទីនោះឯង
ស្តេចអោយលើកថ្នល់ច្រើនខ្វាត់ខ្វែង និងស្ពានថ្មតែងឆ្លងកាត់ភ្លា ។
ទៅវិញទៅមកក្នុងទីក្រុង កម្លុងជាន់នោះស្ពានផ្លូវថ្លា
ពុំសូវមានសោះក្នុងភារា ម្យ៉ាងទៀតជនាសម្បុណ៌ខ្មៅ ។
ទាំងប្រុសទាំងស្រីទុកសក់បួង រាស្ត្រហ្លួងកម្លុងទាំងក្នុងក្រៅ
សំពត់ស្លៀកសោតមានសខ្មៅ តែពុំឆ្អិនឆ្អៅស្អាតដូចគេ ។
មានតែក្រមាព័ទ្ធចង្កេះ សម្បុរប្រផេះដូចសត្វភេ
ដងខ្លួនខ្លីវែងលែងទទេ គ្មានសល់ទំនេររាស្ត្រដល់ម្នាក់ ។
មានតែមហាក្សត្រស្តេចផែនដី ហើយនិងមន្ត្រីត្តមសក្តិ
អនុមន្ត្រីឬវរៈ មានគ្រឿងស្លៀកពាក់សង់ក្លាត់ព្រៃ ។
អាវជាយចរបាប់សម្រាប់យស ខ្ពង់ស្កប់តាមថ្នាក់ក្រសៃ
អាវណាយសែសយសម្រាប់ខ្មែរ សុទ្ធតែទិញមកពីស្រុកក្រៅ ។
ស្រីខ្មែរតែពុំទាន់ស្អាត់ ដឹងយល់ប្រាកដអម្បោះឆៅ
ថ្ពេចហួតសំឡីស្រីមិនខ្លៅ ល្វង់មិនប៉ិនប៉ៅធ្វើសូត្រផង ។
ត្បាញកើតមិនឆើតសាច់សំពត់ មិនជិតគត់មត់សោះឡើយហោង
ខ្លីខ្វាពេកពន់អន់កន្លង សៅហ្មងពេកក្រែងមិនថ្លៃថ្លា ។
អំពីនៅខ្មែរបូរាណ គេបានសង្កេតនឹងនេត្រា
ខ្មែរនៅផ្ទះរោងដោយធម្មតា ប្រក់ស្លឹកចាកចារនិងស្បូវភ្លាំង ។

ផុះរាស្ត្រគ្មានតុទូកៅអី ជើងម៉ាវែងខ្លីសម្រាប់តាំង
កន្លែងនិទ្រាជានិច្ចធំ វាំងននទនាំងមុងក៏គ្មាន ។
ប៉ុន្តែកន្ទេលកក់ឫផ្តៅ ហួងសៅទាំងសព្វទ្រព្យធនធាន
រាស្ត្រក្រប្រាកដអត់ស្រែកឃ្លាន ស្តេចពុំប្រទានភោគសម្បត្តិ ។
រាស្ត្ររកបានទ្រព្យត្រូវដាក់ឃ្លាំង បើស្រូវរាប់ថាំងតាំងបញ្ញត្តិ
សេនាបតីមន្ត្រីក្បត្រ បានទ្រព្យសម្បត្តិផ្ទាល់ពីរាស្ត្រ ។
របស់អម្រស់ជនជាតិខ្មែរ រកស៊ីធ្វើស្រែស្រូវពេញពាស
បរបាញ់សត្វសោតដោយជន្ទាស បង់សំណាញ់វាសវិធយកត្រី ។
ជុំវិញកំផែងព្រះរាជវាំង មានជាងសម្រាំងសម័យថ្មី
រយពាន់គ្រប់គ្រាន់ក្នុងបុរី សឹងមានឈ្មោះល្បីរៀងរាល់ប្រាណ ។
ប្រសប់ក្រឡឹងគូរឆ្លាក់ថ្ម ជារូបល្អៗច្រើនសណ្ឋាន
កសាងប្រាសាទស្អាតប៉ុន្មាន ដូចបានរៀបរាប់មកហើយស្រាប់ ។
ឯគ្រឿងយុទ្ធភ័ណ្ឌសស្ត្រាវុធ សម្រាប់តយុទ្ធបាញ់ចាក់កាប់
ធ្នូស្នាបង្ការគ្រប់ប្រដាប់ ត្រូវមានស្រាចស្រាប់ទុកបម្រុង ។
នោះគឺលំពែងស្នែងក្របី ដាវវែងដាវខ្លីស្រួចៗចុង
មុគថ្នាបង្ការខ្នាំងទាំងស្រុង មានខែលព័ទ្ធកុងការពារខ្លួន ។
ខ្មែរកាំភ្លើងមិនចេះសិត ប្រើដែកកាំបិតស្នូរផ្លែបួន
ផ្លែបីឫស្សីស្រួចថែមធួន ច្រើនណាស់ចំនួនរាប់ពុំបាន ។
កាលក្នុងគ្រានោះជនជាតិខ្មែរ សឹងតែស្មោគគ្រោកពន់ប្រមាណ
កើតព្យាធិឃ្លង់ស្រែងគ្រប់ឋាន ស្ទើរពុំសល់ខានកន្លែងណា ។
រោគឃ្លង់ជារោគអាក្រក់ណាស់ មានឆ្លងដល់ម្ចាស់ជាតិខេមរា
ស្តេចមួយព្រះអង្គក្នុងសីមា ចាស់ៗហៅថាស្តេចកម្លង់ ។

ស្តេចគេសាងព្រះរូបទុក ដាក់ចំពីមុខវត្តក្នុងក្រុង
ហៅឧណ្ណាលោមមាត់កំពង់ ទន្លេមេគង្គ ឬមុខបួន
នៅក្រុងភ្នំពេញយើងសព្វថ្ងៃ ក្សត្រស្តេចទ្រង់ព្រះឈួន
ដោយហេតុរោគនេះវារុកគួន ជាតិខ្មែរចិនយួនស្គាល់គ្រប់គ្នា ។
បានជាជាន់នោះមានអក្សរ ចារឹកនៅថ្មករតាមគ្រា
សាវតាប្រវត្តិកម្ពុជា យូរយាររវាំងគ្រិះសាសនា ។
មួយពាន់មួយរយប៉ែតប្រាំមួយ ស្តេចខ្មែរទ្រង់ព្រួយព្រះចិន្តា
អោយសាងមន្ទីរថែរក្សា រោគឃ្លង់នេះណាគ្រប់កន្លែង ។
គ្រិះស្ថានប្រមាណមួយរយពីរ ក្សត្រថ្លៃភូមិស្តេចចាត់ចែង
រើសពេទ្យផ្សំថ្នាំរោគឃ្លង់ស្រែង ស្រុកអំណែងជាដើមហេតុ ។
ទីដប់គ្រឡប់ប្រែចរចា អំពីសាសនាលិចអណ្តែត
ចាស់ទុំគួរជឿនរកប្រែត ឃើញច្បាស់ក្រឡែតក្នុងប្រវត្តិ ។
សាសសែខ្មែរយើងពីបូរាណ រាប់អានអ្នកតាប្រែតព្រាយព្រាត់
អារក្សទេវព្រាក់ខ្មោចកំសត់ ជឿជាត់ប្រាកដប្រកាន់ថា ។
ក្នុងទឹកលើដីព្រៃក្រោមលើ មានអ្នកតាធ្វើឱ្យឈឺផ្សា
អមនុស្សបិសាចកាចអស្ចារ្យ កោតខ្លាចរអាគ្រប់ៗគ្នា ។
មនុស្សយើងមើលវាពុំឃើញទេ បឹងស្ទឹងទន្លេស្រះគង្គា
ជាទីលំនៅរបស់វា ដើរទៅពានពារវាប្រកាន់ ។
ធ្វើឱ្យឈឺចាប់ស្លាប់អន្តរាយ ជាតិខ្មែរស្រុកអាយជឿជាក់ស្បាន់
អ្នកតាអាក្រក់ច្រើនណែនណាន់ នៅក្នុងខេត្តខ័ណ្ឌព័ទ្ធសីមា ។
អ្នកតាល្អនោះមានតិចណាស់ ក្មេងចាស់ប្រកាន់ជឿតម្រា
ត្រ័យភូមិត្រ័យភេទសង្កេតថា ព្រហ្មញ្ញសាសនាវិសេសណាស់ ។

ព្រហ្មញ្ញមានព្រះធំបំផុត　　បីព្រះអង្គគត់ប្រវត្តិសាស្ត្រ
អធិប្បាយរាប់រៀបរបៀបព្រះ　　អោយយើងដឹងច្បាស់ដូច្នេះថា ។
ខ ១ គេហៅថាព្រះព្រហ្ម　　ជាធំបំផុតព្រះនានា
បង្កើតមណ្ឌលភពលោកា　　មានព្រះរូបាទុកតំណាង ។
មុខបួនដៃបួនខ្លួនក៏ធំ　　និយមរូបភាពគេកសាង ,
អនុស្សាវរីយ៍ជាទីតាំង　　បែបផែនដោយយ៉ាងអំពីថ្មា ។
ខ ២ ហៅថាព្រះឥសូរ　　មានឫទ្ធិតេជោជួយប្ដេជ្ញា
បំផ្លិចបំផ្លាញលោកនានា　　គេសាងទុកជាសក្ការៈ ។
ព្រះរូបព្រះអង្គមានបារមី　　មានព្រះនេត្របីថ្មចម្លាក់
និងរូបព្រះច័ន្ទចរជៀងជាក់　　លើព្រះកេស្វរៈជាសញ្ញា ។
ខ ៣ ហៅថាព្រះនារាយណ៍　　ផ្ទុះផ្លាយព្រះញាណមានមេត្តា
ទ្រទ្រង់សព្វសត្វក្នុងលោកា　　វត្ថុធម្មតាអោយឋិតថេរ ។
គេសាងព្រះរូបល្អសមសួន　　មានព្រះហស្តបួនវំពូកកើ្ត
កាន់ស័ង្ខដិបងបូទុមេ　　ប្លែកៗព្រះគេបីព្រះអង្គ ។
ព្រហ្មញ្ញសាសនាផ្សាយយូរយារ　　ពីស្រុកឥណ្ឌាចូលមកត្រង់
ដែនកម្ពុជាមិនបាត់បង់　　តម្រូវចំណង់ចិត្តខេមរា ។
តាំងពីសករាជបួនរយឆ្នាំ　　គេចាំប្រវត្តិពង្សាវតារ
ទាំងស្ដេចមន្ត្រីរាស្ត្រត្រូវការ　　ព្រហ្មញ្ញសាសនាកាន់ក្ជូចគិត ។
រហូតដល់គ្រិះសករាជក្រោយ　　មួយពាន់បីរយសែសិបពិត
ប្រាសាទស្ពាងស្អាតទាំងឆ្ងាយជិត　　ប្រព្រឹត្តធ្វើថ្វាយព្រះទាំងបី ។
ឯបណ្ដាជនក្នុងរដ្ឋា　　រាជការចែកក្រុមតាមវេណី
ទី១ បុរោហិតព្រាហ្មណ៍ព្រឹទ្ធក្ដី　　និងប្រាជ្ញកវីបូរាណា ។

| | |
|---|---|
| ទី ២ ក្រុមនាយកសេនី | មេសង្គ្រាមជ័យពលអស្សា |
| ធ្វើរជើងហត្ថិ ឬព្វា | ទី៣ ហៅថាក្រុមកុំពី ។ |
| ក្សត្រាធិការពាណិជ្ជករ | ឬថាពួកក្រុមជលធរណី |
| ធ្វើស្រែចំការរាស្ត្ររកស៊ី | ដំណាំភាគីដីងជួញព្រៃ ។ |
| ទី ៤ ក្រុមជាងគ្រប់ចំណែក | ជាងដែកជាងស្មិតសិតពុម្ពផែ |
| ជាងមាសជាងប្រាក់ឆ្លាក់ក្បាច់ស្វៃ | ក្រឡឹងជើងគ្រែតុទូតាំង ។ |
| ជាងឈើធ្វើផ្ទះព្រះវិហារ | ប្រាសាទនានានិងរាជវាំង |
| ជាងឆ្លាក់អក្សរលើថ្មផ្ទាំង | ល្អៗសម្រាំងសម្រាប់ស្រុក ។ |
| គេមើលឆ្ងាយណាស់អស់ពួកជាង | គេថាត្រូវសាងឱ្យជ្រះផុក |
| ពីខ្លួនឯងសិនទើបនៅសុខ | ចូលអង្គុយតុទីប្រជុំ ។ |
| នឹងក្រុមដទៃបានឥតទាស់ | ទាំងអស់គ្នារាប់លែងស្កប់គុំ |
| ទំនៀមនេះប្លែកក្រៃពេកពុំ | សមគួរនិយមយកតម្រាប់ ។ |
| ព្រះពុទ្ធសាសនាៗផ្ដើម | ជាសាសនាដើមល្អចំណាប់ |
| នៅស្រុកឥណ្ឌាជាគោលច្បាប់ | វិន័យសណ្ដាប់ក្នុងសាសនា ។ |
| ទុកឱ្យមនុស្សសត្វបដិបត្តិតាម | ពុទ្ធបញ្ញត្តិហាមមួយទៀតថា |
| ពុទ្ធានុញ្ញាតស្អាតអស្ចារ្យ | ទេសនាពន្យល់ពីបាបបុណ្យ ។ |
| មានពីប្រាំរយហុកសិបឆ្នាំ | គេចាំដឹងព្វជានិរន្ត៍ |
| មុនគ្រិស្ដសាសនាបណ្ដាជន | អត់ធនមិនធ្វើកម្មទុច្ចរិត ។ |
| សាងសីលធ្វើទាននិងភាវនា | ការពាររវាំងតាំងក្នុងចិត្ត |
| រក្សាពូជមនុស្សឱ្យថេរឋិត | ថាវរៈជាប់ស្អិតក្នុងសន្តាន ។ |
| កាលដើមអ្នកស្រុកកម្ពុជា | រាល់គ្នាប្រកាន់ពន់ប្រមាណ |
| ព្រហ្មញ្ញសាសនាសព្វភូមិឋាន | រាប់អានស្មោះសខំប្រព្រឹត្ត ។ |

ដល់គ្រិស្តសាសនាគមកក្រោយ មួយពាន់បីរយសែសិបពិត
ជនជាតិខេមរៈអ្នកឆ្លាយជិត គ្រឡប់គំនិតកាន់សាសនា ។
សមណៈគោត្តមវិញទាំងអស់ ក្នុងចន្លោះជាតិខេមរា
ក្នុងព្រះបូរីរាជសីមា រាស្ត្រនិងសាវ័ការមាត្យមន្ត្រី ។
សាសនាឧត្តមសុខុមល្អិត ប្រើសំស្ក្រឹត និងបាលី
ភាសាខ្ពង់ខ្ពស់ក្នុងលោកីយ ប្រុសស្រីចូលចិត្តកាន់គ្រប់ប្រាណ។
មនុស្សជាតិទាំងអស់ទោះក្រមាន មិនហ៊ានលើកខ្លួនហួសប្រមាណ
មិនប្រមាថជាតិញាតិសន្តាន ធ្វើតាមលំអានពុទ្ធសាសនា ។
ភាសាបាលីប្រពៃណាស់ ចារិកចម្រិព្រះពីលង្ការ
ព្រះសង្ឃរៀនដឹងប្រឹងសិក្សា ទៅចារចម្លងមកតម្កល់ ។
ទុកក្នុងនគរកម្ពុជា ក្នុងគ្រិស្តសករាជរៀបរៀងដល់
មួយពាន់មួយរយដោយយោបល់ ជាតិខ្មែរកុំឆ្ងល់គួរជឿបាន ។
ទី ១១ កត់តាមបទបាទ អំពីប្រាសាទជាន់បូរាណ
ស្តេចខ្មែរសាងទុកទាំងប៉ុន្មាន នៅក្នុងដែនដានកម្ពុជរដ្ឋ ។
កសាងរវាងបួនរយឆ្នាំ គេចាំដឹងឃើញក្នុងប្រវត្តិ
សាវតាសង្ខេបតាមបែបបទ ចាប់សាងកំណត់គ្រិស្តសាសនា។
ប្រាំបីរយហាសិបឆ្នាំគ្រីស្ត ន័យនេះសម្តែងដោយសញ្ញា
១ គឺព្រះប្រាង្គយ៉ាងអស្ចារ្យ ហៅថាប្រាសាទនគរវត្ត ។
ហើយនិងប្រាសាទឈ្មោះព្រះខ័ន កំណាន់ថ្វាយព្រះជាកំណត់
២ គឺប្រាសាទស្អាតប្រាកដ សម្រាប់ចក្រព័ត្រស្តេចផែនដី។
ស្តេចគង់ទម្រង់ព្រះរាជវាំង ទីតាំងឧត្តមសមសិរី
នូវអង្គរធំរឿងរង្សី ៣ គឺបន្ទាយការសត្រូវ ។

កំផែងខ្ទាត់ខ្ទែងអង្គរធំ និយមប្រវត្តិពីម៉ែឪ
៤ គឺចំនួនថ្នល់ស្ពានផ្លូវ តម្រូវកាន់ភ្ជាគ្រប់ទីក្រុង ។
៥ គឺមន្ទីររោគព្យាបាល សង់ចំកណ្តាលមិនដើមចុង
ឱសថគ្រប់មុខទុកបម្រុង រក្សារោគឃ្លង់ស្រែងជាដើម ។
ប្រាសាទប្រសើររៀងដរាប ក្បែរទន្លេសាបល្អយ៉ាងឆ្នើម
នៅប្របជើងភ្នំធំសម្បើម ផ្ទៃថ្នើមឈ្មោះហៅថាដងរែក ។
កសាងប្រាសាទបានដោយស្រួល ត្រូវមានកូនឈ្នួលជាងឯកៗ
ហើយនិងពួកឈ្លើយច្រើនអនេក ប្លែកៗចាប់បានក្នុងចម្បាំង ។
ប្រាសាទស្ពាងស្អាតល្បីនាមឈ្មោះ ខ្ពង់ខ្ពស់បំផុតជាតិស្រុកអាំង
ស្តេចខ្មែរបានសាងយ៉ាងសម្រាំង ទុកជាទីតាំងកម្លាំងឫទ្ធិ ។
មួយហៅប្រាសាទបន្ទាយឆ្មា នៅជើងបុព្វាដងរែកជិត
ព្រះជ័យវរ្ម័នទី២ពិត សាងដោយពិនិត្យល្អអស្ចារ្យ ។
ពីប្រាង្គបាគោ និងបាគង លំលែសមទ្រង់ឥតឧបមា
ខាងកើតសៀមរាបភាពចេត្យា ព្រះបាទឥន្ទ្រាវរ្ម័នសាង ។
៣ ប្រាង្គបាយ័នល្អលើសលប់ ក្នុងទីបពិភពក៏ដោយយ៉ាង
និងអង្គរធំជាភស្តុតាង សំអាងវវាងត្រិស្តសាសនា ។
ប្រាំបីរយប៉ែតសិបទៅក្រោយ ដល់ប្រាំបួនរយដោយសញ្ញា
មួយទៀតប្រាសាទស្អាតរចនា ឈ្មោះថាអង្គរធំជៀងជាក់ ។
ព្រះបាទយសោវរ្ម័ន សំខាន់សាងទុកក្នុងត្រើះស័ក
ប្រាំបួនរយរាប់រៀងតាមថ្នាក់ ខេមរៈប្រាសាទស្អាតជាងគេ ។
ប្រាំពីគីឡូម៉ែត្រទទឹង បណ្តោយបើនឹងគិតកាញ់គ្នេ
ដប់បីគីឡូមិនតូចទេ ជាមេប្រាសាទផងទាំងឡាយ ។

៤ គឺប្រាសាទនគរវត្ត រុងរឿងប្រាកដល្អឆើតឆាយ
ប្រាសាទនេះជាប់ដែនដីអាយ ម៉ិតប្រាយរចនាមិនទាន់ស្រេច ។
សុរិយាវរ្ម័នស្តេចទី ២ ក្សត្រថ្លៃភូមីព្រះអង្គស្តេច
សាងទុកតំណាងយ៉ាងល្អផ្តាច់ សម្រេចក្នុងគ្រាត្រិស្តសាសនា ។
មួយពាន់មួយរយម្ភៃឆ្នាំ គេចាំប្រាកដពង្សាវតារ
៥ គឺប្រាសាទបឹងមាលា វាល់គ្នាពុំដឹងស្តេចណាសាង ។
ពីកាលណាមកក៏មិនដឹង គេប្រឹងសង្កេតរកភស្តុតាង
ពុំឃើញមានទុកជាតួយ៉ាង ក្នុងប្រាង្គប្រាសាទមានចម្លាក់ ។
រឿងរ៉ាវនិយាយពីជាតិខ្មែរ ពីកាលណោះដែរកែបញ្ជាក់
បញ្ចោរទឹកចិត្តជនខេមរៈ លក្ខណៈ ប្រព្រឹត្ត និង ចរិយា ។
ទី ១២ តែងទុកទំនៀម ពីសៀមលុកលុយស្រុកខេមរា
យកអង្គធំថ្លៃអស្ចារ្យ រឿងរ៉ាវសាវតារគេចង់ចាំ ។
ពីឆ្នាំមួយពាន់ពីររយហា លុះគ្រាដល់មួយពាន់បីរយឆ្នាំ
ក្បែរអង្គរធំព្រៃឆ្វេងស្តាំ ចំណាំចំណែកប្លែកធម្មតា ។
ស្តេចសៀមលើកទ័ពចូលលុកលុយ ប៉ុន្មែយទទ្រើបដើរស៊ើបការណ៍
ក្បែរអង្គរធំព្រៃរដ្ឋា កន្លែងណា។ទ័ពចូលដែរ ។
ពីដើមប្តីទឹកដីសៀម ជាប់ជាទំនៀមរបស់ខ្មែរ
ប្រាំរយឆ្នាំគត់រលត់សែ ស្ទើរតែបាត់ឈ្មោះថៃសៀមសោះ ។
កាលណាដឹងខ្លួនថាមានឫទ្ធិ ក៏គិតក្បត់ខ្លាំងខ្មែរទាំងស្រប់
តតាំងច្បាំងយកស្រុកកេរ្តិ៍កោះ ភូមិភាគទាំងអស់របស់ខ្មែរ ។
ជាតិសៀមបៀមជាប់ធម៌គុំកួន វាល់ខ្លួនអ្នកក្រុងឬអ្នកស្រែ
ប្រព្រឹត្តក្បត់ខ្មែរច្បាំងច្រើនខែ ច្រើនខួបណាស់ដែរដោយចិត្តក្រោធ ។

សៀមខ្មែរច្បាំងគ្នាប្រាំរយឆ្នាំ គេចាំជឿជាក់ហេតុចាក់ដោត
ប្រកាន់កំហឹងខឹងចាក់ដោត ចាញ់កលបញ្ឆោតខ្មែរច្រើនដង ។
លើកមកពេលណាបរាជ័យ ស្លាប់ពលទីទៃច្រើនកន្លង
បាក់ទ័ពត្រឡប់រត់គិកកង ខូចចិត្តបំណងមិនសម្រេច ។
ពីព្រោះជាន់នោះកងទ័ពខ្មែរ នៅខ្លាំងពូកែស្រស់ស្រូចស្រេច
ក្លៀវក្លាអស្ចារ្យចិត្តប្តូរផ្តាច់ ឈាមសាច់រូបកាយថ្វាយទឹកដី ។
កោតខ្លាចអំណាចចៅហ្វាយនាយ មិនធ្វើពាយងាយគ្រប់សេនី
សេនាយោធាម៉ាតមន្ត្រី គោរពច្បាប់ថ្មីអាណាចក្រ ។
ពុំហ៊ានទទឹងរឹងទទូច ជាប់ពូជដៅពង្សវង្សខេមរា
សុទ្ធ១មិនផុតកិច្ចការវ: ស្លាប់ថ្នាក់ខ្ពស់ទាបសភាពត្រង់ ។
ប៉ុន្តែវេលាគ្រាក្រោយ១ នាំឱ្យរលប់រលាយបង់
បាត់ក្តីសុចរិតចិត្តផ្ចូរផង់ ចំណង់ទោសៈគ្របសង្កត់ ។
គ្មានគារវៈធម៌ និងសាមគ្គី ខ្លួនមួយចិត្តពីរគ្មានអំណត់
អំពើរទៅមកទុកទ្បេងទាត់ ប្រកាន់ប្រាកដធមិតស្បា ។
ដណ្តើមអំណាចពីគ្នាឯង ទាស់ទែងទាមទារយសសក្តា
ខ្លះទៅពឹងសៀមមកជួយការ សៀមបានដោយសារខ្មែរពឹងរក ។
លើកទ័ពប្រសប់ចូលសំងុត់ សង្កិនបាត់មាត់រត់ជ្រៀតជ្រក
សៀមថែចង្រៃចូលសង្សក ច្បាំងយកអង្គរធំពីរដង ។
ក្នុងរាជព្រះស្រីសុរិយោទៃ សៀមចូលជាញជ័យយូរកន្លង
ជាងមួយឆ្នាំឆ្លាយច្បាំងគឹកកង សៀមយកបានម្តងគ្រិស្តសាសនា ។
មួយពាន់បីរយហាសិបបី ចក្រិតយុទ្ធយ៉ាងអស្ចារ្យ
ទ័ពសៀមដណ្តើមយកប្រាង្គប្រា រាជ្ជាអង្គរធំបានម្តង ។

ដល់រាជព្រះបាទម្ចាស់សិរសា　ធម្មសោកាក្យគ្រច្បាស់ច្បង
សៀមចូលប្រកួតអួតប្រឡង　ច្បាំងគ្នាគឹកកងប្រាំពីរខែ ។
សៀមយកអង្គរបានម្តងទៀត　មហាក្សត្រយើងឆ្លៀតប្រឹងណាស់ដែរ
សៀមថៃចង្រៃខ្លាំងពូកែ　ធ្វើគតស្តេចខ្មែរក្ស័យជន្មា ។
មួយពាន់បីរយកៅសិបបួន　គ្រិស្តសាសនាជួនគេពណ៌នា
រឿងរបាក្សត្រកម្ពុជា　វេលាចារឹកប្រទេសជាតិ ។
កើតសឹកចម្បាំងទាំងប៉ុន្មាន　ស្តេចខ្មែរក៏បានខំខ្មីឃ្មាត
ការពារសម្បាច់ដែរទាយាទ　ពុំមានឃ្លៀងឃ្លាតក្រិតក្រស័ត្រ ។
គេស្មានថាកាលក្រោយជាតិថៃ　សៀមសាសន៍ចង្រៃអាក្រក់ក្តាត់
យកអង្គរបានក្រុងក៏ស្ងាត់　ខ្មែរកើតវិបត្តិពីរបីឆ្នាំ ។
ព្រោះក្រុងនៅក្នុងអំណាចសៀម　ខុសខួចទំនៀមខ្មែររងកម្ម
រងទុក្ខតៗនៅប្រចាំ　ប្រជែងឆ្វេងស្តាំច្រើនប្រការ ។
ទី ១៣ បែរប្រែអធិប្បាយ　បរិយាយសំណៅពង្សាវតារ
ប្រវត្តិសាស្ត្រជាតិតាមមាត្រា　តម្រូវតម្រាខេមរាបូត្ត ។
ព្រោះតែច្បាំងគ្នាគ្រាក្រោយៗ　នាំអោយខេមរភ្ញាក់តក់ស្លុត
ទាំងស្តេចមន្ត្រីភ័យស្រយុត　គេចវាងមិនផុតក្តីអន្តរាយ ។
ព្រះចៅរដ្ឋាខេមរាវង្ស　ស្តេចលើកទីក្រុងជៀសចេញឆ្ងាយ
ចោលទីអង្គរល្អឆើតឆាយ　មិនស្តាយទៅតាំងទិសទក្ខិណា ។
គឺទិសខាងត្បូងរិញម្តីម្ចា　ដើម្បីការពារសៀមឫស្យា
កុំអោយចូលលុកលុយសីមា　បានដូចចិន្តាវាងាយៗ ។
គំណតមកក្សត្រប្រសើរ　ស្តេចពុំហ៊ានធ្វើវាំងបន្ទាយ
ពីឥដ្ឋពីថ្មល្អពណ្ណរាយ　ដូចស្តេចមុននាយវង្សវរ្ម័ន ។

ស្តេចគង់នៅប្រាង្គប្រាសាទ ពុំសូវស្អាតបាតបិទបាំងខណ្ឌ
ក្រោមលើគ្រឿងឈើធ្វើវាំងច័ន្ទ ឆាយាកំណាន់ទីកំនាល់ ។
ចុងព្រះរាជរោងនៅពីមុខ រៀបទុកកន្លែងដំណែងផ្ទាល់
មន្ត្រីថ្នាក់ខ្ពស់ចុះឡើងគាល់ រៀងរាល់វេលាជាប្រក្រតី ។
នគរក៏ចុះអាប់អោនក្រៃ បានជាសព្វថ្ងៃគ្មានសល់អ្វី
ប្រាសាទចិញ្ចែងគំផែងក្តី ឈើព្រៃឫស្សីដុះរូបជិត ។
កុំបានរាជការខំខ្នះខ្នែង ចាត់ចែងជួសជុលដោយពិនិត្យ
កាប់ឆ្កាបន្លាដុះរូបជិត រៀងៗមកពិតដល់សាសនា ។
មួយពាន់បួនរយម្ភៃមួយ ស្តេចខ្មែរទ្រង់ព្រួយយ៉ាងអស្ចារ្យ
ព្រះបាទពញាយ៉ាតមហាក្សត្រា ស្តេចសោយរាជ្យប្រាណក្នុងបុរី ។
ក្រុងកម្ពុជាភារារដ្ឋ ឈ្វេងយល់កំណត់កំណើតថ្មី
ថាអង្គរធំព្រំដែនដី ជិតសៀមអប្រិយទ្រាំពុំបាន ។
ស្តេចនាំព្រះវង្សានុវង្ស ចតុរង្គក្នុងវាំងទាំងប៉ុន្មាន
មេនំអកយាយយាងចេញថ្កាន ទៅតាំងនាស្ថានមាត់កំពង់ ។
ទន្លេមុខបួនក្រុងភ្នំពេញ ជាខាងត្បូងវិញសក្តិសមទ្រង់
កសាងប្រាង្គមុនីទីប័ញ្ញយង់ ស្តេចគង់ជាសុខឥតភ័យា ។
ទីក្រុងថ្មីនេះព្រោះនៅជិត មាត់កំពង់ពិតដៃគង្គារ
ទន្លេមេគង្គវង់ជលធា ឡើងជាកំពង់ជំនួញធំ ។
ជាតិខ្មែរចិនយួននិងចាមជ្វា កូឡាភូមាក្លឹង្គនិយម
និយាយអោនកាយថ្វាយបង្គំ ទូលសុំរកស៊ីព្រមប្រុសស្រី ។
ព្រះបាទពញាយ៉ាតម្ចាស់ក្រុងក្រៃ ក្សត្រថ្លៃចាត់ទូតព្រះចក្រី
អោយនាំរាជសារជាដីរី វត្ថុអ្វីៗគ្រប់ប្រការ ។

ទៅថ្វាយស្តេចចិនមិនដែលខាន ក្សត្រក្សាន្តសោយរាជ្យក្នុងរដ្ឋា
ក្នុងក្បួនព្រះវង្សពង្សាវតារ មិនថាកំណត់ប៉ុន្មានឆ្នាំ ។
ព្រះបាទពញាយ៉ាតសុគតទៅ គេនោះគេនៅដឹងឃើញចាំ
ថាក្នុងរវាងពីរបីឆ្នាំ ក្រុងកម្ពុជាផែនដីអាយ ។
មានស្តេចសោយរាជ្យបីព្រះអង្គ ចំណាង់សោយរាជ្យប្រទូស្តរ៉ាយ
ពុំសុខនឹងគ្នាជាវែងឆ្ងាយ វិះរកឧបាយជ្រេវរាជគ្នា ។
ព្រះបាទធម្មោរាជោជៀម យាងទៅពឹងសៀមអយុទ្យា
ស្តេចសៀមអង់អាចមិនខ្លាចរា លើកពលយោធាជួយប្រញាប់ ។
មួយប៉ែកចែកទ័ពតាមជើងគោក ច្រើនក្រៃរងោកមិខ្វាន់ខ្វាប់
មួយប៉ែកជើងទឹកសន្ធឹកអាប់ ស្មើរនឹងក្រឡាប់ផែនប្រថពី ។
ជើងទឹកចូលតាមខេត្តកំពត កំពង់សោមសោតអរញ្ញី
ពាក់ថ្លុករាជតបៈឫទ្ធី ខ្លះលីលំពែងស្នែងក្របី ។
សៀតក្រេះកាន់ដាវសោវសំសៃ មានផ្លែសស្វាចគ្មានខ្លាចអ្វី
ចូលអោយខ្មែរកាប់សម្លាប់ខ្មី ធ្នូស្នាបាញ់ក្តីក៏មិនមុត ។
បាញ់ក៏មិនត្រូវក៏មានដែរ ចូលមកស្រុកខ្មែរប៉ងប្រយុទ្ធ
វាយចុះតាមចិត្តតតទ្រោមទ្រុឌ ខាំមាត់ដូចគ្រុឌរាជបក្សី ។
រីឯស្តេចខ្មែរពីរព្រះអង្គ ភិតភ័យឡើនឡង់បាត់ស្មារតី
ឃើញទ័ពសៀមមកចូលមកខ្មី ដល់ភពផែនដីកម្ពុជា ។
ស្តេចខ្មែរពីរពង្សទ្រង់រិះគិត ពិនិត្យយល់ជាក់ក្នុងទ័យា
ថាបើលើកទ័ពទៅការពារ រាំងរាពុំឈ្នះទ័ពសៀមដែរ ។
ក៏ទ្រង់ព្រមថ្វាយរាជ្យសម្បត្តិ ទៅព្រះមហាក្សត្រធម្មោខ្មែរ
ពុំហ៊ានទទឹងរឹងគេចកែ តាមតែព្រះទ័យប្រោសមេត្តា ។

ព្រះបាទធម្មោរាជាជាតិ ខ្ទីខ្នាតរៀបចំកិច្ចរាជការ
ក្នុងព្រះបុរីរាជសីមា តាមព្រះចិន្តាដោយសុចរិត ។
ទី ១៤ ទៀតឆ្លៀតថ្លាថ្លែង សំដែងប្រវត្តិតត់លិខិត
ក្សត្រថ្លៃធម្មោស្ដេចទ្រង់ក្រិត រៀបរាប់ដោយល្អិតត្រិស្ដសាសនា។
មួយពាន់មួយរយកៅប្រាំបី ចក្រីធម្មោលើកបុត្រា
ច្បងមួយព្រះអង្គសនេហា ព្រះនាមឈ្មោះថាស្រីសុគន្ធបាទ ។
ឱ្យសោយរាជ្យស្នងព្រះចេស្ដា តាងព្រះបិតាតាមក្បួនខ្នាត
ក្សត្រថ្លៃមពង្សទ្រង់អនុញ្ញាត បូត្តបរិសុទ្ធស្អាតប្រពៃថ្លៃ ។
ក្នុងរាជស្ដេចនេះកើតចម្បាំង ក្នុងយ៉ាងខ្លាំងពន់ពេកក្រៃ
ខ្មែរឈ្មោះនាយកនកាចចង្រៃ ច្បាំងនឹងក្សត្រថ្លៃសុគន្ធបាទ ។
ឯកូនាយកនជាពលព្រះ គាប់នឹងស្ដេចណាស់ជាមនុស្សឆ្លាត
ចុះឡើងចេញចូលក្នុងប្រាសាទ សង្វាតឡើងគាល់រៀងរាល់ថ្ងៃ។
ឯសេនាម៉ឺនមុខមន្ត្រី សេនាបតីមហាក្សត្រថ្លៃ
មានចិត្តឥស្សាច្រណែនក្រៃ កែខៃរករឿងទូលបង្កាច់ ។
បន្ទុះនាយកនមនុស្សសំណប់ ឱ្យស្ដេចទ្រង់ស្អប់យកទោសផ្ដាច់
ជីវិតជីវន្តមិនទាន់ស្រេច សម្រេចសេចក្ដីដូចគំនិត ។
នាយកនដឹងខ្លួនរត់ពួនបាត់ ប្រយ័ត្នការពារជន្មជីវិត
ខឹងនឹងទ្រង់យសគ្មានទសពិត ប្រព្រឹត្តតាមមនុស្សឥស្សា ។
នាយកនភៀសទៅនៅខែត្រក្រៅ ដើរហៅប្រមូលពួកសេនា
គ្រប់ខេត្រកម្ពុងក្នុងសីមា ច្រើនក្រៃត្រៀបគ្រាក្បួនទ័ព។
ចេញទៅតតាំងច្បាំងនឹងស្ដេច រៀបទ័ពស្រួចស្រេចវាយប្រសប់
ទិសបួនឡោមព័ទ្ធសង្កត់ជាប់ ពលស្ដេចត្រឡប់បរាជ័យ ។

នាយកនធ្វើគត់ព្រះសុគន្ធ បាទអស់ព្រះជន្មគ្រានោះនៃ
រូចច្បាំងតាំងខ្លួនឯងប្រពៃ ជាស្ដេចឡើងវើតសូញ្ញា ។
គ្រឹះស័កមួយពាន់ប្រាំរយប្រាំ គេចាំដឹងឮឃើញគ្រប់គ្នា
នាយកនធ្វើស្ដេចកម្ពុជា គណនាចំនួនដប់បួនឆ្នាំ ។
ក្រោយមកព្រះអង្គច័ន្ទទី១ ស្ដេចស្ដែងតែងព្រួយចិត្តរកាំ
ដោមឯកប្លែកពិតនិម្មិតសាំ ខុសពីចំណាំតាមធម្មតា ។
ព្រះអង្គគង់នៅក្នុងស្រុកសៀម ជ្រាបថាព្រះរៀមរតន៍រេខា
នាយកនធ្វើគត់ផុតសង្ខារ ក្សត្រាលើកទ័ពក្នុងគ្រឹះស័ក ។
មួយពាន់មួយរយដប់ប្រាំឆ្នាំ សស្រាំចូលមកកម្ពុជា
សងសឹកជួសតាងព្រះរៀមរក្ស អប្បលក្ខណ៍នាមថាអាកនកាច ។
ចាក់កាប់សម្លាប់គ្នាអស្ចារ្យ ក្សត្រាចមពង្សទ្រង់អំណាច
ព្រះទ័យក្លៀវក្លាហានអង់អាច មិនខ្លាចលុកចាប់នាយកនបាន ។
សម្លាប់ចោលនៅក្នុងបន្ទាយ ព្រះអនុជពណ្ណរាយពង្សអវតាន
សោយរាជ្យសម្បត្តិជាក្សត្រក្សាន្ត ក្នុងភូមិភពឋានរាជបូរី ។
ព្រោះតែចម្បាំងគ្នាញឹកញយ នាំឱ្យជ័យឫទ្ធិរាជរាសី
សៀមទៀតក៏ឆ្លៀតតែងសេចក្ដី សារទាររជីរសពីខ្មែរ ។
ស្ដេចព្រះអង្គច័ន្ទមិនព្រមអោយ ថ្ងៃក្រោយសៀមខឹងខំប្រឹងតែ
លើកពលពាលោច្រើនហូរហែ ចូលវាយស្រុកខ្មែរយកជ័រ ។
ប៉ុន្តែសៀមចាញ់គ្រប់អន្លើ ស្ទាក់ស្ទើរគ្រឡប់វិលវិញវៃ
គ្រឹះស័កមួយពាន់ប្រាំរយខ្ចី ម្ភៃប្រាំបីម្ដងប្រាកដ ។
រំលងប្រាំឆ្នាំក្រោយមកទៀត សៀមឆ្លៀតលើកទ័ពគ្មានកំណត់
មកច្បាំងតតាំងទៀតទៀងទាត់ វាភ្លាត់ចំណាប់ចាញ់ទៀតដែរ ។

ទ័ពសៀមលើកមកតាមជើងទឹក ជើងគោកសន្ធឹកខ្លាំងពូកែ
គង់នៅរត់ខ្ចាត់ខ្ចាយទ័ពខ្មែរ គេចបែរថយវិញគ្រឹះស័កឆ្នាំ ។
មួយពាន់ប្រាំរយសាមសិបបី សេចក្តីសាមគ្គីកំណត់ចាំ
សាវតាប្រវត្តិកត់ចំណាំ ស្តេចសៀមរកាំព្រះចិន្តា ។
ក្រោយសៀមបាក់ទ័ពត្រឡប់ទៅ ស្រុកទេសលំនៅវិញកាលណា
ស្តេចព្រះអង្គច័ន្ទជាតិខេមរា ទ្រង់លើករដ្ឋាក្រុងបូរី ។
ទៅតាំងនៅទីលង្វែកវិញ ភូមិភាគនេះមិញគួរគប្បី
ថ្វាយការពារទ័ពខ្មាំងអប្រិយ ជាងនៅដែនដីស្រុកពោធិសាត់ ។
ស្តេចព្រះអង្គច័ន្ទសំខាន់ណាស់ ហ្លួងម្ចាស់បានសោយរាជ្យសម្បត្តិ
គ្រប់គ្រងដែនដីប្រពៃក្តាត់ បរិស័ទអស់អញ្ជស្រឡាញ់ក្រៃ ។
ព្រះបាទចមពង្សស្តេចទ្រង់ធមិ ព្រះទ័យត្រង់ល្អអចិន្ត្រៃយ៍
ជ្រះថ្លាចំពោះរតនត្រ័យ ក្សត្រថ្លៃសោយរាជ្យសែសិបឆ្នាំ ។
ទ្រង់បានសាងវត្តលោកសង្ឃ តម្រង់ព្រះទ័យក្នុងសីលប្រាំ
ប្រាថ្នាមគ្គផលកុសលកម្ម ជឿតាមបណ្តាំពុទ្ធសាសនា ។
ព្រះបាទសម្តេចព្រះអង្គច័ន្ទ ទ្រង់ព្រះសុវណ្ណគតសង្ខារ
ក្នុងឆ្នាំមួយពាន់ប្រាំរយហា សិបប្រាំដោយការប្រពៃណាស់ ។
ទី ១៥ បែរប្រែអធិប្បាយ បរិយាយតាមក្បួនប្រវត្តិសាស្ត្រ
ស្តេចខេមរាវង្សទ្រង់តេជះ ជាក់ច្បាស់រវាងគ្រិស្តសាសនា ។
មួយពាន់ប្រាំរយហាសិបប្រាំ ចំណាំចំណែកពង្សាវតារ
ព្រះបាទបរមឥន្ទរាជា ឡើងសោយរាជ្យគ្រាក្រោយតមក ។
កាលនោះស្តេចសៀមកើតចម្បាំង នឹងមនយ៉ាងខ្លាំងសៀមជ្រុលជ្រក
ស្តេចដែនដីខ្មែរប្រែរិះរក ឱកាសវាយយកស្រុកសៀមវិញ ។

ទ័ពខ្មែរពូកែខាងវាយបក ចូលដល់បាងកកពលពាសពេញ
ទ័ពសៀមស្លន់ស្លុតភ័យរត់ចេញ ជើងដូចគេវេញប្រាសកន្លែង ។
ខ្មែរចាប់បានឈ្លើយចិតសិបពាន់ នាំដល់តំបន់ហើយចាត់ចែង
ប្រើធ្វើបង្គីរែកលីសែង ធ្វើផ្ទះសម្បែងវាំងតំណាក់ ។
ដល់រាជចក្រពង្សទ្រង់នាមា ព្រះបាទសទ្ធាទីមួយជាក់
សោយរាជ្យជិណស្ដេចខេមរៈ បញ្ជាក់ដឹងច្បាស់គ្រិស្តសាសនា ។
មួយពាន់ប្រាំរយហុកប្រាំពីរ ក្សត្រថ្លៃភូមីឫទ្ធីក្លា
ស្ដេចបានឱកាសបង្កើយការ និងសៀមដោយសាមនមានជ័យ ។
ចូលលុកវាំងមុនីដុតទីក្រុង ខ្ទេចខ្ទីគ្មានគង់វង្សទីទៃ
កើតអន្តរាយពិតសៀមភិតភ័យ ចាត់វៃអោយទូករូតម្ភីម្នា ។
មកពឹងព្រះអង្គអោយជួយច្បាំង ដេញខ្មាំងអំពីទីភារា
ព្រះបាទសម្ដេចព្រះសុទ្ធា រាជាលើកទ័ពទៅជួយថៃ ។
ទ័ពខ្មែរពូកែយ៉ាងសម្បើម ចូលវាយដណ្ដើមទីក្រុងក្រៃ
ទ័ពមនអង់អាចខ្លាចក្សិណក្ស័យ ដោះដៃរត់ទៅស្លាប់ម្ភីម្នា ។
ដល់ពីរបីឆ្នាំតមកទៀត សៀមឆ្លៀតសងគុណព្រះសុទ្ធា
លើករាល់ចូលលុកកម្ពុជា ប៉ុន្តែហេតុពីអកតញ្ញូ ។
ទ្រុសគុណខ្មែរយ៉ាងនេះឯង លើកទ័ពមកតែងមិនធនស៊ូ
ចាញ់ខ្មែរក្លាហានមិនបានយូរ សិស្សភ្លេចគុណគ្រូវិនាសឆាប់ ។
ក្រោយទៀតស្ដេចលាវប្លួងប្របាង ចមប្រាង្គលើកពលមកគាន់គាប់
អាងអួតឫទ្ធីមីរខ្នាន់ខ្នាប់ ចូលមកប្រកាប់ប្រចាក់គ្នា ។
ហ្លួងព្រះសុទ្ធាជាអម្ចាស់ មានឫទ្ធិតបះក្រៃមហិមា
លើកទ័ពតតាំងច្បាំងរាំងរា រាជាឈ្នះលាវបច្ចាមិត្ត ។

អំណើះដល់រាជមហាក្សត្រា ព្រះជ័យជេដ្ឋាទីមួយពិត
រឿងប្រវត្តិសាស្ត្រថ្លែងស័ក្តសិទ្ធិ ប្រឌិតថាក្នុងគ្រិស្តសាសនា ។
មួយពាន់ប្រាំរយចិតសិបប្រាំបួន រៀបរាប់ចំនួនមហាក្សត្រា
ព្រះបាទសទ្ធាជាព្រះបិតា ស្តេចផ្ទេររាជប្រាអោយរាជបុត្រ ។
ទ្រង់នាមព្រះបាទជ័យជេដ្ឋា ឬជ័យជេស្ដាដ៏បរិសុទ្ធ
ការចលាចលវាងមិនផុត ព្រោះព្រះធម្មុតបូផែនដី ។
ដាក់រាជ្យសម្បត្តិអោយបុត្រា ពួកសេវកាមាត្យមន្ត្រី
អន់ចិត្តជាខ្លាំងទាំងប្រុសស្រី ប្រជារាស្ត្រក្តីចលាចល ។
ពេញទាំងនគរវិកវរណាស់ ទាំងក្មេងទាំងចាស់កោលាហល
អុកឡុកពុំសុខកើតកង្វល់ រៀងដរាបដល់គ្រិស្តសាសនា ។
មួយពាន់ប្រាំរយកៅសិបបី ជាតិសៀមអប្រិយចិត្តឫស្យា
ឃើញខ្មែរកង្វល់ក្នុងសីមា ដូចចាំខាងលើមកហើយស្រាប់ ។
សៀមទៀតឆ្លៀតលើកពលសេនីយ៍ ចូលមកឃ្មាតខ្មីសង្កត់ផ្ដាប់
ចូលដល់លង្វែកស្រែកអឺងអាប់ ស្ទើរនឹងក្រឡាប់ផែនប្រថពី ។
ទ័ពខ្មែរពួកែចេញប្រយុទ្ធ អាវុធច្រូងច្រាងអាងឫទ្ធី
ចាក់កាប់សម្លាប់សៀមខ្ទេចខ្ទី សៀមថយចេញពីលង្វែកអស់ ។
មិនយូរប៉ុន្មានក្រោយនោះទៀត សៀមឆ្លៀតកែនទ័ពសព្វចន្លោះ
ក្មេងចាស់ចំនាស់ចេះបាញ់បោះ មិនអោយសល់សោះក្នុងបុរី ។
មានទ័ពផ្ទើរជើងមួយពាន់នាក់ កាន់ផ្គាក់កាន់ដាវសោវវែងខ្លី
ប្រាំបីរយរាប់ទ័ពហាត្ថី សុទ្ធតែដំរីសឹកសង្គ្រាម ។
មុនចូលចម្បាំងតាំងច្រកស្រា ក្លៀវក្លាបំផុតព្រេចហុតឈាម
បរទៅប្រុងប្រៀបរៀបក្លាម១ ចេញពីព្រហាមម៉ោងប្រាំបី ។

ពលសេះជិះសេះចងកែបឈ្នាន់ មួយពាន់ប្រាំរយពាក់អាវខ្លី
សៀតគ្រឹះក្របីលីទង់ដៃ ស្រែកវៃស្រែកហ៊ោលើកយោធា ។
សៀមលើកយោធីមីខ្មាន់ខ្មាប់ ស្មើរនឹងក្រឡាប់កម្ពុជា
ចូលព្រំប្រទល់ដល់ទ័ពភ្លា រាល់ខ្មែរការពារពេញទំហឹង ។
ទ័ពខ្មាំងវាយខ្លាំងអស់ពីចិត្ត ទ័ពខ្មែរចូលកិតកាត់ទទឹង
ទ័ពក្រឡប់វាយបកវឹង ទ័ពសៀមឈប់ទ្រឹងមួយស្របក់ ។
ទ័ពខ្មែរពូកែរាំងមិនឈ្នះ ទ័ពសៀមរហ័សបាញ់បន្តក់
បន្តិចសៀមកកចូលមកប្រក់ ទ័ពខ្មែរប្រែហាក់ជៀសមុខវា ។
ទ័ពខ្មាំងក៏តាំងលើកទង់ដៃ ផ្លុំត្រែចេញវៃលើកយោធា
សំដៅទៅក្រុងកម្ពុជា នាម្នាលង្វែករាំងស្តេចខ្មែរ ។
ទ័ពខ្មែរយាមក្បែរជុំវិញក្រុង បាញ់ប៉ុងផ្សេងផ្លូលរត់ចូលហែរ
សៀមចែចង្រៃខ្លាំងពូកែ ប្រឹងរត់បាញ់តកម្រឈប់ ។
រាល់ខ្មែរប្រែលុកពីក្រោយខ្នង កាប់ផងចាក់ផងវាយប្រទប់
ប្រទាស់ប្រទែងជ្រែងជ្រុលជ្រុប មួយថ្ងៃទល់យប់១ទល់ព្រឹក ។
យូរណាស់ព្រួញជះដូចទឹកភ្លៀង ទាត់ទៀងចាក់កាប់ស្លាប់សន្ធឹក
ខ្មោចខ្លីរក្រុងខ្មែរព្រោះតែសឹក រលាយដូចទឹកគ្មានសល់អ្វី ។
ទ័ពខ្មែរខ្មាំងទៅទាំងស្រស់ រត់ដោះចោលក្រុងព្រៃឫស្សី
ព្រះជ័យជេស្ឋាស្តេចផែនដី ហើយនិងព្រះបិតាព្រះអង្គ ។
គៀសខ្លួនទៅពួននៅស្ទឹងត្រែង ចំបែងព្រះទ័យព្រោះខូចបង់
ទីក្រុងលង្វែកបែកបាក់ខ្ទង់ ទៅជាផេះផង់ធូលីអស់ ។
ព្រោះសៀមវាលុកមកទីក្រុង ដុតខ្ទេចគ្មានគង់អ្វីតិចសោះ
ជាតិខ្មែរក្រមុំឬកំលោះ សៀមគៀរចាប់អស់ប៉ែតសិបពាន់ ។

ជាពេញ្ជីបេនាំទៅនៅស្រុកវ៉ា វេទនាអនេកប្លែកអនន្ត
តាំងពីនោះមកខ្មែរក៏អន់ អាប់អោនច្រើនជាន់ច្រើនតំណ ។
ថយឫទ្ធិអំណាចខ្លាំងពូកែ ព្រោះតែខូចបង់បន្ទាយល្អ
មហានគរមនុស្សកុះករ ត្រឡប់ជាក្រពន់ប្រមាណ ។
ទៅជានគរតូចទេវិញ ស្ទើរគេឯងមិញមិនស្គាល់បាន
ទៅចុងបូព៌ាប្រទេសស្ថាន គេស្មានដូចស្រុកស្ងួយសៀមពិត ។
ទីដប់ប្រាំមួយខ្ញុំសូមថ្លែង សំដែងទៅក្រោយដោយពិនិត្យ
តាមក្បួនប្រវត្តិសាស្ត្រសិកសិទ្ធិ ដល់ជិតកណ្ដាលសាសនា ។
មួយពាន់ប្រាំរយគ្រាក្រោយមក ស្រង់យកសំណៅពង្សាវតារ
អំពីអ្នកស្រុកជាតិខេមរា ពុំដែលផ្ញើសារកាន់គ្នាទេ ។
ចំពោះប្រទេសអឺរ៉ុបសោះ ពីព្រោះកាលនោះផ្លូវវៀចវេ
ឆ្ងាយពេកអនេកបានជាគេ ក្រក្រៃក្រិះរេទៅមកណាស់ ។
ផ្លូវកប៉ាល់ភ្លើងក៏គ្មានដែរ ព្រៃកជីកស៊ុយអេជំនាន់ចាស់
ពុំទាន់មានដងឆ្លងជលសាស លំបាកក្រៃក្រាស់ពន់ប្រមាណ ។
អ្នកដើរមួយឆ្នាំទើបបានដល់ ត្រូវខ្យល់រលកបោកបក់ប្រាណ
ត្រូវវាងជ្រោយបោនលោនជលស្ថាន អែះស្បែរ៉ង់បានទើបបានដល់ ។
ឯផ្លូវទៅមកលំបាកពិត ឆ្ងាយណាស់មិនជិតដូចចាំស្រាប់
ប៉ុន្តែគង់មានជាតិចំណាប់ វែ្កកសស្រអាប់អឺរ៉ុព្វាង ។
បានមកនគរកម្ពុជា មិនរាមកទៅតាមផ្លូវវាង
ផ្លូវរាបវែងវង់គង់មិនរាង គេប្រៀបថាកាលត្រិស្តសាសនា ។
មួយពាន់ប្រាំរយហាសិបឆ្នាំ ឃើញចាំប្រាកដពង្សាវតារ
ជាតិព័រទុយហ្គែកួចផ្កា យាត្រាដល់មកប្រទេសខ្មែរ ។

ជាលើកបឋមតាមសំពៅ ឬទូកក្រហៅធំៗដែរ
ប៉ងរកស៊ីជួញជំនួញព្រៃ ប៉ុន្តែមានអ្នកប្រៀនប្រដៅ ។
សាសនាកាតូលិកមកព្រមគ្នា តាំងព្រះវិហារនៅខាងក្រៅ
ក្នុងខេត្តមួយជាប់ជារឿងរ៉ាវ មាននាមឈ្មោះហៅពញាឮឯង ។
ព័រទុយហ្គេខ្លះរប៉សកែ យកប្រពន្ធខ្មែររូបល្អខែង
មានកូនមានចៅតអង្វែង គេឯងដឹងស្គាល់ដល់សព្វថ្ងៃ ។
ហៅភូមិកាតូលិកក្រុងភ្នំពេញ មនុស្សច្រើនចូលចេញអចិន្ត្រៃយ៍
ដាក់ឈ្មោះភូមិស្ថានមានបច្ច័យ ជាប់ជាយូរក្រែមកហូរហែ ។
បន្ទាប់មានជាតិអេស្បាញ៉ុល ឬសគល់សាសន៍នេះអឺរ៉ុបដែរ
នៅស្រុកម៉ានិលយូរឆ្នាំខែ ស្រាប់តែចូលមកកម្ពុជា ។
ក្រោយជាតិអឺរ៉ុបព័រទុយហ្គេ រិះរេរករឿងទាស់ទែងគ្នា
អេស្បាញស្វាញស្វិតចិត្តនិន្នា នាម្នាអ៊ីគោរបល្លូសូរ ។
និងរុអេហ្វូសកាស្ទីយ៉ា ឬស្យាទុច្ចរិតចិត្តលោភា
គិតការកំបាំងតាំងសញ្ញា ឡើងរដ្ឋា(រាជា)ឈឺឆ្អាលស្តេចពញាតន់ ។
ដឹកនាំពលកងឆ្លងសមុទ្រ ច្រើនក្រៃបំផុតគ្រឿងយុទ្ធភ័ណ្ឌ
ចូលដល់ភូមិភពគ្រប់តំបន់ រិបជាន់ដណ្តើមរាជ្យសម្បត្តិ ។
អំពីស្តេចខ្មែរទ្រង់នាមនៃ រាមាជើងព្រៃដេញកំចាត់
ព្រះបាទរាមាជាមហាក្សត្រ ទ្រង់ព្រួយពេកក្លាត់បរាជ័យ ។
ចាញ់ដៃអេស្ប៉ាញច្បាំងស្វាញស្វិត ល្មោចល្មិតពួកពលផងទីទៃ
រាមាដាក់រាជ្យរំពេចវៃ ថ្វាយស្តេចជេដ្ឋជ័យពញាតន់ ។
ព្រះបាទពញាតន់ទ្រង់អំណរ ស្មោះសទទួលរាជ្យរូសរាន់
រួចស្តេចសងគុណធ្ងន់អនន្ត តាមជាន់យសសក្តិថ្នាក់ទាបខ្ពស់ ។

អ៊ុគោរបល្លូស្សូអេរ៉ូប្អូស ហ្លួងម្ចាស់ដំឡើងថ្កុំថ្កើងយស
អោយធ្វើចៅហ្វាយខេត្តចំពោះ អនុគ្រោះតបគុណតាមកម្លាំង ។
ក្រោយជាតិអឺរ៉ុបសាសន៍ហូល្លង់ នៅខាងជើងត្រង់ស្រុកបារាំង
ផែនដីទំនាបទាបយ៉ាងខ្លាំង វិស្សាចូលប្រាំងរងារណាស់ ។
ជាតិនេះពូកែធ្វើជំនួញ ចំណែកខាងជួញរកប្រាក់កាស
ហ៊ានដើរសមុទ្របំផុតសាស្ត្រ ទាំងក្មេងចំណាស់មិនខុសគ្នា ។
ក្នុងកាលគ្រានោះសាសន៍ហូល្លង់ លះបង់ស្រុកធំដីគម្មា
ចូលមកតាំងទីនៅស្រុកជ្វា យូរយារអង្វែងឆ្នាំណាស់ហើយ ។
ចង់ធ្វើជំនួញរកទ្រព្យា ក្នុងកម្ពុជាពុំលង់ឡើយ
បើកទូកសំពៅឆ្លងកោះត្រើយ បានមកដល់ហើយគ្រិស្តសាសនា ។
មួយពាន់ប្រាំមួយរយពីរពិត ខ្ញុំសង្កេតគិតឃើញសាវតារ
សាសន៍ព័រទុយហ្កេចិត្តប្ញស្សា កាឡាធើឃើញហូឡង់ដែរ ។
នាំគ្នាចាក់កាប់សម្លាប់ទៅ អស់ពីរសំពៅនៅទទេ
កាន់ចិត្តអាឃាដព្យាបាទគេ ចងពារវេរាមិនឈប់ឈរ ។
ប៉ុន្តែអានជាតិហូល្លង់ខ្លះ សង់ផ្ទះជំនួញក្នុងនគរ
អាងរាជការធំជាជំហរ ក្សត្រថ្លៃភូធរជាតិខេមរៈ ។
ដឹងពៅហ្វាយស្រុកហូឡង់ដេ ក៏គេមានចិត្តអាណិតស្ម័គ្រ
ចងស្ពានមេត្រីក្តីរាក់ទាក់ នឹងកម្ពុជៈស្តេចស្រុកខ្មែរ ។
ផ្ញើរសារទៅមកជាញយញឹក ក្រាបទូលរំឭកគ្រប់ឆ្នាំខែ
ជួញបានចម្រើនកើនហូរហែ ហូឡង់ពូកែរកស៊ីណាស់ ។
សាសន៍ព័រទុយហ្កេចិត្តឈ្នានីស រេរិះរករឿងចាញ់ចង់ឈ្នះ
ដំឡើងចកថ្កើងដូចថ្លើងបះ ចាក់ច្រាស់សម្លាប់ហូឡង់ដេ ។

ញីក១ញយ១ដោយជុំវិញ វិបអួសទំនិញយកទទេ
ទទួចស្ទូរពូជលួចបួន់គេ ជាតិហូឡង់ដេនៅពុំបាន ។
ឈប់ធ្វើជំនួញក្នុងស្រុកខ្មែរ តាំងតែទើសទាក់ក៏អាក់ខាន
ព្រោះព័រទុយហ្គេកាចសាមាន្យ កាន់ចិត្តតិរច្ឆានអន្សតិរ្ថិយ៍ ។
បារាំងសែសសាសន៍អឺរ៉ុបដែរ មកនគរខ្មែរយើងនេះខ្មី
មុនគេរាប់នាមតាមសេចក្តី ប្រវត្តិបូរីកម្ពុជា ។
នាមឈ្មោះហៅលោកជីឡាមុត មុនគេបំផុតតាំងវិហារ
សាសនាកាតូលិកមួយនៅនា ពញាឮក្នុងគ្រាគ្រិស្តសាសនា។
មួយពាន់ប្រាំរយប៉ែតសិបប្រាំ ចំណាំចំណែកពង្សាវតារ
តែនៅពុំបានខានធ្វើការ ព្រោះសាសន៍ឫស្យាព័រទុយហ្គេ។
លុះរំលងក្រោយមួយរយឆ្នាំ គេចាំរហូតមិនភូតទេ
បារាំងសែសម្នាក់ទៀតនាម្មេ ឈ្មោះលីជីសេរីរ៉ុះរ៉ឺមក ។
ក៏ព័រទុយហ្គេបានកំចាត់ កំចាយចេញបាត់កើតសៅលោក
នៅពុំបានទេគេកុំចោក មិនអោយនៅជ្រកក្នុងស្រុកខ្មែរ។
យើងនឹងដឹងរឿងទៅមុខទៀត គួរឆ្លៀតមើលក្នុងប្រវត្តិសែ
អំពីបារាំងមកតាំងថ្លែ ស្រុកយើងតាំងតែពីកាលណា។
ក្នុងកម្ពុជាភារារដ្ឋ កំណត់ឆ្នាំខែប្រែសញ្ញា
គង់ដឹងដំណឹងពង្សាវតារ ពីជាតិខេមរានិងបារាំង ។
ទីដប់ប្រាំពីរកាលរលាយ ខូចបង់បន្ទាយលង្វែករាំង
ស្រុកខ្មែរស្គាល់តែពីទុក្ខំ ហេតុកើតចម្បាំងនឹងគ្នាឯង ។
មួយពាន់ប្រាំរយកៅសិបប្រាំ គេចាំគ្រិស្តសកដោយជាក់ស្តែង
ស្រុកខ្មែរមានទុក្ខយូរអង្វែង ប្រជែងដណ្តើមអំណាចគ្នា ។

មិនដល់មួយរយឆ្នាំឡើយនៃ មានស្តេចប្រាំបីព្រះអង្គា
សុគតព្រោះញាតិមិត្តពាធា និងសុគតគ្រាកើតចម្បាំង ។
ព្រោះជាតិដទៃចាប់ធ្វើគត រលាយរលត់ផុតជីវី
ដូចបានអធិប្បាយរាយនាមំ ទុកជាទីតាំងខាងក្រោមស្រាប់ ។
មួយស្តេចរាមាជើងព្រៃ សោយរិលាល័យទៅឆាប់ៗ
ដោយពីរទុយហ្គេបះបោរកាប់ ឬបាញ់សម្លាប់គ្រិស្តសាសនា ។
មួយពាន់ប្រាំរយកៅសិបប្រាំ គេចាំប្រាកដពង្សាវតារ
ពីរទៀតព្រះបាទជាតិខេមរា ទ្រង់ព្រះនាមថាស្តេចពញាតន់ ។
សោយរិលាល័យក្នុងចម្បាំង នឹងចាមយ៉ាងខ្លាំងខ្សែជីវិន
ចូលកាន់ទីស្ថានមឿរតាមទាន់ នៅក្នុងតំបន់ខេត្តត្បូងឃ្មុំ ។
បីស្តេចព្រះនាមឈ្មោះពញាអាន ក្សត្រក្សាន្តសុគតព្រោះគំនុំ
មនុស្សព្រះប្អោស់ច្បងចងពៀរពុំ ល្ហែល្ហើយដល់ជុំជួបសាមគ្គី ។
ប្រល័យស្តេចក្ស័យព្រះជន្មា វេរាព្រះអង្គចង់ប្រតិព័ត្ត
ប្រពន្ធគេនោះព្រោះកាចភ្លាត់ ព្រះជនប្រាកដគ្រិស្តសាសនា ។
មួយពាន់ប្រាំរយកៅសិបប្រាំបួន សំនួនរឿងរ៉ាវពង្សាវតារ
ថ្លាថ្លែងសំដែងតាមរបា ក្សត្រជាតិខេមរាប្រាំបីអង្គ ។
បួនស្តេចព្រះនាមពញាសួរ ខ្ញុំថ្លែងហែហួរដោយត្រង់ៗ
ស្តេចអស់ព្រះជន្មព្រោះចិត្តចង់ ចំណងរាគៈកាមតណ្ហា ។
គំណាលថាកាលព្រះមហាក្សត្រ បានសោយសម្បត្តិស្រេចកាលណា
ទ្រង់បានប្រគល់កិច្ចរាជការ ថ្វាយព្រះបិតុលានាមឧទ័យ ។
ជួយរៀបចាត់ចែងតែងរាជការ ក្នុងដែនសីមាថ្វាយជេដ្ឋជ័យ
ពញាសួរលោភាពុំប្រពៃ ក្បត់ព្រះឧទ័យជាបិតុលា ។

ក្រោយមកលួចយកព្រះមហេសី នាមអង្គវត្តិស្រីកល្យា
ត្រូវជាព្រះញាតមាតុច្ឆា ស្នេហារួមរ័ក្សស្ម័គ្រមេត្រី ។
ព្រះបាទឧទ័យស្តេចជ្រាបច្បាស់ ទ្រង់ខ្ញាល់ពេកណាស់ព្រះចក្រី
ធ្វើគតពញាសួរស្តេចផែនដី ជាព្រះក្មួយខ្ទីគ្រិស្តសាសនា ។
មួយពាន់ប្រាំមួយរយសាមសិប ចាមតិញអារ៉ាប់ដើរស៊ើបការណ៍
ថ្វាយព្រះឧទ័យលួងព្រះបិតុលា ពញាសួរអាសារបរាជ័យ ។
ប្រាំ ហ្លួងសម្តេចព្រះអង្គនន់ ព្រះទ័យទន់ភ្លន់ល្អប្រពៃ
បុត្រាព្រះបាទស្តេចឧទ័យ សោយវិលាល័យព្រោះព្រះវង្ស ។
នាមព្រះអង្គច័ន្ទស្តេចធ្វើគត់ រលាយរលត់សង្ខាទ្រង់
ព្រមព្រះបិតាព្រះចោមពង្ស ពុំគង់មរណាំទាំងរាជបុត្រ ។
ដណ្តើមអំណាចយករាជ្យសោយ តមកខាងក្រោយពុំបរិសុទ្ធ
អង្គច័ន្ទចូលសាសន៍ស៊ីម៉ាឡុត តាមជ្វាកំបុតពួកមហាម៉ាត់ ។
កាលនោះមានជាតិហូឡង់ដេ ក៏គេបានឃើញព្រះមហាក្សត្រ
ស្តេចព្រះអង្គច័ន្ទអាក្រក់ក្តាត់ ធ្វើកម្មវិបត្តិបុត្រអង្គនន់ ។
ជាយ៉ាងសម្បើមអស្ចារ្យណាស់ បាបនេះក្រៃក្រាស់អាក្រក់លន់
ឃុំក្នុងធិមផៃវយូរពេកពន់ អោយក្ស័យព្រះជន្មព្រោះអាហារ ។
យូរថ្ងៃបុត្រផ្ទៃព្រះអង្គនន់ អត់ធន់ពុំបានឃ្លានអស្ចារ្យ
ហែកព្រះមំសាំធ្វើក្រយា អោយជាអាហារដូចក្អែកត្មាត ។
ប្រាំមួយព្រះបាទបូទិម្មា រាជាសុគតក្នុងប្រាសាទ
ព្រោះព្រះសិរសារស្តេចប្រមាទ ធ្វើរាជឃាដគ្រិស្តសាសនា ។
មួយពាន់ប្រាំមួយរយចិតសិបពីរ មែនពិតជាទីគួរអស្ចារ្យ
ពុំដឹងរឿងខឹងដូចម្តេចម្ល ក្សត្រាស្តេចសោយវិលាល័យ ។

ប្រាំពីរ ព្រះបាទជ័យជេដ្ឋា ហឫទ័យឫស្យាពុំប្រពៃ
ធ្វើគតប្អូនជេដ្ឋជ័យ ស្រេចរឹបង្ខំយកមហេសី ។
ព្រះបាទបទំបិតាក្មេក អាក្រក់ពន់ពេកក្នុងបូរី
ប៉ុន្តែក្រោយមកអគ្គមហេសី ព្រះបទំស្រីមានបញ្ញា ។
ញុះញង់អោយផ្ងាវាធ្វើគត រលត់ព្រះជន្មជ័យជេដ្ឋា
ភ្លាម១សរឈរាមមហាក្សត្រ បទំភស្តាស្វាមីមិត្រ ។
មួយពាន់ប្រាំមួយរយចិតបី គ្រិស្តសាសនាខ្មីសេចក្ដីពិត
រឿងរ៉ាវប្រវត្តិកត់កួចគិត បណ្ឌិតចារឹកទុកគរ១ ។
ប្រាំបី ព្រះបាទព្រះអង្គជ័យ សុគតក្នុងព្រៃក្រៅនគរ
ទីចម្បាំងខ្លាំងរឹករវរ នឹងព្រះតូចស្ដេចអង្គនន់ ។
មួយពាន់ប្រាំរយចិតសិបបួន គ្រិស្តសាសនាធួនស្ដេចអស់ជន្ម
ហេតុព្យេវរវើរាជាទម្ងន់ ព្រះបាទអង្គនន់ធ្វើគតបាន ។
ឯការចាក់កាប់សម្លាប់គ្នា ព្រះរាជវង្សានុវង្សាន
ជាយូរអង្វែងពន់ប្រមាណ លំអានតាំងពីគ្រិស្តសាសនា ។
មួយពាន់ប្រាំរយកៅសិបបី ក្នុងព្រះបូរីរាជរដ្ឋា
ដូចមានរឿងរ៉ាវពង្សាវតារ អស្ចារ្យរវាងជិតរយឆ្នាំ ។
ជាប់រៀង១មកដូច្នេះខ្មី រាស្ត្ររដ្ឋមន្ត្រីខ្មែររងកម្ម
មហាសត្រូវនៅប្រចាំ កើតទុក្ខសោកសាំគ្រប់វេលា ។
នគរអាប់អោនកោនតែខ្លួន សាសនាចាមសៀមយួនតួនផ្ដន្ទា
កញ្ជ្រោកកញ្ជ្រោលចូលយុទ្ធនា ច្បាំងយកភារាដោយឆ្វយ១ ។
ទីដប់ប្រាំបីប្រែថ្លាថ្លែង សំដែងតំណាតទៅនាយ
ក្រោយដែលស្រុកខ្មែរខូចបន្ទាយ លង្វែកសៀមវាយបែកខ្ទេចខ្ទី ។

លំដាប់តមកប្រទេសសៀម ឈប់ស្ញៀមពុំសូវចូលញាំញី
ប៉ុន្តែស្រុកខ្មែរតាំងអំពី នោះមកធានិរបរិត ។
ចេះតែមានហេតុចលាចល កង្វល់រំភើបកំរើបចិត្ត
ចាក់កាប់សម្លាប់គ្នាល្មោចល្មិត ច្បាំងដណ្តើមឫទ្ធិអំណាចគ្នា ។
សៀមទៀតក៏ឆ្លៀតរកឱកាស ឃើញសាសន៍ខ្មែរគ្មានធម៌សាមគ្គី
លើកទ័ពប្រសប់ទាន់វេលា ចូលយុទ្ធនាសង្គ្រាមជ័យ ។
ក្នុងរាជព្រះស្រីសុរិយោពណ៌ ក្សត្រថ្លៃតូចឥតនិរភ័យ
លើកទ័ពតតាំងច្បាំងវិញវៃ សៀមបរាជ័យត្រិស្តសាសនា ។
មួយពាន់ប្រាំមួយរយដប់ប្រាំបី ប្រែថ្លែងសេចក្តីទៅមុខថា
ដល់រាជព្រះបាទជ័យចេស្តា ទីពីរក្សត្រាយកក្សត្រី ។
ជាតិយួនសមសួនរូបល្អស្រស់ ស្ម័គ្រស្មោះស្មាលស្នេហ៍ជាមហេសី
យួនចូលមកនៅក្នុងបូរី ផែនដីខាងត្បូងត្រិស្តសាសនា ។
មួយពាន់ប្រាំមួយរយម្ភៃ ព្រះបាទជេដ្ឋជ័យនាមជេដ្ឋា
ស្តេចទ្រង់សំណព្វព្រះចិន្តា នឹងព្រះធិតាមហេសីយួន ។
យួនមានអំណាចអង់អាចណាស់ ធ្វើផ្ទះលំនៅ១មាំមួន
ខាងត្បូងក្រុងខ្មែរតែរៀងខ្លួន ច្រើនរាប់ចំនួនស្មើរពុំបាន ។
ពេញព្រៃនគរនិងសាដែក ចំណែកខាងត្បូងបូរីឋាន
ក្នុងរាជជេដ្ឋាមហាក្សត្រក្សាន្ត ស្តេចបានបណ្តោយតាមមហេសី ។
យើងនឹងបានឃើញទៅមុខទៀត សាសន៍យួនវាឆ្លៀតយកផែនដី
ដេញខ្មែរថយក្រោយអោយរួញខ្លី យួនធ្វើម្ចាស់ដីរួសរន្ថាន ។
បន្ទាប់មកទៀតកម្ពុជា ព្រះបាទរាមាធិបតីច័ន្ទ
នេះពុទ្ធសាសនាដែលសំខាន់ ចូលកាន់សាសនាពួកមហាម៉ាត់ ។

មួយពាន់ប្រាំមួយរយសែសិបពីរ គ្រិស្តសមទិវបាក្យត្រ
ស្តេចនេះហឫទ័យអាក្រក់ក្បាត់ លះកាត់ធមិព្រហ្មវិហារបួន ។
បានធ្វើគត់បង់ព្រះអង្គនន់ ក្សិណក្ស័យព្រះជន្មហេតុគុំកួន
ព្រមព្រះមាតាបិតាស្ងួន និងបុត្រក៏ជូនដល់មរណា ។
ទាំងព្រះវង្សានុវង្សក្តី អង្គនន់ចក្រីក្ស័យជន្មា
ដូចបានអធិប្បាយបរិយាយឃ្លា ពីកាលក្នុងគ្រាមុនហើយស្រេច ។
កាលនោះមានព្រះរាជបុត្រា ព្រះជ័យជេដ្ឋាទីពីរស្តេច
ពីអង្គរូបល្អសមសាច់ សម្រេចកើតពីអគ្គមហេសី ។
យួននោះចំពោះនៅមិននឹង ទីពឹងស្តេចយួនអបណាមខ្ទី
ស្តេចយួនមាំមួនលើកសេនី ចូលមកបូរីកម្ពុជា ។
ទ័ពយួនចំនួនច្រើនចំណាប់ ព័ទ្ធចាប់សម្តេចព្រះរាមា
ធិបតីអង្គច័ន្ទមូភារា នាំទៅម្ទីម្ទាឃាត់ឃុំទុក ។
គ្រិស្តសកមួយពាន់មួយរយ ហាសិបប្រាំបីក្រោយតទៅមុខ
បុត្រាជេដ្ឋានាំចាក់រុក អង្គច័ន្ទជាប់គុកនៅស្រុកយួន ។
កាលក្រោយសម្តេចព្រះអង្គច័ន្ទ បូរីខេត្តខ័ណ្ឌមិនមាំមួន
បុត្រាជេដ្ឋាទទួលខ្លួន សោយរាជ្យសមសួនតមកទៀត ។
នាមឈ្មោះព្រះបទំរាជា ឱរាមិនសូវតឹងចង្អៀត
ស្តេចនេះឯងជាក់ដែលឆ្លាក់ឆ្លៀត ពឹងយួនជ្រែកជ្រៀតចាប់អង្គច័ន្ទ ។
បទំមហាក្សត្រកូនកាត់យួន ព្រះរូបសមសួនល្អសំខាន់
បានសោយរាជ្យស្រេចស្តេចវន្ទាន ខ្ទីខ្ទានរៀបចំនគរខ្មែរ ។
ស្តេចដែលសោយរាជ្យតមកទៀត ខ្ញុំឆ្លៀតរៀបរាប់ជាប់ហូរហែ
តាមក្បួនសាវតាវង្សាសៃ ខែកែអោយច្បាស់គឺព្រះបាទ ។

ព្រះជ័យជេដ្ឋាស្តេចទី៤ ឧត្តមសមសួនបរិសុទ្ធស្អាត
សោយរាជ្យសម្បត្តិដោយដាច់ខាត ត្រឹមត្រូវក្បួនខ្នាតរបាក្សត្រ ។
ព្រះអង្គធុញទ្រាន់នឹងចម្បាំង ក្បត់ខ្លាំងពុំសុខវិតកក្តាត់
នៃនឹងជាតិយួនផ្ទួនមិនបាត់ មិនបានស្ងប់ស្ងាត់សោះឡើយហោង ។
ឥតមានកំណត់យប់ព្រឹកល្ងាច ស្តេចទ្រង់ដាក់រាជ្យដល់ប្អូនផង
អោយព្រះសុណិសាបុត្រាច្បង ឡើងសោយរាជ្យស្នងព្រះមហាក្សត្រ ។
ប៉ុន្តែកាលណាមានការក្រ ធំៗកម្រមកដល់ថ្វាត់
មន្ត្រីរាស្ត្រក្តីក្រាបប្រតិបត្តិ អញ្ជើញមហាក្សត្រសោយរាជ្យវិញ ។
គ្រិស្តសកមួយពាន់ប្រាំពីររយ មួយថែមខាងក្រោយនាំឱ្យម្នេញ
បារាបៀងវ៉ា និងយ៉ាឱញ យួនចូលនៅពេញដូចស្រុកវា ។
ដើមឡើយសាសន៍យួនចូលមកច្បាំង នឹងខ្មែរយ៉ាងខ្លាំងឥតគណនា
ប៉ុន្តែស្តេចទ្រង់នាម្នា ព្រះជ័យជេដ្ឋាថ្នាក់ទី៤ ។
បានលើកសាកលពលយោធា ច្បាំងទប់ការពារយ៉ាងមាំមួន
ចាក់កាប់សម្លាប់សេនាយួន យួនចាញ់ថយខ្លួនមិនផុតដែន ។
បារា បៀងវ៉ា និងយ៉ាឱញ នៅពេញទីនោះរាប់ម៉ឺនសែន
កាលមុនសុរត្តខ្មែរនៅណែន ស្រុកនេះជាដែនកម្ពុជា ។
ទី ១៩ សំនួនថ្លែង សម្តែងពីស្តេចទ្រង់នាម្នា
ព្រះបាទស្រីធម្មោរាជា ទីប្អូនកាលគ្រាសោយសម្បត្តិ ។
តំណាងព្រះបាទជ័យជេដ្ឋា ជាព្រះបិតាព្រះមហាក្សត្រ
រាជនេះមានហេតុអាក្រក់ក្តាត់ ពុំបានស្ងប់ស្ងាត់ក្នុងក្រុងក្រៃ ។
ស្តេចនាមអង្គឥមព្រះរៀមរត្ន ប្រាកដគឺត្រូវជាបងថ្លៃ
ដណ្តើមរាជរដ្ឋក្សត្រភូវណៃ ហៃហៃប្រជែងអំណាចថ្លា ។

ព្រះបាទអង្គឥមទៅពឹងយួន គុំកួនលើកទ័ពពលយោធា
តតាំងជួយច្បាំងយកភារា ធម្មោរាជាពឹងសៀមថៃ ។
សៀមទៀតឆ្លៀតលើកទ័ពយ៉ាងធំ ចូលដល់និគមទីក្រុងក្រៃ
ឧត្តុង្គកម្លុងពីរបីថ្ងៃ ក្សត្រថ្លៃអង្គឥមទ្រង់ជ្រាបថា ។
បើច្បាំងតតាំងក៏ពុំឈ្នះ ទ័ពសៀមច្រើនណាស់ហៅក្លាហាន
ទម្លាក់អាវុធមុខមុតថ្លា ចុះ ខ សញ្ញាដាក់ផែនដី ។
ក្រុងកម្ពុជាជាចំណុះ ស្រុកសៀមវិញចុះមិនជាអ្វី
សុំអោយតែស្តេចសៀមប្រណី អោយសាយបូរីរាជ្យសម្បត្តិ ។
តទៅសុំនៅក្នុងអំណាច ស្តេចសៀមឯងអាចអរពេកក្តាត់
ហើយបានយល់ព្រមល្មមបញ្ញត្តិ ស្តេចឡាយហត្ថលេខាភ្លាម ។
គ្រិស្តមួយពាន់ប្រាំពីររយ ម្ភៃទៅក្រោយខ្មែរទីមទាម
វិលវល់គំនិតរឹមរាម ស្មើរនឹងកួតឈាមគ្រប់ៗគ្នា ។
តាំងពីនោះមកស្តេចផែនដី ព្រះចៅបូរីកម្ពុជា
មានស្តេចសោយរាជ្យក្នុងភារា ត្រូវនាំភស្តុភារភ្ញីមាសប្រាក់ ។
សួយសារអាករជាទំនៀម ទៅថ្វាយស្តេចសៀមដោយស្មោះស្ម័គ្រ
តាម ខ សញ្ញីទីវដ្ត: ដែលបានបញ្ជាក់មកហើយស្រាប់ ។
គ្រិស្តមួយពាន់ប្រាំពីររយ ម្ភៃប្រាំទៅក្រោយឃើញក្បួនច្បាប់
ពង្សាវតាខ្មែរប្រែប្រាយប្រាប់ ទុកជាសណ្តាប់ដូច្នេះថា ។
ព្រះបាទអង្គឥមស្តេចប្រព្រឹត្ត ពុំសូវល្អពិតតាមក្រិត្យា
មន្ត្រីតូចធំក្នុងសីមា កើតមានចិន្តាអាក់អន់ចិត្ត ។
នឹងល្ងង់សម្តេចព្រះអង្គឥម ចរិយាពុំត្រូវសុចរិត
ខុសបែបលំនាំច្បាប់ក្រមក្រិត្យ រាស្ត្រពុំស្នេហ៍ស្និទ្ធស្រឡាញ់ផង ។

បង្ខំអោយផ្ទេររាជ្យសម្បត្តិ អោយបុត្រាក្សត្រសោយរាជ្យម្តង
នាមព្រះសុទ្ធាទីពីរស្នង ត្រឹមត្រូវបំណងតាមក្រសៃ ។
កាលនោះគាប់ជួនយួនឃើញថៃ មានអំណាចក្រៃលើជាតិខ្មែរ
មានចិត្តឈ្នានីសរិះគន់ដែរ គិតតែប្រែកិច្ចនយោបាយ ។
ចៅហ្វាយស្រុកយួនកួសាំងស៊ីន ទាក់ទិនរករឿងមុនវែងឆ្ងាយ
ចាប់ទោសថាខ្មែរក្តៅក្រហាយ ប្រើនយោបាយកាប់សម្លាប់ ។
យួនបួនដប់នាក់នៅស្រុកខ្មែរ ងឿកងែវរំពេចគេចក្រឡាប់
ប្រកាន់ទោសខ្មែរកែរកច្បាប់ ខ្មែរដោះសារប្រាប់យ៉ាងណាក្តី ។
យួនមិនព្រមជឿជាក់ក្នុងចិត្ត ទុច្ចរិតលើកពលពាសេនីយ៍
ចូលច្បាំងសង្ឃបយកផែនដី ខេត្តមីថរក្តី និងវិញឡុង ។
គ្រិស្តមួយពាន់ប្រាំពីររយ ម្ភៃប្រាំមួយរយនៅខាងចុង
ទាត់ទ្បើងរៀងរាល់ដល់មកក្នុង កំឡុងសាសនាគ្រិស្តមួយពាន់ ។
ប្រាំពីររយសាមសិបប្រាំមួយពិត ខ្ញុំបានពិនិត្យឃើញគ្រប់គ្រាន់
ប្រវត្តិខេមរាតាមថ្នាក់ជាន់ ប៉ុន្មានស្តេចខ្មែរនាមព្រះបាទ ។
សុទ្ធាទីពីរទ្រាំពុំបាន ក្សត្រក្សាន្តវាំងវៃព្រះទ័យស្អាត
ដាក់រាជ្យជ្រួលជ្រួសខ្លាចហួសខ្នាត ថ្វាយទៅព្រះបាទធម្មោវិញ ។
ឯលួងសម្តេចព្រះធម្មោ ទីបួនវរោស្បើយទោម្ទិញ
សោយរាជ្យសម្បត្តិតទៅមិញ ពិតចេញកំណត់បានដប់ឆ្នាំ ។
លុះព្រះធម្មោទីវង្គត រលាយរលត់ខ័ន្ធទាំងប្រាំ
ខាងក្រោយមកទៀតឡៀតគេចាំ ចំណែកចំណាំរាជ្យសម្បត្តិ ។
បានមកក្រោយទៀតស្រីធម្មោ ទីប្រាំវរោបុត្រមហាក្សត្រ
សោយរាជ្យតំណប្រពៃក្តាត់ តែនៅមិនស្ងាត់ចលាចល ។

| | |
|---|---|
| ស្តេចនេះសោយរាជ្យបានមួយឆ្នាំ | ជាហេតុពៀកម្មស្តេចមកដល់ |
| ព្រះអនុជបន្ទាប់ព្រះអង្គផ្ទាល់ | វកកលធ្វើគតព្រះអង្គបាន ។ |
| ទី ម្តែ សូមលៃរឿងប្រវត្តិ | សាវតាកំណត់ជាក់លាក់ថាន |
| ថ្លែងតាមដំណើរហេតុដើមដាន | លំអានពីគ្រិស្តស័កមួយពាន់ ។ |
| ប្រាំពីររយសែសិបប្រាំពីរ | រៀងវីរហូតបំផុតជាន់ |
| ដល់គ្រិស្តសាសនាបានគ្រប់គ្រាន់ | រវាងមួយពាន់ប្រាំពីររយ ។ |
| ហាសិបប្រាំពីរជាទីតាំង | ខេមរដ្ឋាវាសនាអោយ |
| កង្វល់វីវក់ជាញឹកញយ | ថ្លោះធ្លោយកើតពីចិត្តឥស្សា ។ |
| ប្រណែននិន្ទានឹងគ្នាឯង | ប្រជែងដណ្តើមយករាជប្រា |
| ស្តេចម្ខាងពឹងយួនឱ្យជួយការ | ស្តេចម្ខាងផ្ញើសារពឹងសៀមថៃ ។ |
| ឯសៀមនិងយួនជួនត្រូវចិត្ត | ចូលច្បាំងល្មោចល្មិតទីក្រុងក្រៃ |
| ច្បាំងឈ្នះរហ័សទារគុណក្រៃ | ពីខ្មែរយ៉ាងថ្លៃធ្ងន់ធ្ងរណាស់ ។ |
| មាសប្រាក់មិនសូវស័ក្តិគ្រប់ន្ទាន | បើបានទឹកដីអ្វីៗខ្លះ |
| គេសាទរជួយរហ័ស | ក្នុងប្រវត្តិសាស្ត្រសំដែងថា ។ |
| កាលនោះសម្តេចព្រះអង្គតុង | ក្សត្រថ្លៃឆោមយង់ពង្សឥស្សរា |
| ច្បាំងនឹងព្រះក្មួយមហាក្សត្រា | ទ្រង់នាមថាភគ្គនិយោ ។ |
| ព្រះភគ្គនិយោនាំទ័ពយួន | ចូលមករុកគួនក្សត្រត្រូវរោ |
| ព្រះបាទអង្គតុងទ្រង់ទុក្ខម្នោ | ព្រះក្មួយលោភាក្បត់ព្រះអង្គ ។ |
| បំណងដណ្តើមរាជ្យសម្បត្តិ | មហាក្សត្រហឫទ័យទ័យឡើនឡង់ |
| ឃើញទ័ពជើងគោកចូលមកត្រង់ | បំណងព័ទ្ធចាប់ព្រះរាជា ។ |
| ព្រះបាទអង្គតុងភៀសព្រះអង្គ | រត់នៅក្រុងព្ធយុធ្យា |
| ក្រោយនោះអស់ពួកពលយោធា | ខ្មែរចូលយុទ្ធនាច្បាំងនឹងយួន ។ |

យួនបរាជ័យមួយរំពេច រត់គេចថយក្រោយដោយវៀងខ្លួន
មេទ័ពជាតិខ្មែរសក្តិបីបួន ក្រោកខឹងមាំមួនគ្រប់ៗគ្នា ។
នឹងហ្លួងសម្តេចព្រះអង្គតុង រត់ភៀសពីក្រុងកម្ពុជា
ទៅនៅក្រុងស្យាមឰយុធ្យា ចោលក្រុងភារាភពផែនដី ។
ក៏នាំគ្នាថ្វាយរាជ្យសម្បត្តិ តំណែងមហាក្សត្រមូលសិរសី
ទៅព្រះជេដ្ឋាទី ៥ ខ្វី ចក្រីសោយរាជ្យកម្ពុជា ។
ព្រះជ័យជេដ្ឋាធ្វើចំបាំង តតាំងនឹងរាស្ត្រក្នុងភារា
អ្នកស្រែលូង់ខ្លៅឆ្កួតលេលា នាម្នាមនុស្សនោះឈ្មោះសិលសួស ។
មនុស្សឆ្កួតម្នាក់ទៀតជាតិហិនហៃ ពិការជើងដៃខ្វិនរបួស
លើកខ្លួនជាស្តេចសម្រេចហួស ក្លែងក្លាយជ្រួលជ្រួសរាជបញ្ញត្តិ ។
លុះព្រះជេដ្ឋាទីវង្គត រំលត់ខ័ន្ធប្រាំកម្មមកកាត់
មន្ត្រីរាស្ត្រថ្វាយរាជ្យសម្បត្តិ ទៅព្រះមហាក្សត្រអង្គតុងវិញ ។
អង្គតុងទ្រង់រាជ្យបានមួយឆ្នាំ គេចាំជីងញូចូច្នេះមិញ
ទ្រង់មានកលយុគកើតទុក្ខម្នេញ ចលាចលពេញក្នុងព្រះរាជវាំង ។
ត្បិតកាលនោះឯងព្រះឧទ័យ បុត្រនៃឧបរាជចាស់ចិត្តខ្លាំង
ធ្វើគតឧបរាជថ្មីមរណំ ក្សត្រថ្លៃសេដ្ឋិព្រះអង្គតុង ។
ស្តេចទ័យភៀសវៃទីវាលវាំងបាត់ ទៅគង់ពោធិសាត់ចោលទីក្រុង
ក្រោយនោះបន្តិចព្រះចោមពង្ស ទីវង្គតក្នុងខេត្តនោះឯង ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ ហាសិបប្រាំបីក្រោយខ្ញុំសូមថ្លែង
តទៅមុខទៀតតាមតំណែង ជាក់ស្តែងប្រវត្តិរាជធានី ។
ព្រះបាទតុងសុគតទៅ រាជ្យសម្បត្តិនៅលើភូមិ
ព្រះបាទឧទ័យស្តេចទីពីរ គង់ក្នុងប្រាង្គម្នីរត្នរាជវាំង ។

ព្រះឧទ័យខ្លៅល្ងង់មិញ ឱ្យខេត្តត្រានិញនិងស្រុកត្រាំង
ទៅយួនប្រយោជន៍យកសុខំ កុំឱ្យកើតច្បាំងនឹងសាសន៍យួន ។
យួននៅពុំស្កប់ស្កល់ចិត្តទៀត វាឆ្លៀតចូលវាយខ្មែរផ្ទួនៗ
យកខែត្រសាដែកធំមាំមួន មាត់ជ្រូកផងបួនខែត្រមែនពិត ។
មហានគរកម្ពុជា ទិសទក្ខិណាគេពិនិត្យ
បានទៅយួនអស់ខ្មែរគ្មានគិត ព្រោះខ្មែរថយឫទ្ធិខ្លៅល្ងង់ផង ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ ហុកសិបគ្រាក្រោយសៀមស្មៅហ្មង
ខឹងនឹងស្តេចខ្មែរពេកកន្លង ចាំចងគំនិតគិតផ្គនា ។
ព្រះបាទឧទ័យស្តេចទីពីរ ភូមីទទឹងរឹងមហិមា
នឹងស្តេចថៃសៀមព្ឈយុធ្យា ក្នុងគ្រាស្តេចសៀមសោយសម្បត្តិ ។
ព្រះបាទឧទ័យស្តេចស្នាក់ស្នើរ ទ្រង់មិនអើពើធ្វើស្គាល់ក្សត្រ
លុបលាងទំនៀមសៀមក្តៅក្តាត់ ខ្ទះបែបក្រស័ត្រមុនៗខ្ចី ។
សៀមខ្មែរទំនៀមពីបូរាណ ជាប់ជាល់អានក្នុងបុរី
បើសៀមផ្លាស់រាជ្យស្តេចផែនដី ស្តេចខ្មែរគប្បីនាំរាជសារ ។
ទៅថ្វាយស្រុះស្រួលទទួលស្គាល់ ទៀងទាត់រៀងរាល់តាមធម្មជាតិ
បើខ្មែរផ្ទេររាជ្យថ្វាយស្តេចណា ផ្ញើសារឱ្យសៀមយល់ព្រមផង ។
សៀមក្រេវក្រឡោតចាប់ទោសខ្មែរ ព្រោះតែប៉ុណ្ណឹងខឹងកន្លង
ព្រះបាទឧទ័យសោតត្រាប់ត្រង ទ្រង់ជ្រាបបំណងស្តេចសៀមជាក់ ។
ចាត់ប្រើរាជទូតទៅពឹងយួន លើកទ័ពមាំមួនមកចាំស្ទាក់
គ្រប់ព្រំប្រទល់កែនពលដាក់ ទ័ពខេមរៈយួនរួមគ្នា ។
យួនលើកទ័ពតាមទន្លេធំ ចូលដល់ដែនព្រំកម្ពុជា
សៀមថៃហាហៃលើកយោធា ចូលដល់ភារាច្បាំងប្រយុទ្ធ ។

យួនខ្មែរពូកែវ៉ាយទល់ជាប់ កងទ័ពសៀមមនរហ័សពិត
វ៉ាយបកថយក្រោយឱ្យពលរត់ តក់ស្លុតខ្លាចស្លាប់បរាជ័យ ។
យួនខ្មែរពូកែឈ្នះទ័ពថៃ សៀមសាសន៍ចង្រៃពេលនោះនៃ
ដកទ័ពត្រឡប់តាមផ្លូវព្រៃ វិលវែរសំដៅឰយុធ្យា ។
ចាប់ខ្មែរអ្នកស្រែមួយម៉ឺននាក់ ដោតជីងកន្ត្រាក់តាមផ្លូវថ្លា
ជាន់នោះជាតិខ្មែរកម្ពុជា សោយទុក្ខវេទនាពន់ប្រមាណ ។
ប្រទេសកើតសឹកជាញឹកញយ នាំឱ្យរាស្ត្ររងកម្មវិខាន
ធ្វើស្រែចំការក៏មិនបាន រត់ចោលភូមិស្ថានផ្ទះសំបែង ។
ជួនត្រូវទ័ពសៀមកែនទៅច្បាំង តតាំងនឹងយួនយកកន្លែង
ជួនយួនកែនយកសាសន៍ខ្មែរឯង ទៅប្រើចាត់ចែងតាមអាជ្ញា ។
ឱ្យខ្មែរជួយច្បាំងវ៉ាយសាសន៍សៀម ជាប់ជាទំនៀមក្នុងសីមា
ជួនខ្មែរចាប់ខ្មែរធ្វើសេនា ទាហានជួយការពារសត្រូវ ។
រាស្ត្រក្នុងនគរវឹកវរខ្លាំង ស្ងមស្ងាំងស្រែកឃ្លានគ្មានធ្វើស្រូវ
រកស៊ីមិនបានខានគ្រប់ផ្លូវ រាជការតម្រូវញឹកញាប់ណាស់ ។
ហើយថែមកើតជំងឺអុត ច្រើនក្រៃបំផុតស្លាប់រហ័ស
មូលរាកចុះក្អួតគ្រួតកម្ររាស់ ក្មេងចាស់ស្លាប់ច្រើនឥតគណនា ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ ចិតសិបប្រាំក្រោយមិនយូរយារ
ព្រះចៅផែនដីកម្ពុជា នាម្ចាឧទ័យស្តេចទីពីរ ។
ប្រយោជន៍នឹងឱ្យអស់ចម្បាំង ក្សត្រថ្លៃនាផ្ចិចមធានី
ដាក់រាជ្យថ្វាយទៅព្រះភូមី អង្គនន្ទជាទីព្រះរាជបុត្រ ។
ព្រះជ័យជេដ្ឋាស្តេចទីប្រាំ សោយរាជ្យប្រចាំសក្តិចមម្កុត
អង្គនន្ទទទួលស្រួលបរិសុទ្ធ មិនឱ្យហួសផុតពេលវេលា ។

ទីម្តេមួយនគរខ្មែរ ចេះតែអាប់អោនសួន្យឫទ្ធា
សៀមយួនគុំកួនវាយផ្តួនា តាំងតែពីគ្រាគ្រិស្តសាសនា ។
មួយពាន់ប្រាំពីររយដៀងជាក់ តមកឥតអាក់ជាធម្មតា
មហានគរធំអស្ចារ្យ ទៅជារដ្ឋាមួយតូចក្រៃ ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ ចិតសិបប្រាំក្រោយក្សត្រភូវណៃ
អង្គនន្ទទីពីរភូមីថ្លៃ ជាម្តេភាជាដ៏បវរ ។
ព្រះអង្គស្តេចធ្វើសឹកសង្គ្រាម ឈ្នះយួនភ្លាម១មិនកម្រ
យកបានមកវិញខែត្រមីថ វិញឡុងស្តេចក៏យកបានទៀត ។
ប៉ុន្តែកាលណោះវិបុលស្រី ចិត្តចោរអប្រិយចោលម្បៀត
ក្បត់ព្រះអង្គនន្ទគន់គិតឆ្វៀត ជ្រែកជ្រៀតបំណងរាជ្យសម្បត្តិ ។
ព្រះបាទអង្គនន្ទជ្រាបសេចក្តី ចាប់វិបុលស្រីមន្ត្រីក្បត់
ចិត្តប្រុស្តសាមាន្យក្លាហានក្លាត់ យកទៅបំបាត់ជន្មជីវិត ។
ក្រោយនោះមានកូនវិបុលស្រី ឈ្មោះបូរអប្រិយចោរទុច្ចរិត
បញ្ចុះបញ្ចូលជនឆ្ងាយជិត អោយរួមគំនិតធ្វើក្បួនទ័ព ។
ជាមួយវិបុលរាជឈ្មោះសូរ អត់កតញ្ញូតគេរាប់
ក្បត់ស្តេចអង្គនន្ទមានគុណគាប់ ត្រឡប់កសឹកសង្គ្រាមជ័យ ។
លើកទៅតតាំងច្បាំងនឹងស្តេច អង្គនន្ទរៀបស្រេចតវិញវៃ
ឈ្មោះបូរចិត្តខូចដូចមនុស្សព្រៃ ចាប់ស្តេចប្រពៃនាមអង្គនន្ទ ។
យកទៅជ្រមុជក្នុងទឹកបឹង តាមចិត្តក្រោធខឹងពុំអត់ធន់
ហេតុតែព្យេវេរាជាទម្ងន់ ព្រះបាទអង្គនន្ទព្រះជន្មក្ស័យ ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ ចិតប្រាំបួនក្រោយប្រែប្រួលក្រៃ
ប្រវត្តិសាស្ត្រជាតិមានបច្ច័យ ហេតុភេទចង្រៃមិនស្ងប់ស្ងាត់ ។

ក្រោយនោះឈ្មោះបូរតិតលៃលក ខ្លាចពុំហ៊ានយករាជ្យសម្បត្តិ
ទៅសោយខ្លួនឯងទើបថែងចាត់ លើកថ្វាយទៅក្សត្រនាមអង្គអេង ។
ព្រះជន្មប្រាំមួយព្រះវស្សា ជាតិជាខត្យាភក្ត្រាឈ្វេង
បុត្រព្រះឧទ័យរូបទន្ទេង ខ្លួនឈ្មោះបូរឯងធ្វើចៅហ្វាយ ។
នាយកមន្ត្រីថ្នាក់ផុតលេខ ថ្កើងពេកទីអគ្គមហាសេនា
ឈ្មោះបូរសម្រេចប្រើអាជ្ញា ដូចមហាក្សត្រាមូលផែនដី ។
សៀមទៀតក៏ឆ្លៀតបានឱកាស ដេរដាសលើកទ័ពសព្វសេនីយ៍
ចូលកម្ពុជារំពេចខ្មី សង្ឃឹមមានជ័យជាប្រាកដ ។
ប៉ុន្តែកាលនោះស្រុកសៀមថៃ មានគ្រោះចង្រៃភារារដ្ឋ
កើតចលាចលរាល់ជនបទ ហេតុព្រះចក្រពត្តិស្តេចផែនដី ។
ដាក់រាជ្យសម្បត្តិព្រះខិត្តយា មេទ័ពសេនាសង្គ្រាមជ័យ
គេចជាគ្រឡប់បវេណីវិញវៃ ចៅក្រុងបុរីព្វយុធ្យា ។
ផុតទុក្ខបានសុខនឹងសៀមហើយ ពិតពុំយូរឡើយកម្ពុជា
ជាតិខ្មែរនិងខ្មែរវិវាទគ្នា ត្បិតក្រុមភ្នាក់ងារជាពួកមន្ត្រី ។
តូចធំជំនុំមិនសុខចិត្ត ហេតុត្បិតឈ្មោះបូរចៅហ្វាយថ្មី
ជំឡើងបួកពេកពេញមេឃដី សុំយកមន្ត្រីពីដើមម្នាក់ ។
ឈ្មោះបែនដែលឈ្មោះបូរបណ្តេញ ឱ្យបែនដើរចេញទៅពឹងពាក់
នៅក្រុងបាងកកដកមកដាក់ ក្នុងក្រុងខេមរៈស្តីរាជការ ។
ឯចៅហ្វាយបែនក៏វិលមក តាមផ្លូវជើងគោកលើកសេនា
យោធាទាហានមានបរិវារ ច្រើនក្រៃអស្ចារ្យចូលមកច្បាំង ។
ចាប់ចៅហ្វាយបូរយកទៅកាប់ សម្លាប់ចោលអស់ពួកអាខ្នាំង
ព្រមឪពុកម្តាយអន្តរាយំ ទូទាំងញាតិមិត្តកូនប្រពន្ធ ។

វំពេងក្រោយមកពីរបីខែ ចៅហ្វាយបែនបែរជាមិនធន់  
ចាញ់គេម្តងវិញពេញទុរន់ ធុរៈទំងន់នៅពុំបាន ។  
ភៀសខ្លួនទៅពួនព្ទយុធ្យា នាំព្រះកុមារមហាក្សត្រក្សាន្ត  
អង្គអេងទៅផងប៉ងផ្ញើរប្រាណ សោយសុខសំរាន្តស្បើយទុក្ខា ។  
ចៅហ្វាយបែនក្រាបទូលស្តេចសៀម ខូចខុសទំនៀមពីដូនតា  
អោយអភិសេករាជកុមារ អង្គអេងក្សត្រាឯក្រុងស្យាម ។  
ធ្វើច្នោះខុសធ្ងន់ពន់ពេកណាស់ ព្រោះសៀមលោភក្រាស់ទីលែស្យកាម  
ទារគុណកំណត់គ្មានបទហាម ជាតិសៀមយួនចាមសឹងដូចគ្នា ។  
ព្រះបាទអង្គអេងជាស្តេចឯក បានរាជអភិសេកព្ទយុធ្យា  
មេទ័ពសៀមហែរព្រះរាជា ចូលមកភារាវាំងតំណាក់ ។  
គ្រិស្តស័កមួយពាន់ប្រាំពីររយ កៅសិបប្រាំក្រោយស្តេចខេមរៈ  
តបគុណសៀមវិញពេញរយៈ ចមចក្រីព្រះទានសបាត្តម្បង(បាត់ដំបង) ។  
ហើយនិងអង្គរអោយទៅសៀម ទំនៀមបែបនេះខុសកន្លង  
ខាងត្បូងយួនយកបន្តិចម្តង ខាងជើងសៀមឆ្លងយកច្រើនក្រៃ ។  
ទីម្តេពីរនគរខ្មែរ ភាន់ប្រែគ្មានឈប់ទាំងយប់ថ្ងៃ  
នៅក្រោមអំណាចយួនសៀមថៃ ឧប្បមែ៉នុប្បមា៉ដូចខ្លាធំ ។  
ព្យាឃីពីររូបប្រជែងគ្នា ដណ្តើមរំគាក្នុងព្រៃភ្នំ  
សាសន៍យួនឃើញសៀមបាននិគម យួនក៏និយមយកខ្លះដែរ ។  
ហើយឱ្យបានច្រើនជាងគ្នាផង បំណងសត្វខ្លាខ្លាំងពូកែ  
វំពាស៊ីសុខពីស្រុកខ្មែរ ប៉ុន្តែបើសាសន៍សៀមនិងយួន ។  
ស្អប់គ្នាយ៉ាងនេះក៏ស្រួលដែរ រវល់តែឈ្លោះគុំគង់គួន  
ដណ្តើមតាំងច្បាំងផ្ទួនៗ រៀងខ្លួនសម្រេចការពុំបាន ។

នគរខ្មែរក៏ពុំសាបសូន្យ គ្រាន់តែស្រពោនពុំក្លាហាន
គេរ៉ូឈ្មោះតមកចៅកសន្តាន គេពុំរាប់អានហានមើលឆ្ងាយ ។
គ្រិស្តស័កមួយពាន់ប្រាំពីររយ កៅប្រាំមួយក្រោយចុះនិយាយ
ប្រវត្តិសាស្ត្រសែខ្មែរមុននាយ ឡូលាយដំណឹងរបាក្សគ្រ ។
ដល់ព្រះអង្គអេងទីវង្គត រលត់ខ័ន្ធប្រាំកម្មវិបត្តិ
រាស្ត្ររាល់ភូមិស្រុកវិតុគក្កាត់ ចៅហ្វាប៉ុកចាត់ការរាជការ ។
តំណាងជួសតាំងស្តេចផែនដី ចក្រីអង្គអេងមានបុត្រា
ព្រះជន្មចំនួនបួនវស្សា ទ្រង់ព្រះនាមថាព្រះអង្គច័ន្ទ ។
ចៅហ្វាប៉ុកចាត់ការរាជការ ពូកែអស្ចារ្យឃ្លាតខ្មីខ្មាន់
ត្រួតត្រាភូមិភពគ្រប់ខេត្តខ័ណ្ឌ ប្រកាន់សុចរិតបីប្រការ ។
ប៉ុន្តែមកទាស់លោកមានខុស ពីព្រោះលោកចាត់ជាតិខេមរា
ទៅជួយច្បាំងសៀមចិត្តឫស្យា វាយមនប្រាថ្នាជ័យជំនះ ។
ចំណែកស្តេចយួនតាមវាំងអាន ដែបានធ្លាក់ពីបល្ល័ង្កព្រះ
ចៅផែនដីយួនជូនលោកម្ចាស់ ចៅហ្វាប៉ុកខ្នះខ្នែងជួយច្បាំង ។
ដណ្តើមយករាជ្យសម្បត្តិបាន ស្តេចយួនវាំងអានបានបល្ល័ង្ក
រាជ្យសោយដោយសារខ្មែរក្លាខ្លាំង ទៅជួយតតាំងទើបសម្រេច ។
សម្តេចចៅហ្វាប៉ុកសេដ្ឋា តែងការរាជការតំណាងស្តេច
រវាងដប់ឆ្នាំមិនចាំបាច់ អធិប្បាយដាច់ស្រេចយ៉ាងណាទេ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ប្រាំមួយគ្រាក្រោយគិតក្មេងខ្លែរ
លោកចៅហ្វាបែនជាបាមេ នាំព្រះខត្តយនាមអង្គច័ន្ទ ។
នៅឯបាងកកចូលក្រាបទូល កំពូលក្រុងចាមតាមកំណាន់
សុំឱ្យស្រោចទឹករាជសុវណ្ណ ព្រះបាទអង្គច័ន្ទសោយសម្បត្តិ ។

ក្រុងកម្ពុជាដែនដីខ្មែរ ស្តេចយួនងឿកង៉ែខ្វាល់ពេកក្តាត់
ប្រកាន់ថាខ្មែរកែបញ្ញត្តិ លួចធ្វើការស្ងាត់លាក់ដំណឹង ។
ស្តេចយួនគុំកួនលើកយោធា ម្ពីម្ពាចិត្តក្រោធប្រឡោតខឹង
បំណងវាយខ្មែរឱ្យខ្ទេចឆ្អឹង ធ្វើតាមកំហឹងចិត្តឫស្យា ។
កាលនោះសម្តេចព្រះអង្គច័ន្ទ វន្ទាន់ទ្រង់យាងយាសយាត្រា
ពីក្រុងបាងកកភិសា ត្រឡប់រដ្ឋាដល់ឧត្តុង្គ ។
ចាត់ព្រះរាជទូតអោយនាំសារ លិខិតសញ្ញាព្រះចក្រពង្ស
ទៅថ្វាយស្តេចយួនឆាប់ពុំលុង ថាទ្រង់សូមចងស្ពានមេត្រី ។
ស្មោះត្រង់ចំពោះនគរយួន សំនួនលេខាសារសេចក្តី
ថាទ្រង់នឹងនាំសួយអ្វីៗ ថ្វាយស្តេចដែនដីយួនរាល់ឆ្នាំ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ដប់បីគ្រាក្រោយជាគ្រោះកម្ម
រំចែករបោកទុក្ខសោកខ្លាំង ឃើញក្នុងបណ្តាំពង្សាវតារ ។
ថាសៀមញុះញង់ព្រះឧបរាជ ខ្មែរយើងឯងអាចកើតចលា
ចលក្នុងបុរីរាជរដ្ឋា ក្បត្រអង្គច័ន្ទមូលជីវិត ។
ស្តេចយាងទៅគង់នៅស្រុកយួន កូសាំងស៊ីនពួនយួនជួយគិត
ច្បាំងតទប់ទល់បច្ចាមិត្រ ឈ្នះស្រេចថ្វាយរិទ្ធិរាជ្យសម្បត្តិ ។
ទៅផ្ទះអង្គច័ន្ទសោយដដែល រក្សាដំណែលកេរ្តិ៍មហាក្សត្រ
ហើយយួនទុកទ័ពច្រើនពេកក្តាត់ ពីរម៉ឺននាក់ចាត់រក្សាអង្គ ។
ឯសៀមខឹងក្តាញ់ព្រោះចាញ់យួន គុំកួនថយទៅតាមផ្លូវត្រង់
យកខែត្រខ្មែរបីមិនលះបង់ បានដូចបំណងគឺស្ទឹងត្រែង ។
ទន្លេរពៅនិងម្លូព្រៃ សៀមបរាជ័យយួនឃើញស្តែង
បានខែត្របីដែរអញ្ចាញ់ឯង ខ្ញុំថ្លែងប៉ុណ្ណេះល្មមស្តាប់បាន ។

គ្រិស្តស័កមួយពាន់ប្រាំបីរយ សាមសិបពីរក្រោយប៉ូរីឋាន
សៀមលើកទ័ពធំពន់ប្រមាណ មេទ័ពចំណានបញ្ជាការ ។
នាមឈ្មោះបូឌិនជាស្ដេចសឹក ផ្ទួសថ្មីកចម្បាំងខ្លាំងក្លៀវក្លា
យោធាទាហានមានចេស្ដា អនុភាពអស្ចារ្យគ្រប់ដំណែង ។
សេនាបូឌិនមិនបង្អង់ លើកទ័ពចូលត្រង់ឥតកោតក្រែង
ចូលកម្ពុជាខ្មែរយើងឯង ស្ដេចស្ដែងអង្គច័ន្ទធន់ពុំបាន ។
ស្ដេចយាងទៅគង់ឯវិញឡុង ក្សត្រថ្លៃឧត្តុង្គតែងរាជសាន(រាជសារ)
ពឹងយួនឱ្យជួយតាមលំអាន ស្ដេចយួនក៏បានលើកយោធា ។
ចូលមកតតាំងច្បាំងនឹងសៀម កាប់ចាក់នឹងសៀមកាំបិតព្រា
ធ្នូស្នាច្បូកស្នរតយុទ្ធា សៀមរាចាញ់ដៃថយទៅវិញ ។
សៀមបរាជ័យកាលគ្រានោះ ខ្មែរយើងមានគ្រោះកើតទុក្ខម្ដេញ
នឹកឃើញខឹងយោពុះពោរពេញ ខាំសង្កៀតធ្មេញខឹងអស្ចារ្យ ។
សៀមចាប់អ្នកស្រុកច្រើនម៉ឺននាក់ នាំទៅតគ្រាក់គួរខ្លោចផ្សា
មុខទ័ពគ្រឡប់ដល់ទីណា ដុតផ្ទះខេមរាគ្មានប្រណី ។
ស្រុកភូមិពួកទ័ពជួបប្រទះ នៅទីណាខ្លះជនប្រុសស្រី
ចាប់ចងចោះសេកដោតដូចត្រី នាំទៅបុរីឰយុធ្យា ។
អត់ទឹកអត់បាយក្រហាយថ្លើម ស្លាប់ច្រើនសម្បើមតាមផ្លូវថ្លា
ព្រាត់ប្រាសកូនចៅយំហៅគ្នា កំព្រីកំព្រាច្រើនអនេក ។
សព្វថ្ងៃជាតិខ្មែរច្រើនមហិមា នៅឰយុធ្យាសៀមគេចែក
ភូមិស្រុកឱ្យនៅទៅដោយឡែក ចំណែកខេមរាឈ្លើយសៀមចាប់ ។
កាលយួនមានជ័យឈ្នះសៀមថៃ ក្រុងក្រៃស្រុកខ្មែរប្រែក្រឡាប់
នៅក្រោមអំណាចយួនពេញច្បាប់ យួនបានកណ្ដាប់ដៃពេញទី ។

ដាក់នគរខ្មែរអោយនៅក្នុង ទំនុកបំរុងអាណាម្ចី
ស្តេចយួនលើកខ្លួនស្មើគិរី រៀបចំធានីនគរខ្មែរ ។
ដាក់នាម៉ឺនយួនទ្រឿងមិញយ៉ាង ដំណាងរាជការមកនៅក្បែរ
ប្រពព្រះករុណាតាមក្រសែ ស្រុកខ្មែរយួនធ្វើប្លតិតតូរ៉ា ។
ត្រួតកិច្ចរាជការគ្រប់ក្រសួង ថ្វាយលួងតម្រូវតាមត្រូវការ
ក្រុងកម្ពុជារាជរដ្ឋា អាប់អោនអស្ចារ្យអង្វែងឆ្នាំ ។
រហូតដល់គ្រិស្តសករាជថ្មី មួយពាន់ប្រាំបីរយសែប្រាំ
ទាល់តុះចំណុះយួនអាណាម ជាតិខ្មែររងកម្មទុក្ខវេទនា ។
កាលយួនជីកព្រែកឈ្មោះវិញតេ តពីទន្លេស្ទឹងគង្គា
មាត់ជ្រូកបាសាក់ធ្លាក់ជលធារ ជាប់គ្នានឹងឈូងសមុទ្រសៀម ។
គ្រិស្តស័កមួយពាន់ប្រាំបួនរយ ដប់ប្រាំបីក្រោយខ្មែរក្រំក្រៀម
អត់ឃ្លានវេទនាជាទំនៀម ជិនជៀមដល់ជាតិជនខេមរា ។
ជាន់នោះលំបាកយ៉ាកអស្ចារ្យ នរណាក៏ដឹងដំណឹងជាក់
ចាស់ៗតំណាលកាលនោះហាក់ ជាតិយើងដូចធ្លាក់បង្គន់អាចម៍ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ដប់ប្រាំពីរដោយភ្លៀងមិនដាច់
ជន់ធំក្រៃលែងលិចខុសខ្យាច់ លិចស្រូវស្ទូងស្រេចអស់ទាំងស្រែ ។
រលួយស្លឹកគ្រួយផលដំណាំ រងកម្មស្រេកឃ្លានឥតមានល្ហែ
នៅស្រុកក្រៅទៀតជនជាតិខ្មែរ ដើរតែចាក់កាប់សម្លាប់គ្នា ។
ប្លន់ដណ្តើមស្បៀងលៀងជីវិត ប្រព្រឹត្តអំពើធ្វើបំពារ
បញ្ចតិសណ្តាប់ធ្នាប់ភារា សម្រាប់នានាប្រទេសជាតិ ។
ទទួលជំងឺឈឺតម្កាត់ កើតមានច្រើនក្តាត់រោគាពាធ
អាកាសមិនស្រួលកំសួលធាតុ កើតអាហិវាតរោគផង ។

ស្លាប់ជនជាតិខ្មែរក្នុងបុរី ទាំងប្រុសទាំងស្រីច្រើនកន្លង
ឈឺឈ្លួលរមួលពោះជាខ្លង រោគឆ្លងនេះចាប់ស្លាប់រហ័ស ។
នៅក្នុងរាជស្តេចព្រះអង្គច័ន្ទ មានយួនប្រាំពាន់ខ្មែរក្មេងចាស់
ប្រាំពាន់ស្មើគ្នាវេរាក្រាស់ ជីកព្រែកមួយច្បាស់ឈ្មោះវិញតេ ។
ដូចខ្ញុំបានថ្លែងពីខាងលើ អំពីយួនប្រើស្មើខ្ញុំគេ
ខ្ញុំពុំហ៊ានថ្លែងឱ្យវែងទេ បុព្វខ្មែរអន់ក្នុងជាន់នោះ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ សាមសិបបីក្រោយក្សត្រទ្រង់យស
អង្គច័ន្ទសុវណ្ណកោដិសំពោះ ខ្មែរយើងរលោះថយចំនួន ។
ទីម្ភៃបី សេចក្តីថ្លែង សំដែងពណ៌នាឃ្លោងឃ្លាបួន
អង្គច័ន្ទស្តេចខ្មែរដែលពឹងយួន គាប់ជួនទ្រង់គ្មានរាជបុត្រា ។
ចក្រពានស្តេចមានតែបុត្រី មួយឈ្មោះអង្គម៉ីរាជធីតា
បើនឹងផ្ទេររាជព្រះករុណា ចំពោះទៅអានុជព្រះអង្គ ។
នាមព្រះអង្គឌួងក៏សឹងបាន ត្រូវតាមលំអានព្រះបំណង
តែនាម៉ឺនយួនគួនគិតចង់ ស្មោះត្រង់នឹងស្តេចព្រះអង្គឌួង ។
ទើបទ្រឿងមិញយ៉ាងចាងហ្វាងធំ ប្រក់ព្រំរាជកិច្ចការទាំងពួង
ប្រួតិតតូវ៉ាត្រួតលើល្បួង ត្រូវមុខក្រសួងគេដាច់ខាត ។
ក៏តាំងបង្គាប់លោកកុង្សី សេនាបតីយោធាមាត្យ
ឱ្យថ្វាយរាជ្យទៅក្រោមល្អងបាទ ព្រះនាមនោមស្អាតនាមអង្គម៉ី ។
ជារាជបុត្រព្រះអង្គច័ន្ទ រូបល្អសំខាន់ផុតផែនដី
សម្តេចព្រះនាងកល្យាណី ក្សត្រីឡើងសោយរាជ្យសម្បត្តិ ។
កាលក្នុងរាជ្យនេះកម្ពុជា ឫកពាជាតិសាសន៍វិនាសបាត់
នាម៉ឺនមន្ត្រីព្រះមហាក្សត្រ ទ្រឿងមិញយ៉ាងចាត់ប្រតិបត្តិតាម ។

ត្រូវអោយតែងតួប្រដាប់ខ្លួន បួងសក់ដូចយួនជាបម្រាម
បម្រុងជឿស្តាប់ច្បាប់យួនហាម ប្រាប់ប្រាមប្រដៅជាអ្នកស្រែ ។
ខែត្រមួយអោយមាននាម៉ឺនយួន ម្នាក់នៅថែធួនត្រួតបន្ថែម
លើចៅហ្វាយស្រុកជនជាតិខ្មែរ ហូរហែជវាបតាមចំនួន ។
មួយទៀតអោយខ្មែរថែរក្សា ចិញ្ចឹមអាហារទាហានយួន
ដែលនៅការពារប្រទេសខ្លួន គ្រប់ទិសទាំងបួនផងទៀតដែរ ។
ក្នុងរាជ្យសម្តេចព្រះក្សត្រី អង្គមុនីផែនដីនគរខ្មែរ
ខាងត្បូងយួនខូងយកដីស្រែ ចំការរាល់ខែឆ្នាំតិចម្តង ។
ខ្មែររត់ចោលស្រែចោលភូមិស្រុក អុកឡុករំជួលជ្រួលកឹកកង
ខ្លាចយួនចាក់កាប់ដេញចាប់ចង ភូមិស្រែខ្មែរផងបានយួនអស់ ។
កាលយួនក្រញីបរិបជាន់ខ្លាំង ខ្មែរគ្មានតតាំងថាអ្វីសោះ
ខឹងណាស់កើតទុក្ខមុខក្រៀមក្រោះ ឃើញក្តីទំនាស់កើតបះបោរ ។
ឯនាម៉ឺនយួនទ្រៀងមិញយ៉ាង ចាប់ហេតុភស្តុតាងខ្មែរអោឡោ
ទ្រៀងមិញខឹងឃោរកើតទោសោ ចិត្តខូចដូចចោរកាចឫស្យា ។
បានប្រកាសតាមចាប់ក្សត្រី សម្តេចអង្គម៉ីរាជធីតា
យកទៅឃុំទុកថែរក្សា នៅស្រុកមួយជាទីក្រុងវេរ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ សែសិបមួយក្រោយក្រិះរេ
ក្សត្រីអង្គម៉ីកម្មបុព្វេ ត្រូវទ្រៀងមិញគេចាប់ទៅឃុំ ។
កន្លងប្រាំឆ្នាំកម្ពុជា ពឹងសៀមការពារស្រុកនិគម
គ្មានស្តេចផែនដីបុរីរុំ យួនទៅប្រកព្រំធ្វើបាបខ្មែរ ។
ខ្លាំងឡើងៗគ្រប់តំបន់ អ្នកស្រុកក៏អន់ចិត្តណាស់ដែរ
មានថ្ងៃមួយគាប់លោស្រាប់តែ ជាតិខ្មែរបះឡើងពេញបូរី ។

នៅក្នុងគម្រោងពីរអាទិត្យ     សម្លាប់ជីវិតយួនប្រុសស្រី
ទាំងតូចទាំងធំប៉ុន្មានក្តី     ទាំងកូនប្រុសស្រីក្នុងអង្រឹង ។
ក៏ខ្មែរចាក់កាប់សម្លាប់អស់     គ្មានសល់មួយសោះយួនស្វាត់ឈឹង
ទោះទាំងកូនខ្ចីបីទទឹង     ក៏ខ្មែរវ៉ៃផតភឹងបីកំណាត់ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ     សែប្រាំមួយក្រោយយួនខឹងក្តាត់
លើកពលយោធាជាសង្កាត់     ចូលមកបំបាត់ចលាចល ។
ចំណែកខាងខ្មែរពឹងសៀមជួយ     មិនសូវភ័យព្រួយទុក្ខកង្វល់
ស្តេចសៀមប្រាប់ច្បាស់ព្រះយោបល់     ព្រះឱង្ការផ្ទាល់លោកមេទ័ព ។
នាមឈ្មោះមូឌីនពីនតេជះ     ហែរព្រះអង្គឌួងវិលត្រឡប់
មកកម្ពុជាយោធាដាប់     ម៉ឺនពាន់រសរាប់រៀបពុំបាន ។
ខ្មែរឃើញទ័ពសៀមច្រើនអនេក     ស្មោះសរក្រៃពេកពន់ប្រមាណ
បូឌីនស្តេចសឹកថ្នឹកចំណាន     ឱ្យពលវាយប្រានទ័ពយួនចេញ ។
ទ័ពយួនដឹងខ្លួនថាមិនធា     មេទ័ពរាមាឈ្មោះទ្រឿងមិញ
នាំទ័ពត្រឡប់ទៅស្រុកវិញ     ទ័ពសៀមនៅពេញនគរខ្មែរ ។
ឡេទ័ពបូឌីនពីនតេជះ     ប្រកាសរៀបចំតាមក្រសែ
លើកព្រះអង្គឌួងដាក់ដង្ហែរ     ជាស្តេចស្រុកខ្មែរកម្ពុជា ។
សោយរាជ្យសម្បត្តិក្នុងបុរី     គ្រប់គ្រងផែនដីដែនភារា
ព្រះអង្គឌួងព្រមល្មមទ័យា     ក្សត្រថ្លៃសោភាឥតប្រកែក ។
ទីម្តេបួនសួនសេចក្តី     ភារណៈបូរីខ្មែរបែកបាក់
កំសត់ទុរគតគ្រប់ចំណែក     ប្លែកៗលើសលប់ពីមុនមក ។
ដោយហេតុសៀមចាប់រាស្ត្រប្រដៅ     នាំទៅស្រុកវាច្រើនអនេក
ស្លាប់គ្រាចម្បាំងខ្លាំងក្នុងលោក     ដូចយើងយល់យោគមកហើយវា ។

ស្លាប់នឹងជំងឺផងទាំងឡាយ ស្លាប់នឹងអត់បាយច្រើនអស្ចារ្យ
ខាងជើងឧត្តុង្គក្រុងសីមា ខ្មែរយើងខ្លោចផ្សាពន់ប្រមាណ ។
ឃើញសុទ្ធតែជីសស្អាត ស្ងាត់ស្ងួនឡូហួសខ្នាតដូចស្មសាន
ឥតមនុស្សម្នាក់នៅក្នុងភូមិឋាន រអាពុំហ៊ានធ្វើស្រែស្រូវ ។
បុកធ្វើចំការច្បារជំណាំ ភ្នួរាស់ដាំពោតរពៅ
គ្រប់គ្រាវបន្លែបែរមើលទៅ ភូមិគ្មានមនុស្សនៅដីទំនេរ ។
ព្រោះខ្លាចសៀមយួនគួនផ្ដន្ទា បំពានបំពារតាមចិត្តគេ
ប្រូតយកគ្រាប់ស្រូវទៅទទេ យួនសៀមជាមេសត្រូវធំ ។
ជំណាំស៊ីផ្លែក្នុងភូមិឋាន ទាំងអម្បាលមាណវាវិលំ
បេះយកផលផីទាំងខ្ចីទុំ កាប់ចោលទាំងគុម្ពពុំមានសល់ ។
ទោះទាំងទីវត្តអារាមក្ដី យួនសៀមអប្រិយចិត្តកំហល់
កំហែងយកទ្រព្យគេតម្កល់ វេប្រគេនផ្ទាល់ចំពោះសង្ឃ ។
ទ្រព្យគរុភ័ណ្ឌសម្រាប់វត្ត សត្រូវមិនអត់បំផ្លាញបង់
ជញ្ជូនយកអស់តាមចំណង់ គ្មានកោតខ្លាចគ្រង់ត្រូវទោសា ។
រុះរើយកអស់គ្មានសល់អ្វី គម្ពីរបាលីច្បាប់សាសនា
ដុតចោលវិហារកុដិសាលា វត្តលោកខេមរាគ្រប់កន្លែង ។
ឯបណ្ដាឋានក្នុងបុរី ទាំងប្រុសទាំងស្រីយើងឃើញស្ដែង
កាន់តែតិចតួចស្ដួចស្ដើងឯង រីឯទុក្ខអង្វែងយូរឆ្នាំណាស់ ។
តាំងតែអំពីកាលណាមក ទុក្ខសោកពុំសូវជួបប្រទះ
កាលណោះខ្មែរចាំហៅកម្មក្រាស់ វេទនាឃើញច្បាស់ពិតប្រាកដ ។
ព្រះបាទអង្គឌួងម្ចាស់សិរសី ចក្រីថ្វាយរាជ្យកម្ពុជរដ្ឋ
ព្រះទ័យសប្បុរសស្មោះទៀងទាត់ ឆ្លាតវៃអំណត់គ្រប់ប្រការ ។

ស្ដេចបរិច្ចាគទានដល់ព្រះសង្ឃ លះបង់រាជទ្រព្យគាប់ចិន្ដា
ទ្រង់ព្រះរាជទានដល់បណ្ដា ជនណាទុរគតខ្សត់អត់ឃ្លាន ។
ឈ្វេងយល់សុខទុក្ខរាស្ដ្រប្រជា សម្បត្តិវេទនាប្រោសប្រទាន
ច្រើនក្រៃពន់ពេកទ្រព្យធនធាន ទ្រង់មានវង្វេងស្រព្រះចិន្ដា ។
ដោយហេតុសង្គ្រោះមិនគ្រាន់គ្រប់ ភូមិសព្វខេត្តខ័ណ្ឌពានសីមា
ម្យ៉ាងទៀតគ្រានោះព្រះចក្រវាឡ តម្រិះយល់ថាក្រក្រៃគិត ។
ព្រោះសៀមវាលើកព្រះទ័យយស អោយសោយរាជ្យនោះក៏មែនពិត
ប៉ុន្តែវាទូលព្រះទ្រង់បុរី ស័ក្តសិទ្ធិដល់គ្រប់ប្រាំមួយឆ្នាំ ។
ទើបសៀមថ្វាយរាជ្យនោះអោយស៊ុប ចក្រភពទ្រង់គិតពិនិត្យចាំ
បែបបទទំនៀមសៀមសាំញ៉ាំ រកាំចិន្ដាសត្យាវង្ស ។
នៅវេលានោះសៀមនិងយួន គុំកួនរកគ្នាជាយូរលង់
មហាសត្រូវទ្រើសទ្រនង់ ពើតពង់អាងរិទ្ធិដោយរៀងខ្លួន ។
ចូលមកច្បាំងគ្នាក្នុងស្រុកខ្មែរ ជាយូរឆ្នាំខែសៀមឈ្នះយួន
តែថាមិនទៀងទាត់មាំមួន ជួនសៀមចាញ់យួនក៏មានដែរ ។
មហាសត្រូវកាចអប្រិយ៍ លុកលុយបុរីនគរខ្មែរ
ជាតិយើងរងកម្ទេចរាល់ឆ្នាំខែ ស្ទើរតែបាត់ឈ្មោះព្រោះចម្បាំង ។
ក្រោយមកមេទ័ពគូរសត្រូវ ធន់ទ្រាំពុំសូវក្លៀវក្លាខ្លាំង
ឈប់ប្រកួតអួតប្រណាំង ហាក់អង់កម្លាំងរៀងៗខ្លួន ។
ព្រមចងចំណងស្ពានមេត្រី នឹងគ្នាជាថ្មីសៀមនិងយួន
នៅក្រុងបាងកកបករកក្បួន លិខិតសំនួន ៩ សញ្ញា ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ សែប្រាំមួយក្រោយហត្ថលេខា
យួនចុះសញ្ញាបញ្ជាក់ថា ព្រមលើកក្សត្រាព្រះអង្គឌួង ។

ជាស្តេចនគរកម្ពុជា ឥតមានរាំងរាអស់ការទាំងពួង
យួនសៀមទំនៀមរបស់លួង មិនត្រូវហែកហួងធ្វើជំរាប ។
យួនថាព្រមបើករាជក្សត្រី អង្គម៉ីព្រះវង្សលួងទាំងអស់
ដែលយកទៅឃុំទីចន្លោះ កៀនកោះកំឡុងក្នុងស្រុកវេរ ។
អោយយាងគ្រឡប់វិលបុរី ស្រុកខ្មែរវិញខ្មី....
លិខិតសំនួនយួនសរសេរ សញ្ញាត្រេតេកុងវង់ស្យង់ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ សែប្រាំមួយក្រោយក្សត្រឧត្តុង្គ
ព្រះបាទអង្គឌួងលួងចក្រពង្ស ស្តេចទ្រង់បានរាជាភិសេក ។
នៅចំពោះមុខនាម៉ឺនយួន និងសៀមថែមធូនធំប្លែកៗ
ស្តេចសៀមស្តេចយួនពីរអង្គឯក ថ្កើងឫកអនេកសម័យនោះ ។
គេតាំងខ្លួនធ្វើជាឪពុកម្តាយ លួងខ្មែរស្រុកអាយពិតចំពោះ
សៀមថាដោយការគេសង្គ្រោះ ត្រូវក្សត្រទ្រង់យសប្រគល់ដី ។
ទន្លេរពៅបាត់ដំបង ម្លូព្រៃមួយផងត្រូវជាបី
អោយសៀមទំនៀមដូច្នេះខ្មី ចក្រីអង្គឌួងម្ចាស់ជីវិត ។
ស្តេចពុំព្រមឡាយព្រះហត្ថា មានព្រះឱង្ការតាមការពិត
ថាខ្ញុំមិនអោយឥតគំនិត អ្វីៗសៀមគិតលោភចង់បាន ។
សៀមគួរទុកជារបស់ខ្លួន ចំនួនទឹកដីស្រុកភូមិឋាន
ដែលយកពីមុនទាំងប៉ុន្មាន លំអានដូចសៀម...ស្រាប់ ។
ចំណែកខាងត្បូងយួនធ្វើបាប ខ្មែរជាដរាបវាយចាក់កាប់
តាមតែអំពើធ្វើខុសច្បាប់ ខ្មែរយើងខ្លាចស្លាប់រត់ចោលស្រុក ។
ចោលស្រែចំការច្បារដំណាំ រងកម្មវេទនានៅពុំសុខ
យួនក្រោមយួនលើធ្វើអុកឡុក ខ្មែររត់ចោលស្រុកយួនយកស្រែ ។

យកដូងយកស្លាធ្យារជំណាំ ដៃដាំផ្កាហើយនឿយតែថៃ
ច្រូតកាត់យកផលដល់ខួបខែ របស់ជាតិខ្មែរទាំងប៉ុន្មាន ។
ទីម្តៃប្រាំព្រះអង្គឌួង ឈ្វេងហេតុទាំងពួងទៅអវសាន
ត្បិតសៀមនិងយួនគួនចង់បាន ទឹកដីភូមិឋានកម្ពុជា ។
គិតវាយចំណែកចែកគ្នាឯង ស្តេចស្វែងទ្រង់ព្រួយព្រះទ័យា
ទ្រង់ព្រះតម្រិះគិតដកឃ្លា ពីមារសត្រូវទាំងពីរនាក់ ។
ដែលអះអាងជាអ្នកទំនុក បម្រុងទៅមុខជាតិខេមរៈ
ឈ្វេងស្រេចពុំលង់ព្រះទ្រង់លក្ខណ៍ យាងហប្ញទ័យស្ម័គ្រជឿលោកមិស ។
ជាតិបារាំងសែសដែលគេនៅ ជាអ្នកប្រដៅសាសនាគ្រិស្ត
ក្នុងកម្ពុជាវេលានេះ ទ្រង់ព្រះតម្រិះសម្រេចថា ។
នឹងដាក់នគរអោយនៅក្នុង ទំនុកបម្រុងប្រូតិកតូរ៉ា
បារាំងសែសចុះទោះយ៉ាងណា ពីនោះរាជការស្រុកបារាំង ។
កំពុងល្បីឈ្មោះខ្ពស់សំភារ នៅចុងបូព៌ាពេញកម្លាំង
ពីព្រោះទើបតែជួយតតាំង ស្តេចយួនឈ្មោះយ៉ាឡុង ។
អោយបានឡើងសោយរាជ្យសម្បត្តិ ប្រពៃពេកក្តាត់កិច្ចបម្រុង
ស្តេចយួនសុខខ្លួនត្បិតនៅក្នុង ទំនុកបម្រុងបារាំងដែរ ។
ក្សត្រថ្លៃអង្គឌួងលួងអម្ចាស់ ឆ្លាតវៃរហ័សប្រាជ្ញពូកែ
អោយតែងរាជសារតាមក្រសែ ចាត់នាម៉ឺនខ្មែររីកុង្សី ។
ម្នាក់ជារាជទូតអោយនាំសារ ឡាយព្រះហត្ថាព្រះចក្រី
ទៅអោយនាម៉ឺនមុខមន្ត្រី អ៊ីរ៉ុបឈរស្តីធ្វើរាជការ ។
កុងស៊ុលបារាំងសាំងកាពួរ សមគួថាទ្រង់ព្រះករុណា
សូមយកបារាំងធ្លាយឃាំងខា រក្សាទឹកដីបុរីស្ថាន ។

| | |
|---|---|
| គ្រិស្តស័កមួយពាន់ប្រាំបីរយ | ហាសិបប្អូនក្រោយដោយលំអាន |
| កាលស្តេចបារាំងខ្លាំងក្លាហាន | រាមាគេបានសំដីមក ។ |
| ណាប៉ូឡេអុងស្តេចទីពា | ចក្រីពិនិត្យគិតលៃលក |
| ទតឃើញរាជសារចិន្តាភ្នក | រិះរកចាត់ប្រើបារាំងម្នាក់ ។ |
| ឈ្មោះថាលោកដឺម៉ុងទីញ៉ី | ចរលីមកធ្វើកិច្ចការវៈ |
| ក្រាបថ្វាយបង្គំនិយមស្ម័គ្រ | ស្តេចជាតិខេមរៈនាមអង្គឌួង ។ |
| បារាំងឈ្មោះដឺម៉ុងទីញ៉ី | វន្ទីក្រាបថ្វាយបង្គំលួង |
| ទទួលបន្ទុកមុខក្រសួង | កិច្ចការទាំងពួងស្តេចបារាំង ។ |
| ចេញពីអឺរ៉ុបតាមកប៉ាល់ | នាវាដង្ហាល់ឆ័ត្រឆក់ផ្លាំង |
| អំណាចទឹកពុះសន្ទុះខ្លាំង | រលកខ្ទប់ប្រាំងជ្រោយសាគរ ។ |
| មកដល់ស្រុកខ្មែរក្នុងខែអ៊ីត | ស្រូតរូតថ្ងៃយប់គ្មានឈប់ឈរ |
| ដល់កំពតពិតចិត្តសាទរ | ទីញ៉ីរឡើងរកផ្ទះសំណាក់ ។ |
| គ្រិស្តស័កមួយពាន់ប្រាំបីរយ | ហាប្រាំមួយក្រោយបែបស្ទើរស្ទាក់ |
| ពុំបានជួបធ្វើរាជការវៈ | ផ្ទាល់មានលាយលក្ខណ៍ព្រះអង្គឌួង ។ |
| សញ្ញាគ្រែតែក៏មានធ្វើ | មកឥតអំពើខាតលុយលួង |
| អាក់ខានអវិជ្ជាការទាំងពួង | កិច្ចមុខក្រសួងមិនសម្រេច ។ |
| គ្រិស្តស័កមួយពាន់ប្រាំបីរយ | ហាសិបពីរក្រោយក្នុងរាជស្តេច |
| អង្គឌួងស្រាប់តែប្រែក្រឡាច់ | ស្រុកមិនស្រួលស្រេចចលាចល ។ |
| ចាមជ្វាដែលនៅខេត្តត្បូងឃ្មុំ | បះបោរប្រជុំកោលាហល |
| កធ្វើកងទ័ពសព្វកង្វល់ | រករឿងផ្តួលផ្ទាល់ព្រះចេស្តា ។ |
| ពុំព្រមចំណុះព្រះអង្គឌួង | ប្រកាន់ថាលួងជាតិខេមរា |
| ជ្វាពុំព្រមស្តាប់ព្រះឱង្ការ | ព្រះរាជអាជ្ញាស្តេចផែនដី ។ |

ព្រមស្តាប់តែនាយចៅហ្វាយវា ជាតិផ្ទានឹងផ្ទាទាំងប្រុសស្រី
តែមួយពុំអោយមានពីរបី ចាមផ្ទាអប្រិយក្បត់លួងខ្មែរ ។
ធ្វើទ័ពតតាំងច្បាំងនឹងស្តេច ប្តូរផ្តាច់អួតអាងខ្លាំងពូកែ
ទ័ពផ្ទាមនុស្សច្រើនណាស់ដែរ ប៉ុន្តែធន់អត់អំណត់ណាស់ ។
ទ័ពព្រះអង្គខ្ទង់លួងជាតិខ្មែរ ក្លាហានពូកែប្រែក្រឡះ
វាយកាត់ទទឹងឆាប់រហ័ស ផ្ទាស្លាប់ក្រៃក្រាស់ធន់ពុំបាន ។
បរាជ័យចាញ់ព្រះចេស្តា ឆ្លេឆ្លាដកទ័ពត្រឡប់ឋាន
រត់ទៅពឹងយួនលាក់ខ្លួនប្រាណ នៅក្បែរនាឋានខេត្តមាត់ជ្រូក ។
ចងស្ពានមេត្រីនឹងជាតិយួន កែខ្លួនខ្លះពួននៅក្នុងទូក
ខ្លាចខ្មែរកាប់ចាក់ពាក់ពន្លូក យកយួនជាពួកបនពំនាក់ ។
ទ័ពខ្មែរតាមក្រោយបណ្តោយកិត ដេញផិតបំណងប៉ងចូលចាក់
ទ័ពចូ... រួចដាក់ យួនជួយវាយស្ទាក់មុខទ័ពខ្មែរ ។
ទ័ពខ្មែរប្រែជាអន់ជោគជ័យ ថយក្រោយវិញវៃបាញ់បន់តែ
យួនផ្ទាទ័ពវាខ្លាំងពូកែ គ្រាន់បើណាស់ដែរពួកមហាមិត្ត ។
កាលផ្ទាបះបោរចោរសាមាន ស្តេចបង្ក្រាបបានប្រែស្ងប់ស្ងាត់
ឆ្នាំដែលអង្គខ្ទង់លួងជីវី មហាក្សត្រស្តេចសោយរិលាល័យ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហាក្រាំបួនក្រោយដោយប្រពៃ
មរណកាលកម្មប្រចាំវ័យ ព្រះបាទ ជ័យវលត់ខ័ន្ធ ។
ព្រះបាទអង្គខ្ទង់លួងទ្រង់ជោគ ប្រសើរក្នុងលោកដូចដួងច័ន្ទ
រស្មីចាំងចែងសែងសុវណ្ណ ស្តេចកាន់សុចរិតទស្សពិតធមិ ។
មានកិត្តិនាមប្រសើរណាស់ ជ្រៅជ្រះ យោបល់
ព្រះទ័យសប្បុរសឈ្មោះតម្កល់ សីលទានមគ្គផលជាប្រក្រតី ។

| | |
|---|---|
| ករុណាមេត្តាប្រោស | សន្តោសរាប់អានរាស្ត្រមន្ត្រី |
| ទំនុកបម្រុងក្នុងបុរី | ដើម្បីភាពវឌ្ឍនាការ ។ |
| ចំរើនសេរីសេចក្តីសុខ | ក្នុងស្រុកខេត្តខ័ណ្ឌ... |
| .... បញ្ញា | ពិសម្ភារាប្រពៃណាស់ ។ |
| រាល់ថ្ងៃព្រះអង្គព្រះរាជទាន | ចែកទ្រព្យធនធានច្រើនក្រៃក្រាស់ |
| ក្នុងព្រះរាជវាំងទាំងក្មេងចាស់ | ស្រីប្រុសចំណាស់អោយអ្នកក្រីក្រ ។ |
| ជាគ្រឿងស្លៀកពាក់សំពត់អាវ | សខ្មៅអាហារបាយសម្ល |
| មាសប្រាក់តាមថ្នាក់អាក្រក់ល្អ | ព្រះទ័យស្មោះសសាងបុញ្ញកម្ម ។ |
| សម្តេចចមពង្សព្រះទ្រង់លក្ខណ៍ | បន្ថយការប្រាក់ដាក់បញ្ចូល |
| មួយរយរៀលដើមក្នុងមួយឆ្នាំ | ព្រះរាជបណ្តាំប្រាក់ចំការ ។ |
| ត្រឹមសាមសិបរៀលទីបំផុត | សំរុតចុះមកតាមសញ្ញា |
| មិនត្រូវយកលើសច្បាប់មាត្រា | បំពានអាជ្ញាស្តេចរឹបជាន់ ។ |
| ក្នុងបុរីរកគ្រលំបាក | គោកយ៉ាកគ្រប់ទីគ្រប់តំបន់ |
| គង់តែស្តេចជ្រៀតឆ្មៀតគ្នេគ្នន់ | ធ្វើចំរើនទាន់ពេលវេលា ។ |
| ទ្រង់អោយធ្វើផ្លូវពីឧត្តុង្គ | ទៅក្រុងកំពតឆ្លងកាត់ភ្នា |
| ទល់ល្បែងសមុទ្រសុទ្ធដល់ជា | គង្គាប្រជារស់ទឹកប្រៃ ។ |
| ហេតុនេះកំពតកំពង់បាយ | ឡើងភ្នំកំចាយខ្ពស់ស្កឹមស្កៃ |
| ឡើងជាកំពង់មួយល្អក្រៃ | នាវាប៉ុកចៃទូកសមុទ្រ ។ |
| ដឹកនាំទំនិញចេញចូលបាន | មិនបាច់រំខានព្រួយតក់ស្លុត |
| បង់គយយូនព័ន្ធធ្ងន់បំផុត | ដើងគោកសោធសុទ្ធមានផ្លូវក្លា ។ |
| ក្សត្រថ្លៃអង្គឌួងល្អងផុតផ្គង់ | ទំនុកបម្រុងផ្លូវវេទ្យា |
| សាស្ត្រ... | អោយរៀនរាល់គ្នាក្នុងបុរី ។ |

ក្រសួងធំ១គ្រប់តំណែង ស្តេចស្តែងចាត់ចែងរើសជាថ្មី
មនុស្សមានគម្រិះចេះគប្បី តាំងជាមន្ត្រីឧត្តមសក្តិ ។
ម្យ៉ាងទៀតលួងមាសបានខ្លះខ្វែង ចាត់ចែងរើសអោយធ្វើប្រាក់
សម្រាប់ចាយវាយងាយទុកដាក់ ក្នុងបុរីរក្សារាជរដ្ឋា ។
១ ព្រះអង្គឌួងលួងសាងវត្ត មាននាមសម្បត្តិជាសញ្ញា
អោយពុទ្ធបរិស័ទអារាម្មា ២ ព្រះវិហារវត្តសំណរ ។
៣ ព្រះវិហារសាលាគួរ ហោជាងគំនូរទឹកមាសល្អ
៤ សាងចេតីយកំបោរថ្ម មួយខាងឧត្តរទីវត្តប្រាង ។
៥ សាងថ្នល់ពីកំពង់លួង ហើយព្រះអង្គឌួងស្តេចបានសាង
សាលាដំណាក់ល្អអស់យ៉ាង ជីកស្រះមួយខាងប្របផ្លូវថ្នល់ ។
ផ្លូវនោះចុះទៅទីឧត្តុង្គ វាំងចាស់បម្រុងព្រះយោបល់
កម្មសទ្ធាជាកុសល ឧទ្ទិសទានដល់អ្នកដំណើរ ។
៦ បង្កើតទ្វារទសមាស ប្រាំបីឱកាសយ៉ាងប្រសើរ
៧ ព្រះអង្គទ្រង់ត្រាស់ប្រើ ព្រះរាជដំណើរអោយប្រែច្បាប់ ។
របៀបរៀបចំក្រមបំណុល ខ្ទីបុលយកការតាមលំដាប់
ដូចថ្លែងមកហើយខាងលើស្រាប់ សេចក្តីសារស័ព្ទយ៉ាងពិស្តារ ។
៨ ស្តេចបាននិមន្តសង្ឃ ពីរអង្គជាតិជាបណ្ឌិតា
ចេះចប់គម្ពីរពុទ្ធសាសនា ជាធម្មាចារ្យសង្ឃទាំងឡាយ ។
គឺព្រះសុគន្ធាធិបតី នាមប៉ាន់ចេះល្បីដែនដីអាយ
គណៈធម្មយុត្តិមុតប្រាជ្ញប្រាយ ជានយោបាយសង្ឃសព្វស្ថាន ។
មកគង់នៅវត្តសាលាគួរ ជាគ្រូលើសង្ឃទាំងប៉ុន្មាន
ព្រះរាជវង្សានុវង្សាណា រាប់អានគោរពគ្រប់១គ្នា ។

សម្តេចសង្ឃរាជនាមទៀងពិត ជាតិជាបណ្ឌិតចេះវិទ្យា
ប្រសើរអង់អាចប្រាជ្ញមេធ្វា ទ្រង់ជាធម្មាចារ្យលើសង្ឃ ។
កុលបុត្របំផុតដែនដីរាយ ក្រុមមហានិកាយពួកច្រើនអង្គ
វក្សាសីលបួនសួនស្លូតត្រង់ លះបង់បាបធម៌ប្រាំប្រការ ។
អោយគង់នៅក្នុងទីវត្តប្រាង ដែលស្តេចបានសាងថ្វាយសាសនា
នាយកលើសង្ឃក្នុងរដ្ឋា ព្រះមហាក្សត្រាជឿផលកម្ម ។
ផលកើតកំណើតក្នុងលោកា បុណ្យបាបសាសនានៅប្រចាំ
ហាក់ដូចស្រមោលចោលឆ្ងេងស្តាំ ទ្រង់កត់ចំណាំពាក្យឧបមា ។
ក្រោយទីវង្គតរលត់ខ័ន្ធ ព្រះបាទដួងច័ន្ទម្ចាស់សញ្ញា
លួងបម្រុងកោដិកប់ចេស្តា មានបុណ្យអស្ចារ្យពន់ប្រមាណ ។
ទីក្រុងឧត្តុង្គមានជោគជ័យ អាស៊ីទ្វីបលោកសព្វភូមិស្ថាន
ស្ញែត្រស្មោះស្រឡាញ់ពេញរាប់អាន ពុំមានសល់ខានកន្លែងណា ។
សាវតារប្រវត្តិទី ២០ ប្រាំមួយសោតនៃមហាក្សត្រា
អង្គខ្ចងលួងមានរាជបុត្រា ច្បងព្រះនាមថាព្រះអង្គម្ចាស់ ។
រាជាវត្តីសីវិល្ឃ រកថ្វាយរាជតំណព្រះវង្សសាស្ត្រ
ស្នងព្រះបិតាបារមីត្រាស់ មានជ័យជំនះគ្រប់ប្រការ ។
ព្រះជន្មម្ភៃប្រាំមួយឆ្នាំ គេចាំកត់ទុកក្នុងសាវតារ
ព្រះអង្គឡើងសោយរាជ្យកាលណា ព្រះនាមហៅថា នរោត្តម ។
ស្តេចគង់នៅរៀនសូត្រសិក្សា តាំងពីកុមារចេះមុតមាំ
ក្នុងស្រុកសៀមទ្រង់ប្រឹងខិតខំ ស្តេចសៀមតែទាំរៀងមកដល់ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហាសិបប្រាំក្រោយរៀបរៀងរាល់
ព្រះនរោត្តមសមសោតសល់ ជឿជាក់មគ្គផលផ្លូវសាសនា ។

ឆ្នាំនេះសៀមបើកព្រះអង្គស្តេច យាងវិលចរត្រាច់មកសីមា
ក្រុងកម្ពុជារាជរដ្ឋា ព្រះរាជឧត្សាសោយសម្បត្តិ ។
កាលលួងសម្តេចនរោត្តម ទាមថ្វាយរាជរម្យពុំស្ងប់ស្ងាត់
មានព្រះអានុជព្រះមហាក្សត្រ មួយអង្គកាចក្តាត់ទ្រង់នាមឈ្មោះ ។
ព្រះអង្គម្ចាស់ស៊ីវត្ថា ប្រាថ្នាដណ្តើមរាជចំពោះ
មានហឫទ័យលោភរាជសក្តិយស ពុំគិតអនុគ្រោះព្រះរាមវ័ត្ត ។
ព្រះអង្គម្ចាស់ស៊ីវត្ថា គិតការបះបោរចោរអប្បលក្ខណ៍
ដណ្តើមរាជថ្វាយដោយចិត្តស្មគ្រ ពុំដឹងភារៈចិត្តព្រះបង ។
កាលណោះមានរាស្ត្រមានមន្ត្រី ក្នុងព្រះបុរីខេត្តខណ្ឌផង
ទៅតាមស្តេចក្បត់ច្រើនកន្លង បំណងប្រយោជន៍រឿងផ្ទាល់ខ្លួន ។
ព្រះបាទសម្តេច នរោត្តម ហឫទ័យអត់ទ្រាំពុំគុំកួន
នឹងព្រះអានុជអណុងនួន ស្តេចភៀសទៅពួនបាត់ដំបង ។
មួយគ្រួសយាងហួសទៅបាងកក ទ្រង់យកប្រដាប់ស្នាប់ស្វរ៉ង
កុក្កដាភ័ណ្ឌព្រះខ័ន្ធផង ចិញ្ចៀនកែវកងសម្រាប់ទ្រង់ ។
កាលទ្រង់យាងទៅនៅបាងកក គ្រាក្រោយនោះមកមានអាណុង
អានុជមួយទៀតឃ្លាតបម្រុង នាមព្រះវង្សសាស្ត្រម្ចាស់សុំអោយ ។
គ្រាក្រោយបានសោយរាជ្យសម្បត្តិ នាមព្រះស៊ីសុវត្ថិក្សត្រសេដ្ឋា
ស្តេចធ្វើចម្បាំងនឹងពួកចោរ ចាមជ្វាមោហោថែមទៀតផង
នេះព្រះអម្ចាស់ស៊ីវត្ថា មានចេស្តាក្រៃកន្លង
ម្ចាស់ស៊ីវត្ថាខ្លាចព្រះបង យាងឆ្លងទៅគង់ស្រុកសំបូរ ។
ទើបព្រះសេដ្ឋានរោត្តម លំនាំប្រពៃមានជ័យយោ
ស្តេចជ្រាបដំណឹងដឹងហៃហូរ ក្សត្រថ្លៃវរោរតយ៉សេដ្ឋា ។

ទ្រង់យាងត្រឡប់វិលមកវិញ ឯស្តេចសៀមមិញក៏ចាត់ការ
ព្រះរាជបម្រើពលសេនា មកនៅត្រួតត្រាផ្ទាល់ព្រះអង្គ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហុកសិបបីក្រោយណាដោយត្រង់
ប្រវត្តិខ្មែរកែតម្រង់ ផ្ចិតផ្ចង់វេលាកាលគ្រានោះ ។
ជាតិបារាំងសែសមកតាំងទី នៅទ្វីបអាស៊ីពិតចំពោះ
ស្រុកយួនផិតយើងថ្លើងកេរ្តិ៍ឈ្មោះ ពីព្រោះជាតិគេខ្លាំងពូកែ ។
មានចិត្តចង់ចងស្ពានមេត្រី នឹងម្ចាស់ដែនដីស្តេចជាតិខ្មែរ
ចៅហ្វាយស្រុកយួនបារាំងសែស ក៏ចូលមកក្បែរក្រុងឧត្តុង្គ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហុកសិបមួយដោយចិត្តបម្រុង
ចូលថ្វាយបង្គំព្រះចោមពង្ស ទ្រើសទ្រង់ព្រះនាម នរោត្តម ។
ដល់ឆ្នាំមួយពាន់ប្រាំបីរយ ហុកសិបមួយដោយកិច្ចផ្សំផ្សំ
គួរវ៉េរណឺម៉ង់ចង់ដឹកនាំ បង្ខំចងស្ពានរាជមេត្រី ។
មេទ័ពជើងទ្បាក្រង់ឌីយេ ចៅហ្វាយស្រុកគេគិតសេចក្តី
ចូលថ្វាយបង្គំព្រះចក្រី នរោត្តម ខ្មីហើយប្រឹក្សា ។
អំពីព្រំដែនកូសាំងស៊ីន នឹងស្រុកខេមរិន្ទពីររដ្ឋា
តម្រូវដរីមទល់ត្រឹមណា ដោយការស័ក្តសិទ្ធិពិតប្រាកដ ។
ព្រោះតែសេចក្តីប្រឹក្សានេះ ស្តេចខ្មែរតម្រិះឃើញឡើងដាក់
ដាក់កម្ពុជាភារារដ្ឋ ជាទីជនបទប្រូតិកតូរ៉ា ។
ទំនុកបម្រុងបារាំងសែស ពុំមានប្រហែសទ្វេធ្វេសការ
ក្នុងឆ្នាំខាងលើធ្វើលេខា លិខិតសញ្ញាត្រេតតេស្រេច ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហាសិបបួនក្រោយនោះសម្តេច
ព្រះ នរោត្តម សមសួនសេច ពុំទាន់សម្រេចកិច្ចទទួល ។

រាជាភិសេកនៅឡើយទេ ព្រោះព្រះប្អូនគេខឹងក្តៅក្តួល
ដើរប្រមូលហៅរាស្ត្រខ្មៅខ្មួល ជ្រើមជ្រួលដណ្តើមរាជបល្ល័ង្ក ។
ស្តេចយាងទៅគង់ឯបាងកក នាំយកម្កុតកែវវត្ថុណាំ
កុក្កុដភ័ណ្ឌមណ្ឌលំ គ្រឿងតាំងសំអាងស្តេចទៅផង ។
គ្រឿងសម្រាប់រាជនៅបាងកក សៀមយកឃាត់ទុកអស់តែម្តង
មិនព្រមថ្វាយមកក្សត្រច្បាស់ច្បង បំណងទារគុណប្រយោជន៍ខ្លះ ។
ហេតុនេះរាជការប្រួតិកតូវ៉ា ផ្ញើសារឱ្យសៀមឆ្លាប់រហ័ស
យកគ្រឿងសម្រាប់រាជល្អល្អះ មកថ្វាយលួងម្ចាស់កែវជីវិត ។
ស្តេចសៀមចាត់ប្រើបំរើម្នាក់ នាំគ្រឿងរាជស័ក្តិព្រះបរពិត្រ
មកថ្វាយចមពង្សទ្រីសទ្រង់ឫទ្ធិ នៅទេវនិមិត្តវាំងឧត្តុង្គ ។
ព្រះមហាក្សត្រក្សាន្តបានទទួល គ្រឿងរាជស្រួលបួលស្រេចពុំលង់
បានរាជភិសេកឯកចមពង្ស ចមពោធិវង្សស្តេចស្រុកខ្មែរ ។
នៅចំពោះមុខអ្នករាជការ ប្រួតិកតូវ៉ាបារាំងដែរ
រួមស្រេចសម្តេចព្រះនោមស្នេហ៍ ទ្រង់បែរព្រះភ័ក្រ្តតម្រិះខ្វី ។
អោយរាជបម្រើពីបាងកក វិលបកត្រឡប់ទៅបុរី
ស្រុកសៀមវិញទៅកុំនៅថ្វី ក្រោយនោះដែនដីកម្ពុជា ។
បានសុខក្សេមក្សាន្តសម្រានស្បើយ ល្ហែល្ហើយគ្មានទុក្ខទោសភ័យា
លែងចំណុះសៀមទាំងពីរគ្រា នោះមករាល់គ្នាគង់ដឹងច្បាស់ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហុកប្រាំបីក្រោយប្រវត្តិសាស្ត្រ
រាជការបារាំងកម្លាំងណាស់ តែងសាររហ័សឆាប់មិម្មា ។
ផ្ញើទៅបាងកកសេចក្តីសារ ថាអោយព្រះចៅអយុធ្យា
ប្រគល់ទឹកដីកម្ពុជា អោយមករាជការបារាំងសែស ។

ទំនុកបម្រុងក្នុង... ស្រុកខ្មែរជាទីដែនថ្មីថែស
........កុំប្រហែស ដាក់ស្មើអង្គគេសជួយការពារ ។
ស្តេចសៀមតបសារថាមិនថី ព្រមអោយទឹកដីកម្ពុជា
សៀមសុំយកផ្តាច់របស់វា ខេត្តបីនៅនាព្រំប្រទល់ ។
គឺស៊ីសុផុនបាត់ដំបង សៀមរាបមួយផងខ្មែរគួរយល់
ប្រាកដជាក់ច្បាស់ដើមឫសគល់ តែមិនរវល់ឈ្លោះតវ៉ា ។
ប្រវត្តិសាស្ត្រខ្មែរទីម្ភៃ ប្រាំពីរសោតនៃមហាក្សត្រា
មានឫទ្ធិអំណាចព្រះចេស្តា គឺ...បើមហាក្សត្រ ។
សេដ្ឋៈសព្វព្រះព័យចង់ធ្វើអ្វី គ្មានរាស្ត្រមន្ត្រីអាចហ៊ានកាត់
ឆ្លើយទទឹងទាស់ដល់មួយម៉ាត់ ខ្លះត្រូវស្លៀមស្លាត់គ្រប់ៗគ្នា ។
ដីក្នុងនគរទាំងប៉ុន្មាន ដូចស្រែភូមិឋានទីនានា
ទុកជារាជទ្រព្យព្រះរាជា នាក់ធ្វើរាល់គ្នាពុំមែនម្ចាស់ ។
បើស្តេចយាងចេញទៅទីណា រាស្ត្រអោនសិរសាក្រាបសំពះ
ថ្វាសរាបដល់ដីស្រីក្មេងចាស់ ទាំងប្រុសចំណាស់ប៉ុន្មានក្តី ។
ក្សត្រថ្លៃទ្រង់លក្ខណ៍ចមចក្រពាន ព្រះអង្គស្តេចមានមុខមន្ត្រី
ធំៗប្រាំនាក់ថ្នាក់កុង្សី សេនាបតីធ្វើរាជការ ។
ជិតផ្ទាល់ព្រះអង្គតាមចំណាំ ទាំងប្រាំសុទ្ធតែទីឧកញ៉ា
១ ថ្នាក់អគ្គមហាសេនា ត្រួតត្រារាជការអធិបតី ។
កុង្សីប៉ុន្មានមានមុខការ ទីពីរឧកញ៉ាយមរាជខ្ចី
ត្រួតត្រាសាលាជំនុំក្តី ទី៣ ហៅថាឧកញ៉ាវាំង ។
ត្រួតត្រាក្រសួងរាជមន្ទីរ ក្សត្រថ្លៃភូមិនឹងព្រះឃ្លាំង
រាជទ្រព្យទាំងពួងលួងស្តេចតាំង ថែទាំអស់ទាំងស្រីបរិពារ ។

ទី៤ ឧកញ៉ាកឡាហោម ត្រួតត្រាមើលព្រមការនានា
ព្រះរាជទីនាំងទូកនាវា របស់ភស្តុភារនេសាទត្រី ។
បឹងស្រែចំការច្បារដំណាំ ព្រោះដាំរុក្ខជាតិទៅលើដី
ទីប្រាំ ឧកញ៉ាទីចក្រី រដ្ឋមន្ត្រីខាងការពារ ។
ព្រះរាជធានីដោយមួនមាំ នឹងការដឹកនាំតាមផ្លូវថ្នា
ក្រសួងជើងគោកយុទ្ធនា អភិបាលភារារាជបុរី ។
សេនាបតីទាំងប្រាំនេះ បើស្តេចតម្រិះជ្រើសតាំងថ្មី
ឬត្រូវដកហូតផ្លាវិញក្តី ស្រេចនៅហឫទ័យព្រះរាជា ។
ព្រះរាជនគរស្តេចទ្រង់ចែក ជាច្រើនចំណែកខេត្តនានា
ខេត្តមួយមានម្នាក់យសសក្តិក្តារ ជាទីចៅហ្វាយស្រុកត្រួតត្រា ។
ធ្វើអធិបតីក្នុងខេត្តមួយ ក្រសួងជំនួយទារពន្ធដារ
គ្រប់មុខដាក់ទុកប្រាក់រាជការ ជំនុំផ្សុះផ្សាកាត់ក្តីផង ។
គ្រប់ខេត្តចៅហ្វាយស្រុកទាំងស្រុង ត្រូវចូលមកក្រុងមួយឆ្នាំម្តង
ផឹកទឹកសម្បថសច្ចាផ្សេង ធ្វើរាជការស្នងព្រះតេជះ ។
ព្រះករុណាស្តេចជាតិខ្មែរ សុទ្ធតែសុចរិតត្រឹមត្រូវណាស់
ប៉ុន្តែមានចៅហ្វាយស្រុកខ្លះ ដែលនៅឆ្ងាយខ្ញុំរាជគារវៈ ។
មិនព្រមចំណុះស្តេចផងខ្លួន ក្រអឺតក្រអូនមិនស្មោះស្ម័គ្រ
មិនទទួលស្តាប់ស័ព្ទសន្ធរៈ ព្រះរាជវចនៈស្តេចខ្លះដែរ ។
អស់ចៅហ្វាយស្រុកគ្មានបៀវត្ស គឺប្រាក់កំណត់សម្រាប់ខែ
មន្ត្រីទាំងនោះហូតយកតែ ចំណែកប្រាក់ដែលត្រូវពិន័យ ។
លើប្រាក់ថ្លៃពន្ធគ្រប់ជំពូក នឹងប្រាក់រាស្ត្រសូកអោយទីទៃ
គាត់យកតាមចិត្តឥតព្រួយភ័យ អាករសួយរ៉ៃប្រយោជន៍ខ្លួន ។

ជំនុំជំរះកាត់ក្ដីក្ដាំង ពុំតាមចំណាំពេញសំនួន
គ្មានយុត្តិធម៌តាមច្បាប់ក្បួន ទទួលជំនួនពីគូក្ដី ។
ឈ្មោះណាច័លក្រគឺចាញ់គេ ឬត្រូវទោសទ្វេគ្មានប្រណី
ស្រេចលើចៅក្រមគេកាត់ក្ដី លំអៀងសេចក្ដីទៅតាមចិត្ត ។
អគតិបួនយ៉ាងអាងជាគ្រូ ធ្វើជាគំរូផ្លូវទុច្ចរិត
ឯពន្ធត្រូវលួងដាក់កំហិត ច្បាប់លើរាជក្រឹត្យត្រូវដាក់ឃ្លាំង ។
ប៉ុន្តែដូចយើងយល់ស្រាប់ហើយ មិនដូច្នេះឡើយនោះអស់ទាំង
ចៅហ្វាយស្រុកក្រៅលាក់បិតបាំង កាត់យកប្រាក់ឃ្លាំងមួយចំណែក ។
យ៉ាងធំទុកធ្វើប្រយោជន៍ខ្លួន កាន់ក្បួនខាងលើមើលឃើញប្លែក
មុខពន្ធទាំងនេះគេបំបែក ចាត់ចែករាយឈ្មោះតាមពួកកង ។
វត្ថុទាំងនោះគឺអង្ករ ស្រូវស្ករព្រៃស្បូត្រអាបោះផង
ឬស្សីវល្លិផ្ដៅធ្វើចំណង គ្រឿងចងរឹតស្រាក់ត្រូវដាក់ឃ្លាំង ។
ជាម្ចាស់រាជទ្រព្យម្ចាស់ផែនដី របស់អ្វីៗល្អសម្រាំង
សង់ព្រះពន្លាឬរាជវាំង អស់ទាំងវត្ថុជាអាហារ ។
សម្រាប់ចិញ្ចឹមល្វៀងព្រះសង្ឃ និងមនុស្សព្រះអង្គម្ចាស់សិរីសា
នៅក្នុងជំពាក់ព្រះករុណា ដែលឥតមានការធ្វើធំដំ ។
បណ្ដារាស្ត្រខ្មែរក្នុងបុរី ប្រុសស្រីគេចែកជាបីក្រុម
ទី១ អ្នកជាពុំមែនក្រុម កញ្ចាស់គេសុំធ្វើរាជការ ។
អ្វីៗសឹងបានតាមបំណង ឬបួសជាសង្ឃក្នុងសាសនា
ចូលកាន់ប្រជុំទីប្រឹក្សា ធ្វើមង្គលការអ្វីៗបាន ។
ទី២ មួយក្រុមមនុស្សខ្ញុំគេ មិនរាប់រកទេចាស់បូរាណ
គឺមនុស្សជំពាក់ប្រាក់សន្ដាន លក់ដូរទិញបានដូចជាសត្វ ។

ប៉ុន្តែមនុស្សនេះបើកាលណា សងប្រាក់ដើមការតាមបញ្ញត្តិ
លោះខ្លួនបានដែរតែវិបត្តិ ជាប់ជាតិថោកក្នាត់ពូជខ្ញុំគេ ។
ទី៣ ពួកពលគួរយល់បាន ប្រាំបីសណ្ឋានមិនរួចទេ
មនុស្សនេះទុច្ចរិតវៀចវេ ប្រព្រឹត្តិសក្ដើឪពុកម្ដាយ ។
គឺពួកមនុស្សទោសក្នុងចំបាំង ក្បត់ខ្មាំងផែនដីរយឆ្នាំផ្លាយ
ជាច្រើនតំណតវែងឆ្ងាយ ឥតមានឧបាយកែខ្លួនបាន ។
ម្យ៉ាងទៀតហៅពលសម្រាប់រាជ ព្រឹកល្ងាចធ្វើការមហាក្សត្រក្សាន្ត
រាល់ឆ្នាំរាល់ខែឥតបីខាន ប្រមាណយូរដែរតែមិនរួច ។
មួយទៀតចាស់ហៅថាពលព្រះ សម្រាប់វត្តខ្លះមានតិចតួច
ទោះមានចំណេះចេះយ៉ាងស្រួច លបលួចដកខ្លួនចេញពុំបាន ។
សៀវភៅប្រវត្តិទីម្ភៃ ប្រាំបីសោតនៃជាលំអាន
រឿងរ៉ាវស្រុកខ្មែរប្រែតាមស្ថាន ប្រមាណសករាជគ្រិស្តសាសនា ។
មួយពាន់ប្រាំបីរយហុកសិបបួន សំនួនលិខិត ខ សញ្ញា
បារាំងតាំងប្រូតិកតូរ៉ា ក្នុងគ្រិស្តសាសនាឆ្នាំកំណត់ ។
មួយពាន់ប្រាំបីរយហុកបី មុនថ្លែងសេចក្ដីក្នុងប្រវត្តិ
ម្ភៃប្រាំមួយដោយហ្មត់ចត់ ហេតុពិតប្រាកដដូចថ្លែងស្រាប់ ។
សញ្ញាត្រេតតេកុងវ៉ង់ស្យុង នៅក្រុងបារាំងយូរមិនធ្លាប់
រវាងមួយឆ្នាំគេចាំស្ដាប់ ទើបផ្ញើត្រឡប់មកស្រុកអាំង ។
សេចក្ដីសំបុត្រ ខសញ្ញា នោះថារាជការស្រុកបារាំង
ត្រូវជួយទំនុកពេញកម្លាំង ខេមរៈរដ្ឋកម្ពុជា ។
អោយកើតសិរីសុខក្សេមក្សាន្ត សត្រូវប៉ុន្មានជួយគាំពារ
កុំអោយលុកលុយក្នុងភារា យូនសៀមជាមារធិរាជធំ ។

ប្រយោជន៍ជាហេតុនឹងប្រតិបត្តិ តាម ខ បញ្ញត្តិអោយសមរម្យ
បានដូចប្រាថ្នាការនិយម ប្រក់ព្រំប្រាកដវឌ្ឍនា ។
ស្តេចបារាំងចាត់អ្នកតំណាង ម្នាក់ជាចាងហ្វាងយសសក្តិជា
ទីសុបេរីយ៉ើឈរធ្វើជា រ៉េស៊ីដង់គាំពារនគរខ្មែរ ។
អោយមកនៅធ្វើកិច្ចរាជការ ប្រឹបព្រះករុណាគ្រាល់ឆ្នាំខែ
ត្រួតគ្រប់ក្រសួងតាមក្រសែ តំរែតំរូវត្រឹមត្រូវច្បាប់ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហុកសិបប្រាំក្រោយនោះមកស្រាប់
ព្រះនគរខ្មែរប្រែក្រឡាប់ ចលាចលចាប់មានចំបាំង ។
រវាងពីរឆ្នាំជាកំណត់ មានពួកអាត្បត់ពីរនាក់តាំង
អួតខ្លួនឯងពិតមានឫទ្ធិខ្លាំង ដើរញុះញង់ហៅរាស្ត្របះពោឡា ។
មួយនាក់ឈ្មោះពិតអាចារ្យស្វា មួយទៀតឈ្មោះថាពោធិកំបោរ
ជាមនុស្សទុច្ចរិតចិត្តមោហោ ប្រកាន់ទេសោអះអាងថា ។
ខ្លួនវាជាអ្នកខ្លាំងពូកែ រាស្ត្រខ្មែរជឿជាក់បើអ្នកណា
ទៅតាមវាហើយវាជួយការ សត្រូវពីណាទិសណាក្តី ។
បាញ់វាមិនស្លាប់កាប់មិនមុត ឃើញចូលតយុទ្ធកុំខ្លាចអ្វី
សហាពោធិ៍កំបោរចោរអប្រិយ អួតអំណួតស្តីប្រាប់រាស្ត្រថា ។
បាញ់វាមិនចេញដេញមិនទាន់ ឫទ្ធិមហន្តយ៉ាងអស្ចារ្យ
ចេះសីលមន្តខ្លាំងបាំងកាយា យាត្រាចេញទៅមើលមិនយល់ ។
ឯបារាំងសែសគេមិនខ្លាច រំលេចលើកទ័ពសព្វវេល
យកខ្លះចេញច្បាំងតាំងតទល់ មិនអោយរវល់ព្រះចេស្តា ។
ព្រះបាទសេដ្ឋា នរោត្តម រៀបចំចេញជួយព្រះករុណា
លើកទ័ពដេញតាមចាប់អាស្វា អស្ចារ្យបែកបាក់រត់ខ្ចាត់ខ្ចាយ ។

អាស្មាស្បែកស្វិតចិត្តអាក្រក់ គេចហក់មិនរួចពីអន្តរាយ
មិនយូរប៉ុន្មានចាប់បានកាយ ឃុំបង្អត់បាយទាល់តែស្លាប់ ។
អាចារ្យស្មាបះពេញមួយឆ្នាំ គេចាំប្រវត្តិកំណត់ស្រាប់
ថ្មេះឯងសូមថ្លែងជាសណ្តាប់ សន្តានគួរចាប់ចាំគ្រប់គ្នា ។
ឯទ័ពអាល័ក្តពោធិ៍កំបោរ ចិត្តទ្រុស្តមោហោខ្លាំងមហិមា
ច្បាំងយ៉ាងសម្បើមផ្តើមឫទ្ធា យូរយាពិបាកឈ្នះបន្តិច ។
ដប់ប្រាំខែទ័ពបារាំង ទ័ពចាប់អាខ្លាំងបានរំពេច
អាងអួតឫទ្ធីខ្លាំងបំបាំងគេច ប្រហារកំទេចជន្មជីវិត ។
ឆោមស្អាតព្រះបាទ នរោត្តម សក្តិសមសោយរាជ្យប្រពៃពិត
ដោយសារបារាំងជួយគំនិត ក្សត្រថ្លៃទ្រង់ឫទ្ធិក្សាន្តហឫទ័យ ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ហុកប្រាំពីរក្រោយឆ្នាំនេះនៃ
ស្តេចទ្រង់តម្រិះលើកក្រុងជ័យ ពីឧត្តុង្គរៃឆាប់ម្ទីម្ទា ។
ស្តេចទ្រង់ចាត់ចែងឱ្យជាងតាំង សាងព្រះរាជវាំងព្រះរាជា
នៅទីភ្នំពេញមាត់គង្គា នាម្នាទន្លេចតុមុខ ។
ជាប់រៀងរហូតដល់សព្វថ្ងៃ មហាក្សត្រថ្លៃរួចចាកទុក្ខ
ដោយសារបារាំងជួយទំនុក សត្រូវរានរុកខ្លាចរអា ។
ម្យ៉ាងទៀតនៅក្នុងនគរខ្មែរ នៅតែពុំបានចំរើនការ
អ្វីសោះទាំងអស់ក្នុងសីមា យឺតយូរអស្ចារ្យជាងស្រុកយួន ។
ដែនកូសាំងស៊ីនទល់ស្រុកខ្មែរ ព្រោះតែស្តេចទ្រង់ប្រកាន់ក្បួន
ទំនៀមទំលាប់ជាប់មាំមួន ស្នាក់ស្ទើរស្នោកស្ទួនគ្រប់កន្លែង ។
មិនព្រមកែប្រែរាជការចាស់ ប្តូរផ្លាស់របៀបរៀបចាត់ចែង
ជាប់ជាគំរូយូរអង្វែង ជាក់ស្តែងរហូតរៀងមកដល់ ។

គ្រិស្តស័កមួយពាន់ប្រាំបីរយ    ចិតប្រាំពីរក្រោយព្រះយោបល់
តម្រិះយល់ឃើញប្រយោជន៍ផ្ទាល់    ចំរើនកើនផលជាប់រហ័ស ។
ដល់ប្រទេសជាតិកម្ពុជា    ក្សត្រថ្លៃសោភាទ្រង់ជ្រាបច្បាស់
លោកស៊ុយបើរយ៉ឺពន្យល់ខ្លះ    ទើបទ្រង់តម្រាស់ព្រះឱង្ការ ។
អោយបារាំងសែសរើកែប្រែ    កិច្ចរាជការខ្មែរថ្វាយក្សត្រា
ឡាយព្រះហស្តស្រេចតាមអាជ្ញា    មាត្រាសំខាន់មានប្រាំ ខ ។
ខ១ បណ្តាជនជាតិខ្មែរ    ធ្វើស្រែចំការទោះមានក្រ
មានដីភូមិភាគអាក្រក់ល្អ    ជាកេរ្តិ៍អាករធ្លាប់ប្រើប្រាស់ ។
អ្នកធ្វើប៉ុន្មានបាអង់អាច    ត្រូវមានអំណាចធ្វើជាម្ចាស់
ដីរបស់ខ្លួនឥតប្តូរផ្លាស់    លប់លើច្បាប់ចាស់ជាអាសារ ។
ខ២ នៅក្នុងខេត្តមួយៗ    រាជការជំនួយប្រូតិតតូរ៉ា
តាំងជារេស៊ីដង់ម្នាក់ដើរមើលការ    ត្រួតត្រាធ្វើជាអធិបតី ។
ខ៣ ក្រសួងរាជការធំ    ក្នុងបូរីរុំរបៀបថ្មី
គឺគយឃ្លាំងប្រាក់មេការក្តី    និងប្រៃសណីយ៍ប៉ុស្តិ៍ខ្សែលួស ។
ត្រូវជាតិបារាំងធ្វើចាងហ្វាង    ត្រួតត្រាតំណាងការជំនួស
ប្រយ័ត្នមុខក្រោយមិនអោយហួស    ជ្រុលជ្រួសឃ្លៀងឃ្លាតច្បាប់មាត្រា ។
ខ៤ ចំនួនផលហូតពន្ធ    ស្រាលធ្ងន់ច្រើនតិចដូចម្តេចម្តា
ត្រូវនាំដាក់ឃ្លាំងជូនរាជការ    ឈ្មោះណាបំភ័ន្តត្រូវទណ្ឌកម្ម ។
អស់ទាំងបារាំងប្រូតិតតូរ៉ា    ត្រូវការកាត់ប្រាក់តាមបណ្តាំ
សាមសិបម៉ឺនរៀលក្នុងមួយឆ្នាំ    ជាប្រាក់ប្រចាំសម្រាប់ខែ ។
ថ្វាយព្រះករុណាម្ចាស់ផែនដី    ក្នុងព្រះបុរីស្តេចស្រុកខ្មែរ
សំរាប់ព្រះស្វោយដោយហូរហែ    រាល់ឆ្នាំរាល់ខែមិនត្រូវខាន ។

៩៥ ពួកពលថ្នាក់ណាក្តី លើកចោលលែងស្តីច្បាប់បុរាណ
មិនអោយមានទោសក្នុងរាជស្ថាន ពួកពលប៉ុន្មានត្រូវរួចខ្លួន ។
គ្រិស្តស័កមួយពាន់ប្រាំបីរយ ប៉ែតសិបបួនក្រោយរាយសំនួន
ប្រវត្តិសាស្ត្រខ្មែរកែពាក្យជូន ក្នុងមាត្រាក្បួនសម្តែងថា ។
កាលនោះមិនស្រួលជ្រួលជ្រើមខ្លាំង ដោយហេតុបារាំងប្រួតិតតូវ៉ា
កែប្រែរបៀបកិច្ចរាជការ លប់ចោលមាត្រាបូរាណចាស់ ។
បំបាត់ពួកពលមិនអោយមាន ពាពានគំនរមន្ត្រីចាស់
នាំគ្នាខឹងក្តៅមួម៉ៅណាស់ គិតជៀងជំទាស់របៀបថ្មី ។
នាម៉ឺនចាស់នោះតែងឈ្លានពាន ធ្លាប់មានពួកពលប្រើប្រុសស្រី
ធ្លាប់បានប្រយោជន៍ទ្រព្យអ្វី១ ពីពលបុរីរៀង១ខ្លួន ។
កាលបើគិតឃើញខាតដូច្នេះ ក៏ចេះតែដើរប្រើសំនួន
កិច្ចនយោបាយកាយស្ងប់ស្ងួន ឯចិត្តគុំកួនជែងចង់ឈ្នះ ។
លបញុះញង់រាស្ត្រក្នុងនគរ បះបោរីកវរឆាប់រហ័ស
គ្រប់ខេត្តជាហេតុអោយឃើញច្បាស់ រាស្ត្រជ្រួលជ្រើមណាស់ក្នុងបុរី ។
លោកកុម៉ង់ដង់បារាំងសែស ពុំហ៊ានប្រហែសភ្លេចស្មារតី
លើកទ័ពប្រញាប់ឆាប់ឃ្មាតខ្មី ដើម្បីបង្ក្រាបចាប់ចោរខ្លាំង ។
គ្រប់ខេត្តខ័ណ្ឌឃុំប្រជុំទ័ព ពលខ្មែរតាមជាប់ជួយកម្លាំង
សឹកសង្គ្រាមជ័យជាតិបារាំង រៀបដូចចំបាំងក្រៅនគរ ។
ទ័ពខ្មែរបារាំងទាំងប៉ុន្មាន ព្រួយប្រាណថ្ងៃយប់ឥតឈប់ឈរ
គគ្រាក់គគ្រុកដើររុករក បះបោរីកវរគ្រប់គ្រាន់ ។
រវាងពីរឆ្នាំទើបសាន្តគ្រាន សុខសាន្តចំពោះគ្រានោះឯង
មិនបានគតបរិទ្ធិអោយឃើញស្តែង មិនជាខ្ពះខ្នែងប៉ុន្មានទេ ។

ប៉ុន្តែដែលដើរបំរាស់នោះ ស្លាប់ពលរលោះជាតិយើងគេ
ទ័ពខ្មែរបារាំងទាំងកូនមេ ក្តាន់ក្តេចំនួនច្រើនពាន់នាក់ ។
ដោយអស់កម្លាំងអត់អាហារ មរណេសញ្ញាចូលមកស្ទាក់
ស្លាប់នឹងជំងឺឈឺចុកចាប់ រងារញ៉័រញាក់ក្តៅក៏មាន ។
របៀបរាប់រៀបតាមបែបបទ សាវតារប្រវត្តិកត់និទាន
លុះស្រុកកើតសុខជាប្រធាន ព្រះចមចក្រពាន នរោត្តម ។
សោយរាជ្យជាស្តេចសំរេចការ កបព្រះករុណាល្អស័ក្តសម
ក្រោយមកទុក្ខសោកគ្មានលាយឡំ ចំរើនមូនមាំក្នុងបុរី ។
រាជការចាប់ធ្វើការធំៗ ប្រវត្តិសមរម្យតាមច្បាប់ថ្មី
ញ៉ាំងស្រុកកើតសុខស្រីសួស្តី គប្បីដូចស្រុកគេជិតខាង ។
ក្សត្រថ្លៃសេដ្ឋា នរោត្តម ព្រះបរមជាមូលកំពូលប្រាង្គ
សោយទីវង្គតផុតសំណាង ភស្តុតាងរវាងគ្រិស្តសាសនា ។
មួយពាន់ប្រាំបួនរយពិត ក្សត្រថ្លៃទ្រង់ឫទ្ធិវង្សខេមរា
សោយរាជ្យសម្បត្តិក្នុងរដ្ឋា សែប្រាំវស្សាជាទៀងទាត់ ។
ក្រោយទីវង្គតរលត់ជាតិ ព្រះញាតិព្រះវង្សទ្រង់កំណត់
ព្រះនាមថ្មីក្រោយដោយសំដី ចក្រព័ត្តសុវណ្ណកោដិតំណាង ។
ព្រះបាទសេដ្ឋា នរោត្តម ព្រះបរមស្ទូរិន្ទពិនសុវ៉ាង
ព្រះរាជទ្រព្យស្តេចបានសាង តួយ៉ាងព្រះកេរ្តិ៍សឹងមានព្រម ។
១ សាងមន្ទីររាជវាំងភ័ក្រ្ត ប្រសើរសមស័ក្តខ្ជោះដុងដោម
ខាងត្បូងខាងជើងជិតចំណោម វត្តឧណ្ណាលោមភ្នំពេញពិត ។
២ ទ្រង់សាងថ្នល់ជុំវិញវាំង បុកគ្រួសថ្មផ្ទាំងក្រាលជុំជិត
៣ សាងចេតិយរុងរឿងឫទ្ធិ បោក់ទេវនិម្មិតល្អស្អាប្ប ។

លើកកំពូលភ្នំព្រះរាជទ្រព្យ បញ្ចុះព្រះសពអដ្ឋិកា
អង្គខ្លួងលួងម្ចាស់ព្រះបិតា លើខ្នងបុព្វតាខ្ពស់ចំពែង ។
៤ សាងវិហាររាជធានី ជិតនៅក្នុងទីវាំងកំផែង
ស្រះសារពើយុទ្ធមួយកន្លែង ដាក់ស្តែងប្រាកដរាជសាវតា ។
៥ សាងវិហារមួយសំដី ព្រះកែវមរកតល្អអស្ចារ្យ
នៅក្នុងកំផែងវាំងប្រាង្គប្រា ទិសទក្ខិណាផែប្រាក់ក្រាល ។
គ្រប់ល្វែងខាងលើធ្វើសំវាំង គ្រឿងតាំងមាសពេជ្ររំលេចប្រាល
ជើងពានមាសប្រាក់ឆ្លាក់ត្រកាល កម្រាលអង្គកែព្រែកាមីញ៉ី ។
ព្រះបដិមាករល្អសំខាន់ សាងពីមាសតាន់រឿងរាំង្សី
ដែលព្រះស៊ីសុវត្ថិម្ចាស់ផែនដី រចនាជាថ្មីតាមឱង្ការ ។
ព្រះរាជបណ្ដាំ នរោត្តម រៀបចំថ្វាយព្រះរៀមរេក្ខា
ឧទ្ទិសចំពោះដល់សាសនា ថ្វាយមហាក្សត្រក្រាបង្គំយកិច្ច ។
ជុំវិញកំផែងវត្តព្រះកែវ ធីមផែវខាងកើតនិងខាងលិច
ខាងជើងណែបនិតជិតបន្តិច ដៃជាងល្បីល្បិចខាងរចនា ។
គូសវាសគំនូររឿងរាមកេរ្តិ៍ ឃើញទេស្នាដៃជាតិខេមរា
ដែលមានកេរ្តិ៍ឈ្មោះយសសក្ការ ជាទីឧកញ្ញាទេពនិមិត្ត ។
ហើយនិងកូនជាងដែលចំណាន រៀនបានចំណេះចេះស័ក្តសិទ្ធិ
គូរថ្វាយចមពង្សព្រះទ្រង់ឫទ្ធិ ល្អពន់ពេកពិតឥតប្រៀបបាន ។
សំណាករូបភាពព្រះរាមរ័ក្ស ហើយនិងព្រះលក្សណ៍រូបហនុមាន
រូបគ្រុឌរូបយក្សហាក់ហៅហាន រូបមហាក្សត្រក្សាន្តព្រះនរាយណ៍ ។
រូបព្រះឥសូរមហាឥសី រូបស្រីសិតាត្រូវទំនាយ
រាពណ៍នក់យកបានទៅដោយឆ្ងាយ ព្រះនាងព្រាត់ព្រាយឃ្លាតស្វាមី ។

រូបស្វាសុគ្រីពនិងពាលី ច្បាំងនឹងទូភីស្តេចក្របី
អស់មាត់ភ្លាត់ក្បាច់ដាច់សិរីសី ពាលីចក្រីសំលាប់បាន ។
ម្យ៉ាងទៀតនៅទីខាងមុខវត្ត ព្រះកែវមរកតវត្តនោះឋាន
គេសាងព្រះរូបមហាក្សត្រក្សាន្ត ព្រះបាទអវតាន នរោត្តម ។
គង់លើអស្សាសេះសសុទ្ធ ក្លាខ្លាំងបំផុតល្អស័ក្តសម
សំណុំសំនួនខ្លួនធំមាំ លំនាំបែបយ៉ាងស្តេចទេវតា ។
នាមឈ្មោះសកៈទេវរាជឫទ្ធិ គង់សេះនិមិត្តទតសួនច្បារ
ហោះហើរដើរលើអាកាសា មានឫទ្ធិចេស្តាបុណ្យបារមី ។
ព្រះបាទលាយលក្ខណ៍ផាក់កែបឈ្នាន់ ដូចទេពទេវីនឋានសួគ៌ស្រី
ទ្រង់សុពិណបាទស្អាតវង្សី ចក្រីឆ្ពោះភ័ក្ត្រទិសឧត្តរ ។
លោកអ្នកឯណាចង់ឃើញវត្ត ព្រះកែវមរកតរតនា
ព្រះរូបតំណាងមហាក្សត្រា ត្រូវការសុំច្បាប់ចូលមើលបាន ។
ពេលម៉ោងនាទីថ្ងៃអាទិត្យ រាស្ត្រនៅឆ្ងាយជិតទាំងប៉ុន្មាន
អញ្ជើញទស្សនាជាកំសាន្ត ទីស្សាវរីយ៍ឋានសាងទុកមក ។
ប្រវត្តិកំណត់ទីម្ដែ ប្រាំបួននេះនៃសូមលៃលក
រឿងតតំណក្សត្រពន្លក ភាវរកសេចក្តីតំណាលថា ។
កាលថ្ងៃក្សត្រថ្លៃទីវង្គត់ រលត់ខ័ន្ធប្រាំទៅកាលណា
ក្រុមជំនុំធំនាយការ ក្នុងព្រះសីមាទាំងប៉ុន្មាន ។
ជាដើមគឺអស់លោកកុង្សី សេនាបតីក្នុងរាជឋាន
ព្រមទាំងវង្សានុវង្សាន្ត ក៏បានជំនុំដោយសុចរិត ។
សម្តេចព្រះសង្ឃរាជា ទាំងពីរគណៈបរោហិត
លោកសុបេរីយ៉ឺធ្វើលិខិត បញ្ជាក់សួរចិត្តមូលមាត់គ្នា ។

អញ្ជើញលួងម្ចាស់ព្រះអង្គារ ក្សត្រថ្លៃសេដ្ឋាអនុជា
អង្គព្រះឧបរាជរឿងឫទ្ធា សូមព្រះសម្ភាព្រមទទួល ។
រាជ្យសម្បត្តិស្នងព្រះវៀម ទំលាប់ទំនៀមលោកប្រែប្រួល
សូមទ្រង់មេត្តាការស្រុះស្រួល ជោគជ័យទំនួលក៏សមសួន ។
កាលនោះលួងឧប្បយោរាជ ព្រះជន្មឯងអាចហុកសិបបួន
អ្នកក្រុងអ្នកស្រែខ្មែរចិនយួន រាល់ខ្លួនស្រឡាញ់លួងអម្ចាស់ ។
ចក្រពានស្តេចមានហឫទ័យល្អ ស្មោះសសុភាពពន់ពេកណាស់
កបព្រះញាណជ័យវៃវហ័ស អធ្យាស្រ័យចាស់ព្រឹទ្ធាចារ្យ ។
លួងព្រមឧបរាជអំណាចខ្លាំង ធេហីសឹកចម្បាំងមានចេស្តា
ក្លាហានបាននាំពលសេនា បង្ក្រាបបច្ចាមិត្តបះបោរ ។
ក្នុងឆ្នាំមួយពាន់ប្រាំបីរយ ហុកសិបមួយក្រោយឱ្យអន្តរាយយោ
ជួសពាងព្រះរាមរាជសេដ្ឋា ពួកចោរចាលចាញ់ព្រះបារមី ។
រីឯឆ្នាំមួយពាន់ប្រាំបីរយ ប៉ែតសិបបួនក្រោយទៀតចក្រី
បង្ក្រាបពួកបះក្នុងបុរី ដែលរាជការថ្មីរីវៀបចំ ។
ព្រះឧបរាជនាមសុំអោយ អានុជសេដ្ឋា នរោត្តម
ស្រុះស្រួលទទួលតាមលំនាំ ចតុស្តម្ភអញ្ជើញសោយសម្បត្តិ ។
ក្នុងឆ្នាំមួយពាន់ប្រាំបួនរយ ប្រាំមួយគ្រាក្រោយមន្ត្រីក្សត្រ
ថ្វាយព្រះនាមឈ្មោះពិរោះក្តាត់ ព្រះបាទស៊ីសុវត្ថិម្ចាស់សិរិសី ។
ក្នុងឱកាសរាជាភិសេក ជាឯកចមប្រាង្គសាងបារមី
លោកគូវែរណឺសេណេរ៉ាល់ថ្មី ដែលនៅឈរស្តីត្រួតរាជការ ។
ស្រុកអាំងដូស៊ិនមួយទាំងមូល ក្រាបទូលថ្វាយមកុដរាជសុវណ្ណ
ព្រះបាទស៊ីសុវត្ថិព្រះមហាក្សត្រា មានបុណ្យអស្ចារ្យយ៉ាងក្រៃលែង ។

ចូលចាំចំណាំកត់សេចក្តី ក្នុងព្រះបុរីយ៉ាងនេះឯង
តាំងពីយូរយាជាកន្លែង ពុំដែលឃើញស្តែងយ៉ាងនេះសោះ ។
ទើបតែស្តេចខ្មែរស៊ីសុវត្ថិ សោយរាជ្យសម្បត្តិគ្មានទំនាស់
ក្នុងស្រុកបានសុខស្រួលទាំងអស់ ស្ម័គ្រស្មោះគ្មានការចលាចល ។
ដោយសាររាជការបារាំងសែស ពុំហ៊ានប្រហែសខំខ្វាយខ្វល់
ទំនុកបម្រុងក្នុងសកល ភូមិភ័ព្វមណ្ឌលកម្ពុជា ។
ឆ្នាំដែលស្តេចបានរាជ្យសម្បត្តិ មហាក្សត្រតម្រិះក្នុងទ័យា
ចង់ចេញប្រពាតក្រៅភារា យាងទៅទស្សនាក្រុងបារាំង ។
ស្រុកធំអស្ចារ្យនៅប៉ារីស អឺរ៉ុបទ្វីបនេះនៅកំបាំង
មានទីបំផុតសមុទ្រឃាំង ទិសបស្ចឹមឆ្ងាយអនេក ។
តាំងតែអំពីកាលណាមក អាស៊ីទ្វីបលោកជាតិប្លែក
ពុំដែលឃើញស្តែងស្តេចឯក១ ក្លាហានចំឡែកដូចព្រះអង្គ ។
យាងទៅប្រទេសអឺរ៉ុបព្យាង ជៀសវាងជ្រោយបោនអេស្ប៉េរ៉ង់
ទាំងថ្ងៃទាំងយប់ឈប់បង្អង់ សោយស្រង់ផ្ទំក្នុងលោនសាគរ ។
តាមយាកប៉ាល់ព្រះទីនាំង កំលាំងគ្រឿងចក្រធាក់ខ្ទាខ្ទរ
មើលត្រើយមិនយល់ទឹកវល់វរ ក្សត្រថ្លៃភូមរមានបារមី ។
សុខសាន្តបានដល់ស្រុកបារាំង អស់ទាំងនាម៉ឺនមុខមន្ត្រី
រាស្ត្របារាំងសែសទាំងប្រុសស្រី នាំគ្នាថ្វាយជ័យសាធុការ ។
លោកប្រេស៊ីដង់រ៉េពុយប្លិច រៀបអិកធិកយ៉ាងអស្ចារ្យ
ទទួលចមពង្សវង្សខេមរា ប្រពៃថ្លៃថ្លាសមសក្តិសិទ្ធិ ។
រៀបដូចទទួលក្សត្រភូធរ ស្តេចមហាស្តេចនគរទាំងពួងពិត
សម្បើមក្រៃលែងស្វែងបុញ្ញរិទ្ធិ ហាក់ទេពនិម្មិតស្តេចទេវតា ។

ព្រះបាទស៊ីសុវត្ថិខត្យាវង្ស ស្តេចទ្រង់សោមនស្សស្រស់ភក្ត្រា
យាងទតតំណែងទីរាជការ ក្រុងក្រែរដ្ឋាស្រុកបារាំង ។
លោកវ៉េពុយប្លិកនិងកុង្សី សេនាបតីស្តេចចម្បាំង
លោកកាប់ពីតែនកុម្មង់ដង់ ហែព្រះនាដ្ឋទតក្រុមមឿង ។
ល្អក្រៃលែងល្អក្រុងប៉ារីស បូរាណរាជនេះពេញហៅសឿង
មណ្ឌលលំអដោយពណ៌ល្បឿង ស្វាយក្រហមលឿងភ្លឺព្រោងព្រាយ ។
ផ្ទះថ្មបន្តថ្នាក់ជាច្រើនជាន់ ដូចឋានទេវិនជាន់សួគ៌ានាយ
គំនូរក្បាច់ពេជរំលេចសាយ ល្អល្អះពណ្ណរាយឥតប្រៀបបាន ។
លុះស្តេចទ្រង់យាងត្រឡប់មក ក្សត្រថ្លៃពន្លកពង្សអវតាន
ទ្រង់ព្រះសោមនស្សពន់ប្រមាណ ដោយហេតុស្តេចបានឃើញឫទ្ធី ។
មហានគរបារាំងសែស ជាកែស(ព្រះកេស)កំពូលលោកមូលី
ទិន្នករបម្រុងនៅក្នុងទី ខេមរៈធារីប្រពៃណាស់ ។
គ្រិស្តស័កមួយពាន់បួនរយ ប្រាំពីរគ្រាក្រោយប្រវត្តិសាស្ត្រ
រាជព្រះស៊ីសុវត្ថិលួងអម្ចាស់ ពតិមានមួយច្បាស់សម្តែងថា ។
ស្តេចសៀមទ្រង់ឡាយព្រះហត្ថ ចំពោះបារាំងប្រូតិកតូរ៉ា
ប្រគល់ខេត្តបីដីរដ្ឋា មកស្តេចខេមរាដូចរាយឈ្មោះ ។
គឺខេត្តសៀមរាប បាត់ដំបង ស៊ីសុផុនផងពិតចំពោះ
ហេតុបុណ្យតេជៈព្រះទ្រង់យស ខ្ពង់ខ្ពស់ពេកពន់ពីមុនមក ។
កាលឆ្នាំមួយពាន់ប្រាំបួនរយ បួនមុននេះដោយសៀមលែលក
ខេត្តបីដែនដីក្សត្រពន្លក ថ្វាយមកលួងម្ចាស់យើងវិញដែរ ។
គឺទន្លេពៅ និងម្លូព្រៃ ស្ទឹងត្រែងសោតនៃរៀងហូរហែ
សករាជរៀបរាប់ភ្ជាប់ក្រសែ ដូចខ្ញុំបានកែមកហើយស្រាប់ ។

ដល់ឆ្នាំមួយពាន់ប្រាំបួនរយ ដប់បួនខាងក្រោយជាលំដាប់
មហានគរធំចំណាប់ បានថ្លែងទូលស័ព្ទថ្វាយដំណឹង ។
មកព្រះករុណាស៊ីសុវត្ថិ តាមហេតុវិបត្តិបារាំងខឹង
ច្បាំងនឹងអាឡឺម៉ង់ព្រោះចង់ដឹង អាងអួតរបឹងឫទ្ធិរាល់ខ្លួន ។
ព្រះស៊ីសុវត្ថិស្តេចកត្តញ្ញូ ព្រះហឫទ័យស៊ូខ្ជាប់មាំមួន
និងក្រុងបារាំងតាំងពីដូន ជួបជួយថែធួនកម្ពុជា ។
ទ្រង់បានអនុញ្ញាតតាមកំហិត អោយរាស្ត្រស្ម័គ្រចិត្តកុំរុញរា
ចេញទៅជួយច្បាំងតតាំងគ្នា ផ្ដន្ទាអាឡឺម៉ង់បរាជ័យ ។
មហាសង្គ្រាមស្រុកបារាំង ក្លាខ្លាំងសម្បើមគួរភិតភ័យ
ក្នុងលោកលើសលប់ភពដទៃ ស្តេចទ្រង់រំពៃឃើញឧប្បការ ។
គុណស្រុកបារាំងជាប្រាកដ ទើបទ្រង់កំណត់ពង្សាវតារ
ខ្មែរប៉ុន្មាននាក់ដែលមរណា ក្នុងការសឹកសាមសង្គ្រាមនោះ ។
កត់ឈ្មោះចារឹកជាប្រធាន នៅទីវិមានអ្នករងគ្រោះ
មរណៈម៉ូរម៉ង់សង់យ៉ាងខ្ពស់ រំលឹកកេរ្តិ៍ឈ្មោះកងយោធី ។
ខាងជើងវត្តភ្នំក្រុងភ្នំពេញ ចេតិយនោះមិញគេសំភី
មានក្បាលហត្ថីជាសញ្ញី សាងទុកតាំងពីរវាងឆ្នាំ ។
គ្រិស្តស័កមួយពាន់ប្រាំបួនរយ ម្ភៃប្រាំក្រោយខ្មែរដឹងចាំ
គួរជឿសាសនាពាក្យបណ្ដាំ កុំអោយសាំញ៉ាំសន្ដានចិត្ត ។
ម្យ៉ាងទៀតក្នុងរាជព្រះមហាក្សត្រ ព្រះបាទស៊ីសុវត្ថិរាំង្សីសិទ្ធិ
ក្រុងផែនដីខ្មែរប្រែប្រចារិក ចលាចលឥតមានដល់ម្ដង ។
ប្រទេសស្គាល់តែពីក្សេមក្សាន្ត សោយសុខសំរានគ្មានសៅហ្មង
មានប៉ះខ្លះដែរតែពួកពួង តិចតួចចំនងមិនអស្ចារ្យ ។

ពីឆ្នាំមួយពាន់ប្រាំបួនរយ    ដប់ប្រាំពីរដោយមានធម្មតា
មួយទៀតមិត្តភក្តិលាតខេមរា    រីងរិតស្នេហាមួយសារក្រៃ ។
ចំពោះរាជការបារាំងសែស    ពុំមានប្រហែសកិច្ចស៊ីវិល័យ
កែប្រែរបៀបរៀបរាល់ថ្ងៃ    ចំរើនថ្លាថ្លៃព្រះនគរ ។
លួងម្ចាស់ព្រះបាទស៊ីសុវត្ថិ    ប្រពៃពេកក្លាតរីងជំហរ
ទ្រង់ធមិសប្បុរសស្មោះសាទរ    ក្សត្រថ្លៃភូធរថ្កើងបញ្ញើរិទ្ធី ។
រាស្ត្រផងស្រឡាញ់ព្រះអង្គណាស់    កាលជួបប្រទះព្រះបពិត
កណ្តាលផ្លូវក្តីឥតភ័យភិត    ឈរដើរពិនិត្យអង្គចក្រី ។
មើលព្រះអង្គបានជាដរាប    មិនបាច់លត់ក្រាបថ្វាស់ដល់ដី
ដូចពីដើមនោះមនុស្សប្រុសស្រី    ឥតបីខ្លាចក្រែងព្រះចេស្តា ។
តាំងពីឡើងសោយរាជ្យសម្បត្តិ    ចំរើនច្រើនក្លាត់ក្នុងសីមា
មុខជាដំណើរដើរទាន់ការ    តាំងពីកាលណា១មក ។
តិចលោតទៅនគរយើង    មុខជានឹងថ្កើងពេជ្រពន្លក
មានផ្កាមានផ្លែតាមតែយក    រើសយកប្រយោជន៍ភោគសម្បត្តិ ។
ប្រវត្តិសាមសិបកាលពីដើម    កើតសឹកសម្បើមមិនបាត់ស្ងាត់
សត្រូវលុកលុយច្រើនពេកក្លាត់    ក្រក្រៃកំចាត់ពន់ប្រមាណ ។
នាំអោយស្រុកខ្មែរប្រែវិបត្តិ    ដូចព្រេងនាយឥតបើប្រៀបបាន
ហិនហោចរាល់ឆ្នាំកម្មរំខាន    ចំបាំងសព្វឋានសព្វកន្លែង ។
ភូមិណាធ្លាប់មានដល់ដំណាំ    ដាក់ដាំរុក្ខជាតិគ្រប់ដំណែង
ទៅជាមានព្រៃឈើដុះឯង    គួរខ្មែរចំបែងអាណោចចិត្ត ។
របរជំនួញជួញលក់ដូរ    ក៏គ្មានហែរហូរហេតុវិបត្តិ
ធ្វើចំការស្រែខ្មែរមិនស្ទិត    រាស្ត្រផងក៏ឥតទីពុំនាក់ ។

លំបាកវេទនាជាអនេក    ល្ងង់ខ្លៅខ្លាំងពេកមើលមិនជាក់
ខេត្តណាឆ្ងាយណាស់រាស្ត្រផ្អើលភ្ញាក់    មានមនុស្សកាប់ចាក់ចោរលួចប្លន់ ។
លុកលុយញីកញាប់ជាប់អង្វែង    ដុតផ្ទះសម្បែងដើររឹបជាន់
អមនុស្សឃោរឃៅព្យួរទាន់ហន់    ស្លាប់គ្រប់តំបន់តាមផ្លូវថ្លា ។
ឥឡូវស្រុកខ្មែរបាត់អស់ហើយ    គ្មានដូច្នេះឡើយក្នុងភារា
ព្រោះតែបារាំងជួយការពារ    ក្រុងកម្ពុជាសុខក្សេមក្សាន្ត ។
មហាសត្រូវធ្លាប់គុំកួន    គឺសៀមនិងយួនក៏ពុំហ៊ាន
ក្នុងស្រុកកើតសុខសព្វទីឋាន    ជាតិឯងក៏ខានចលាចល ។
ពីព្រោះជាតិខ្មែរទាំងអស់គ្នា    កោតខ្លាចសម្ភារព្រះយោបល់
ស្តាប់វាជាវាទស្តេចខ្លួនផ្ទាល់    លែងគិតរឿងឆ្គល់ថាអ្វី១ ។
ចំណែកខាងពួកចោរកំណាច    ខូចកាចលួចប្លន់ជនប្រុសស្រី
សាបសូន្យអស់ហើយក្នុងបូរី    ព្រោះរាជការថ្មីតាំងអោយមាន ។
មណ្ឌលប៉ុស្តិ៍ស្រុកគ្រប់កន្លែង    តំណែងរាជការពួកទាហាន
ប៉ូលិសឃុំប្រើដើររុករាន    ចោរខ្លាំងក៏គ្មានធ្វើតាមចិត្ត ។
គិញស្ទិរតេដើរស៊ើបការណ៍    ចាប់ចោរមោហាកាចទុច្ចរិត
ស៊ីញ៉ូឡេទ្វេទោសតាមកំហឹង    ធ្វើយ៉ាងប្រៀតប្រិតគ្រប់ក្រសួង ។
តែងរក្សាសុខបណ្តារាស្ត្រ    ច្រើនក្រៃពេញពាសនាម៉ឺនលួង
ដើរមើលត្រួតត្រាការទាំងពួង    ចោរលែងហែងហួងលួចប្លន់បាន ។
ហេតុនេះសុខណាស់ក្នុងភារា    អស់រាស្ត្រប្រជាទាំងប៉ុន្មាន
ទីសង្ឃឹមលើមហាក្សត្រក្សាន្ត    មានចិត្តចង់បានធ្វើការថ្លា ។
ហ៊ានយកគ្រាប់ពូជជាអ្វី១    ដាក់ដាំលើដីភូមិនានា
ដែលរត់ចោលតាំងពីយូរឆ្នាំ    ដូចកាលក្នុងគ្រាមុនវិញដែរ ។

រាជការទំនុកបម្រុងយើង ប្រែរៀបចំឡើងជាប់ហូរហែរ
អស់ទាំងរបៀបរាជការខ្មែរ សឹងតែត្រឹមត្រូវគ្រប់អន្លើ ។
ឥឡូវតម្រូវខាងមន្ត្រី មនុស្សណាគប្បីទើបអោយធ្វើ
រើសយកចំពោះចេះមិនស្មើរ មនុស្សភ្លើភ្លេចភ្លាំងមិនតាំងដែរ។
អស់ពួកមន្ត្រីទាំងប៉ុន្មាន សឹងបានបៀវត្សសំរាប់ខែ
ក្រុមលួងក្រសួងរាជការខ្មែរ សុទ្ធតែរើសយកដោយប្រឡង។
ឈ្មោះណាទទួលប្រាក់សំណូក ស៊ីសូកពីរាស្ត្រដូចម្តេចម្តង
ត្រូវដកឆ្ងាយចេញបណ្តេញផង ចាប់ចងធ្វើទោសកំណត់ឆ្នាំ ។
អំពីរបៀបតុលាការ ក្នុងដែនរដ្ឋាយើងដឹងចាំ
ពីដើមមន្ត្រីកាត់ក្តីក្តាំ ខុសពីចំណាំរឿងដុះស្បៀ ។
អ្នកមានប្រាក់សូកទើបបានឈ្នះ អ្នកទាល់ណាស់បានចាញ់គេ
បិទផ្លូវឧទ្ធរណ៍មិនបើកទេ ក្រែក្រនេះវេណាស់គួរក្តី ។
គ្មានទេចាងហ្វាងតុលាការ ខេត្តណាក៏ដោយក្នុងបុរី
ចៅហ្វាយស្រុកធ្វើអធិបតី ទារពន្ធអ្វីៗនាំដាក់ឃ្លាំង ។
ត្រួតត្រាបណ្តាជនអ្នកស្រុក អោយបានក្តីសុខរួចទុក្ខ
ជម្រះក្តីផងដោយសច្ចាំ ពីផ្ទាំងក្រសួងចៅហ្វាយស្រុក។
បន្ទាប់មកទៀតមានបាឡាត់ សុភាយោក្បាត់ស្មៀនដាក់ស្នុក
ដល់មេឃុំតោងទៅអង្គុយប៉ុក គ្មានទេទូតុអ្វីសរសេរ ។
ឥឡូវនេះណារាជការលួង បំបែកក្រសួងឯកជាទ្វេ
មិនអោយច្រឡូកច្រឡំទេ កាញ់ត្អែតម្រូវតាមត្រូវការ ។
ទី១ ហៅក្រុមរដ្ឋបាល ត្រូវកាលក្រសួងទារពន្ធដារ
ក្នុងខេត្តតំបន់ខ្លួនត្រួតត្រា រក្សាក្តីសុខគ្រប់និគម ។

ទី២ ក្រសួងតុលាការ បង្កើតសាលានៅប្រជុំ
ទីរ៉េស៊ីដង់រួមខេត្តឃុំ សម្រាប់ជំនុំកាត់សេចក្តី ។
គរុលហុបទវិវាទ មជ្ឈិមជាជាតិខ្មែរប្រុសស្រី
កើតមានរឿងរ៉ាវហេតុអ្វីៗ កាត់ក្តីបានតែខ្មែរនិងខ្មែរ ។
សៀមចិនយួនក្លឹងបារាំងគ្រិស្ត តាំងប្រទេសនេះច្បាប់កែប្រែ
មានរឿងទាស់ទែងមិនលែងដែរ ប៉ុន្តែត្រូវប្តឹងទ្រីប៊ុយណាល់ ។
សាលាបារាំងអោយកាត់ក្តី ប្រុសស្រីទាំងអស់ជាឱ៉ាល់
ទីរ៉េស៊ីដង់អ្វីយ៉ង់តាល់ រឿងរ៉ាវអម្បាលម៉ានក៏ដោយ ។
ខេត្តមួយមានរ៉េស៊ីដង់មួយ ហើយភូឈួយស្មៀនរៀបរយ
ថីបកភាសាកត់ត្រាអោយ មុនក្រោយដុះស្បៀរឿងវីវាទ ។
គរុលហុប្ញមជ្ឈឹម អោយក្រឹត្យប្រៀបផ្ទឹមច្បាប់តាមជាតិ
កាត់ក្តីសេចក្តីមិនឃ្លៀងឃ្លាត សំរេចតាមមាត្រាបារាំង ។
ឡឺរ៉េស៊ីដង់ជាចាងហ្វាង ដំណាលរាជការនៅស្រុកតណ្ហស៊ីន
រៀបរយដោយសច្ចំ យុត្តិធម៌ប្រពៃណាស់ ។
សាលាដំបូងទីរួមខេត្ត កត់ហេតុសេចក្តីអោយចាញ់ឈ្នះ
បើកផ្លូវឧទ្ធរណ៍ពេញរង្វះ មិនបិទដូចចាស់ជាន់បុរាណ ។
ថាបើគូក្តីមិនសុខចិត្ត ត្រូវផ្តិតមេដៃកំណត់បាន
ពីរថ្នាក់ទៅទៀតតាមលំអាន ខ្មែរផុតត្រឹមសានវិនិច្ឆ័យ ។
ខាងទ្រីប៊ុយណាល់ទៀតក៏ដែរ សិនតែមិនអស់ចិត្តសង្ស័យ
ត្រូវធ្វើលិខិតផ្តិតម្រាមដៃ ដាក់កំណត់ថ្ងៃសុំឧទ្ធរណ៍ ។
សើរើប្តឹងដល់សាលាធំ នៅទីប្រជុំព្រៃនគរ
អោយរើជំរះយុត្តិធម៌ អោយអសើរីករវរសង្ស័យចិត្ត ។

សាលាដំបូងខ្មែរភ្នំពេញ ក្រុមមឿងនេះមិញមានកម្រិត
របៀបកែប្រែដូចលំអិត ទុកជាកំហិតជាតិបញ្ជ័យ ។
ហៅថាសាលាលុយុនវិញ នៅក្រុងភ្នំពេញយើងសព្វថ្ងៃ
សាងចំកំម៉ង់ទីក្រុងព្រៃ ស្អាតល្អផ្កាថ្លៃសម្រាប់ខ្មែរ ។
មានរឿងកើតទុក្ខមិនសុខចិត្ត ធ្វើពាក្យលិខិតប្ដឹង...
ការទាំងអស់នេះគេបញ្ជាក់ ធ្វើកើតដោយប្រាក់ពន្ធនានា
ដែលរាស្ត្របង់ថ្វាយទាន់វេលា ទុកជារាជទ្រព្យឃ្លាំងសម្បត្តិ ។
អំពីទូរលេខប្រៃសណីយ៍ បង្កើតមន្ទីរច្រើនពេកក្លាត់
ខ្សែល្បបន្តតាមបញ្ញតិ ឆ្លងកាត់កាន់ត្អាគ្រប់ទីក្រុង ។
ចង់ផ្ញើទៅណាសារលិខិត សំបុត្រស្រោមបិទស្រោបបម្រុង
ដាក់ឈ្មោះញាតិមិត្តបិទជិតស្លុង យកទៅដាក់ក្នុងទូរាជការ ។
សំបុត្រទាំងនោះមិនដែលបាត់ បានដល់ឆាប់ក្លាត់ជាសញ្ញា
ឬចង់វាយលួសជាជើងសារ ទៅណាមកណាក៏សឹងបាន ។
គ្រប់ទីតំបន់ក្នុងបុរី បង់ពន្ធសម្តីភាសាអាន
មួយម៉ាត់កាត់យកមិនប៉ុន្មាន យើងឆាប់ដឹងដានដើមដំណឹង ។
មុនឆ្នាំមួយពាន់ប្រាំបួនរយ ដប់ពីរគួរអោយខ្មែរជ្រាបដឹង
យើងផ្ញើសំបុត្រការផ្សេងៗ ពីហ្លឹងទៅខេត្តបាត់ដំបង ។
រវាងប្រាំពីរថ្ងៃទើបដល់ គួរគិតពិផលឆ្ងល់កន្លង
ឥឡូវផ្ញើទៅពីរបីម៉ោង ដល់ហើយអ្នកគោងគិតចំណាំ ។
អំពីមន្ទីរព្យាបាលរោគ កាលពីដើមមកក្នុងមួយឆ្នាំ
គ្រុនចាញ់ជំងឺឈឺប្រចាំ រងកម្មកើតពិសឈើធម្មតា ។
អាហិវាតរោគស្លាប់ទាន់ហន់ ក្មេងតូចអុតស្អន់ជាន់ញាក់ស្មា

មនុស្ស........................ ..................................។
សិស្សណាត្រូវការរៀនបារាំង ភាសាត្រិស្តាំងគ្រូបង្ហាត់
បង្ហាញមើលវាក្យពាក្យសារស័ព្ទ រាជការបានចាត់សាងមណី ។
សាលារៀនសង់ពីថ្មឥដ្ឋ ល្អអស់ពីចិត្តក្នុងធានី
មានគ្រូបារាំងខ្លាំងវិធី បង្រៀនតាំងពីកុមារដ្ឋាន ។
តាំងពីថ្នាក់ទាបដល់ថ្នាក់ខ្ពស់ ពិគ្រោះឃើញគួរធ្វើគ្រូបាន
អោយបុណ្យសក្តិធ្វាជាប្រមាណ នៅក្នុងដែនដានកម្ពុជា ។
អ្នកក្រក៏ដូចជាអ្នកមាន មិនអោយអត់ឃ្លានខ្មែរគ្រប់គ្នា
រាជការអាណិតគ្រប់វេលា ក្នុងគ្រាដែលរៀនអោយប្រឡង ។
យកស្បៀងអាហារបរិភោគដែរ កូនខ្មែរមិនយូនសូនបំណង
មួយទៀតរាជការគិតប៉ុនប៉ង ម្តេចម្តងបម្រុងសង់សាលា ។
អោយច្រើនថែមទៀតសម្រាប់អស់ ខ្មែរនៅកៀនកោះស្រែចំការ
ឆ្ងាយពីទីក្រុងឆ្ងាយសិក្សា រៀនតាមប្រាថ្នាគ្រប់កន្លែង ។
អាវសានកិច្ចទោសប្រវត្តិ មានគ្រប់បែបបទដូច្នេះឯង
ខ្ញុំបានទស្សទាយជាអង្វែង លោកបានសំដែងពន្យល់ថា ។
នគរបែកបាក់បរាក់ហិនហោច ល្វិតល្ហោចខ្ទេចខ្ទីក្រុងសីមា
ដោយកើនចម្បាំងខ្លាំងអស្ចារ្យ ដូចបានថ្លែងការជាលំដាប់ ។
រាជការបារាំងតាំងរៀបចំ មូនមាំរាជថានបានចំណាប់
ក្នុងហាសិបឆ្នាំយើងចាំស្រាប់ ស្រុកវិលក្រឡាប់ប្រែថ្លៃថ្លា ។
ទៅជានគរមួយថ្មីថ្កើង ផុសឡើងនៅក្នុងទ្វីបអាស៊ី
ស្រុកអាំងដូស៊ីនពិនលោកា ស្រុកណាមិនលើសកម្ពុជរដ្ឋ ។
សម្បត្តិសម្បូរឥតសូរយល់ ល្បីល្បាញកេរ្តិ៍ឈ្មោះទៅទៀងទាត់

ផ្ទះផ្សារកំឡុងក្នុងជនបទ រុងរឿងប្រាកដគ្រប់អន្លើ ។
ស្រុកស្រែចំការបណ្តារាស្ត្រ ដាំដុះពេញពាសសព្វសារពើ
ផល្លានុផលផ្លែមើមឈើ រាស្ត្រនាំគ្នាធ្វើចំរើនណាស់ ។
វត្តអារាមខ្មែរដែលសត្រូវ វាដុតចោលទៅពុំទាន់ចាស់
គ្រាកើតចម្បាំងខ្លាំងក្រៃក្រាស់ សាងវិញរហ័សល្អចិញ្ចែង ។
ប្រក់ក្បឿងរុងរឿងជាងពីដើម ស្អាតបាតយ៉ាងឆ្នើមគ្រប់កន្លែង
សាងពីថ្មឥដ្ឋវិចិត្រស្តែង ច្រើនលើសដំណែងជាន់ដើមផង ។
វេលាថ្ងៃបុណ្យទានខត្តបួក មហាជនគរសឹកច្រើនកន្លង
ស្លៀកពាក់សុទ្ធតែស្វាយបៃតង ចិញ្ចៀនកែវកងទំហ៊ូពេជ្រ ។
ខ្សែដៃខ្សែខ្លួនសួនសមល្អ បង់កស្បៃរឿងពណ៌លឿងលេច
ឆ័ត្រព្រៃល្អក្រែសរសៃល្មេច អ៊ុតសក់រួញរេចបំប្រាសស្នា ។
ពាក់អាវសម័យម៉ក្តីរលា អាវពោក៏រ៉េដ៏ជិតស្នា
រំលេចពណ៌ល្អពងក្រសារ ស្បែកជើងឱនផ្កាសែសយមាស ។
ប្រុសៗតែងខ្លួនបីថុង បើកកសំយ៉ុងបះជន្ទាស
ស្បែកជើងស្រោមជើងដើរយាងយាស ចុះបែបដូចរាស្ត្រនៅក្រុងដែរ ។
ខ្លះពាក់មួកសខោបារាំង ខោចិនកន្តាំងហាក់ថៅកែ
រលីងរលើបទំនើបខ្មែរ សុទ្ធសឹងហួលព្រៃមានតម្លៃ ។
ខ្លះស្លៀកសំពត់ជរផាមួង បែបនាម៉ឺនលួងអម្ចាស់ថ្លៃ
ពាក់អាវកុតសស៊ីវិល័យ ឫកពារវិស័យអ្នករាជការ ។
ពាក់នាឡិកាដៃក្រឡៃមាស ជាតិរាស្ត្រមានទ្រព្យធ្លាប់សង្ហា
ដើរមើលបុណ្យទានមានបរិវារ អ្នកស្រែចំការសង់គ្រឹះស្ថាន ។
ផ្ទះរោងផ្ទះប៉ិតផ្ទះហោតិល ធ្វើបង្អួចព្រិលខ្យល់ចូលបាន

| | |
|---|---|
| ប្រក់គ្បឿងគ្រឿងឈើធ្វើផ្ទោងផ្លាន | បិទជាំងពិដានរនាបក្ការ ។ |
| ចាក់ពុម្ពស៊ីម៉ង់ធ្វើជើងតាង | ល្អ១ដោយយ៉ាងផ្ទះខេមរា |
| កំពូលម៉ែត្រស្រួចដូចចេត្យា | ហោណាំងគ្រៀបគ្រាគុកៅអី ។ |
| ទូតាំងចានឆ្នាំងសមស្លាបព្រា | ផ្ទះបាយជិតគ្នាសម្រាប់ស្រី |
| ចំអិនអាហារបាយចំណី | ម្ហូបអ្វី១ឆ្ងាញ់ពិសារ ។ |
| ចេះប្រើរបស់មានតម្លៃ | នៅទីក្រុងក្រៃរាជរដ្ឋា |
| រហូតដល់អ្នកស្រែចំការ | ស្រុកយើងថ្លៃថ្លាពន់ប្រមាណ ។ |
| សម្បូណ៌សប្បាយជាជាងមុន | ដោយសារតែគុណរាជការបាន |
| ទំនុកបម្រុងក្នុងសែនសាន | គ្រជាក់ក្សេមក្សាន្តគ្រប់ប្រការ ។ |
| ព្រះស៊ីសុវត្ថិស្តេចបានសាង | ទុកជាភស្តុតាងក្នុងសីមា |
| រំលឹកព្រះកេរ្តិ៍មហាក្សត្រា | ដូចបានថ្លែងការជាសណ្តាប់ ។ |
| ១ ស្តេចបានសាងព្រះចេត្យា | មួយគួរអស្ចារ្យល្អចំណាប់ |
| ក្នុងវត្តព្រះកែវមានតស្រាប់ | ២ ស្តេចបានចាប់ចាត់ចែងការ ។ |
| សាងព្រះពុទ្ធរូបមានមួយអង្គ | ស្អាតល្អរបាញ់ថ្វាយជេដ្ឋា |
| ព្រះនរោត្តមផ្តាំផ្តាជ្វា | ទុកមុនក្សត្រាវំលត់ខ័ន្ធ ។ |
| តម្កល់ទុកក្នុងវត្តព្រះកែវ | ខាងត្បូងធីមថៃវសុទ្ធមាសតាន់ |
| ៣ សាងវិហារសុវត្ថាន- | ណ្ណារាមក្នុងខ័ណ្ឌស្រុកលើកដែក ។ |
| ៤ ទ្រង់បានសាងព្រះវិហារ | នៅនាភ្នំជីល្អចម្លែក |
| ក្នុងខេត្តជើងព្រៃជិតមាត់ព្រែក | ទុកដល់ខាងផ្នែកផ្លូវសាសនា ។ |
| ៥ សាងទីនាំងភោជនី | ឋិតនៅក្នុងទីវាំងប្រាង្គប្រា |
| ៦ ទីនាំងច័ន្ទឆាយ្យា | ៧ ទេវាវិនិច្ឆ័យ ។ |
| ៨ ទ្រង់កសាងសត្យា | មួយលើបុព្វតាខ្ពស់ស្កឹមស្កៃ |

ភ្នំព្រះរាជទ្រព្យនៅសព្វថ្ងៃ ប្រប់ត្រៃត្រឹងល្អចំណាប់ ។
៩ រុះរើកំផែងវាំង ភ្នំពេញហើយតាំងសាងវិញឆាប់
យ៉ាងល្អតំណព្រះកេរ្តិ៍ស្រាប់ ទី១០ ទ្រង់ចាប់សាងសាលា ។
ប្រាង្គកូ ខេមរៈថ្នាក់ជាន់ខ្ពស់ រួចដាក់នាមឈ្មោះជាសញ្ញា
សម្គាល់ដល់ជនជាតិខេមរា ហៅថាកិលេសស៊ីសុវត្ថិ ។
ទម្លាប់ហៅជាប់ដល់សព្វថ្ងៃ កូនសិស្សច្រើនក្រៃចូលរៀនហាត់
កំណត់៤ឆ្នាំចាំបញ្ញត្តិ ប្រឡងរេញថ្នាត់ធ្វើរាជការ ។
ខ្ញុំចង់រៀនទៀតទៅហាណូយ កំណត់ឆ្នាំក្រោយតាមប្រាថ្នា
ប្រឡងបាស្ស ក្លូរិអា ក្រែងមានវាសនាបានធ្វើធំ ។
ផ្លូវមួយឈ្មោះកេរ្តិ៍ស៊ីសុវត្ថិ យកនាមមហាក្សត្រមកបន្ទំ
បន្ថើតខាងក្រោយឱ្យសមរម្យ រាជការនិយមសម្គាល់ថា ។
ផ្លូវនេះកើតក្នុងរាជព្រះអង្គ ជីកវាយផ្ចិតផ្ចង់ពួកមេការ
ត្រាវើពុយព្លិកសាធារណា តែងថ្វាយក្សត្រាម្ចាស់ផែនដី ។
ជាប់ឈ្មោះពីនោះដល់សព្វថ្ងៃ ក្នុងទីក្រុងក្រៃរាជបុរី
ជនជាតិចំណុះទាំងប្រុស-ស្រី សឹងប្រាប់សេចក្តីឈ្មោះផ្លូវស្រាប់ ។
១១ ទ្រង់សាងបណ្ណារៈ អគ្គេយ៍វាំងភ័ក្ត្រល្អចំណាប់
តម្កល់សាស្ត្រាក្រាំងក្បួនច្បាប់ ទំនៀមទម្លាប់ជាតិខេមរា ។
គម្ពីរបាលីសំស្ក្រឹត បិតកភាសិតប្រែភាសា
វិចនសារៈពុទ្ធិការ ឧត្តមថ្លៃថ្លាជាបំផុត ។
ហៅថាព្រះរាជបណ្ណាល័យ ក្នុងរាជក្សត្រថ្លៃជាចមម្កុដ
ស្តេចមានសទ្ធាសិល្ប៍បរិសុទ្ធ លំអិតតាមច្បាប់សាសនា ។
ប្រទានយសសក្តិសមណភេទ ដែលចេះដឹងវេទត្រ័យសិក្ខា

ក្បួនច្បាប់សម្រាប់រៀនសិក្សា បកប្រែភាសាពាក្យបាលី ។
ជាភាសាខ្មែរខេមរៈជាតិ ពុំមានឃ្លៀងឃ្លាតខ្វះសេចក្ដី
បង្ហាត់កូនសិស្សដែលចូលថ្មី រៀនព្រហ្មចារិយធម៌តាមថ្នាក់ ។
បង្កើតក្រសួងរាជបណ្ឌិត នៅជិតជាប់គ្នាបណ្ណារៈ
ក្បាច់ពន្លាត្រីសូរស្រួចស្រោងស្រាក់ ខ្ពស់ខ្ពង់ទ្រង់ដាក់ប្រាង្គសុវណ្ណ ។
សាលាបាលីទីជាន់ខ្ពស់ សង្ឃកិត្តិយសច្រើនណែនណាន់
កូនសិស្សរៀនស្ដាប់ចិត្តបង្គាប់ ចេះដឹងសំខាន់ច្បាប់សាសនា ។
អ្នកប្រាជ្ញច្រើនអង្គសង្ឃគ្រហស្ថ ទាំងអស់សុទ្ធតែបណ្ឌិតា
មានកេរ្តិ៍នាមឈ្មោះយសសមណា រៀងរាល់រូបាគ្រប់ៗអង្គ ។
គេបានសូនសាងព្រះរូបស្ដេច បែបយ៉ាងស្រស់ស្រេចពីស៊ីម៉ង់
ទុកទីវត្តភ្នំខាងត្បូងត្រង់ អស់អ្នករហង់ចូលបម្រើ ។
ស្ដេចគង់ទីនាំងកៅអីមាស ស័ក្ដិសមឱកាសយ៉ាងប្រសើរ
ក្លោងទ្វារប្រាសាទស្អាតគ្រាន់បើ សាងបែបដំណើរគង់គ្រសាល ។
ព្រះស៊ីសុវត្ថិទ្រង់គ្រឿងក្រុស ភ្លឺប្រះមាសពេជ្ររំលេចប្រាល
ទាហានរក្សាព្រះភូបាល និត្យនៅសព្វកាលទិវារាត្រី ។
លោកបូខូវាំងស៊ីប៉ើរយើ សាងធ្វើផ្លូវស្ពានថ្វាយចក្រី
ព្រះស៊ីសុវត្ថិម្ចាស់សិរសី ច្រើនណាស់ឥតបីបើគណនា ។
គឺស្ពានស៊ីម៉ង់បង្កប់ដែក មាំល្អចំឡែកក្រែមហិមា
កាត់ព្រែកកំពតទីជលធា ឆ្លងទៅតាមធ្លាផ្លូវព្រៃនប់ ។
ស្រែចាមវាលរេញកោះតាកៀវ រថយន្តបើកភ្លៀវភ្លាមចូលម្លប់
រាជឋានដំណាក់ព្រះចមភព មានគ្រប់ផ្ទះហាងបុងកាឡូ ។
លើកំពូលភ្នំពពកវិល ត្រជាក់ធ្លាក់ព្រិលលើបូកគោ

មហន្តរដូវត្រូវជំនោ វាយោត្រជាក់ហាក់ហេមន្ត ។
ហឫទ័យសុខសាន្តសំរានស្បើយ យើងឃើញស្រាប់ហើយគិរីវ័ន្ត
ឡើងជាទីក្រុងក្នុងតំបន់ បែបតាមហន្តឈ្មោះកំចាយ ។
កំចាត់អស់សត្វកាចសាហាវ ចេញក្រៅបំផុតដែលសែនសប្បាយ
ក្រុមសាធារណៈតាក់តែងថ្វាយ ក្សត្រថ្លៃនោមឆាយម្ចាស់ជីវិត ។
ស្ពានថ្មឈ្មោះកេរ្តិ៍ស៊ីសុវត្ថិ យកតាមមហាក្សត្រជានិមិត្ត
ព្រែកកុំពង់បាយឆ្ងាយជីវិត ធ្វើដោយពិនិត្យល្អស្វាវ្យ ។
ចាក់ពុម្ពបេតុងហុងម៉ាកសេ ឆើតឆាយជាងគេទិសទក្ខិណា
ស្នាដៃជាងឆ្នៃពួកមេការ តែងថ្វាយក្សត្រាម្ចាស់សិរសី ។
អង្គព្រះភូមីស៊ីសុវត្ថិ ជាតិជាមហាក្សត្រឆ្នើមបុរី
ប្រសើរលើសលប់ភពផែនដី ថ្មីថ្មើងឥតបីនឹងប្រៀបបាន ។
សោយរាជ្យប្រវត្តិកំណត់ចាំ ម្ភៃបួនឆ្នាំជាប្រមាណ
ជាជាតិអ្នកស្រុកសុខក្សេមក្សាន្ត រាប់អានកោតខ្លាចព្រះចេស្តា ។
ទ្រង់សិល្បិ៍សទ្ធាទីគុណខ្ជាប់ ប្រទានរាជទ្រព្យពួកសមណា
សមណៈជីព្រាហ្មព្រឹទ្ធាចារ្យ ថ្វាយសាធុការដោយរាប់អាន ។
ព្រះជន្មាយុព្រះចក្រី ប៉ែតសិបប្រាំបីវស្សាសាន្ត
ជរាទុក្ខាក្បៀវក្លាហាន វាយដំអង្គប្រាណព្រះមហាក្សត្រ ។
ព្រះឈួនមោគគួនកាន់តែខ្លាំង មរណៈទុក្ខចូលមកស្កាត់
យកដួងវិញ្ញាណឈ្មួនចេញបាត់ មហាក្សត្រសោយទីវង្គតកម្ម ។
ក្រុមព្រះរាជវង្សពង្សវស្សរ៉ា និងលោកសេនាបតីប្រាំ
ក្សត្រី-ក្សត្រាសោយសោកសាំ ឆ្វេងស្តាំកាន់ទុក្ខជាសញ្ញា ។
ធ្វើហុនមេថ្វាយព្រះភ្លើង ស្ដេចយើងរំលត់ជន្មសង្ខារ

អគ្គីដាក់កោដិមាសសុវណ្ណ អ្នកក្រុមប្រឹក្សាអាណាចក្រ ។
និងក្រុមបាគួរបរ៉ោហិត ជិតស្និទ្ធភីលៀងអស់នាងអ្នក
ក្រុមរាជបណ្ឌិតពិនិត្យជាក់ ថ្វាយនាមទ្រង់លក្ខណ៍ថ្មីមួយជា ។
រាជានុកោម្ចាស់សិរសី ព្រះជាតិផែនដីជាតិខេមរា
ប្រជាជនខ្មែរស្រែ-ចំការ ស្រុកក្រុងក្តីណាសោតដឹងចាំ ។
ក្រោយនោះបារាំងប្រូតិតតូរ៉ា និងលោកសេនាបតីប្រាំ
ឯកទោត្រីចត្វាទាំងឆ្វេងស្តាំ ជំនុំចំណាំតាមលំអាន ។
អញ្ជើញសម្តេចព្រះកែវហ្វា មុនីវង្សបុត្រាមហាក្សត្រក្សាន្ត
ឱ្យសោយរាជ្យក្នុងបុរីស្ថាន គ្រិស្តសាសនាបានចំនួនជា ។
មួយពាន់ប្រាំបួនរយម្ភៃ ប្រាំពីរសោតនៃគិតគណនា
ថ្ងៃប្រាំបួនអួតបានឫកពារ ជាពេលវេលាមានជោគជ័យ ។
ព្រះស៊ីសុវត្ថិមុនីវង្ស ស្តេចទ្រង់សោយរាជ្យដោយប្រពៃ
ស្នងព្រះបិតាវិលាល័យ សណ្តោសហាប្ញទ័យតាមរាជការ ។
លោកឡឺវ៉េស៊ីដង់ស៊ុបប៊េរីយើ លោកគួរវេរណើសេណេរ៉ា
ថ្វាយកុភជៈភ័ណ្ឌគ្រឿងសង្ហា ម្កុដពេជ្រមុក្តា និងព្រះខ័ន្ត ។
ស្តេចទ្រង់ព្រះភស្តព្រះភូសារ ភ្លឺផ្លេកអស្ចារ្យចាំងសែងច័ន្ទ
រស្មីព្រោងព្រាតទិព្វសុវណ្ណ បរិស័ទណែនណាន់ចូលថ្វាយជ័យ ។
សព្វសាធុការពរតេជៈ សូមឈ្នះអស់ទុក្ខសោករោគភ័យ
ថ្កើងព្រះកេរ្តិ៍យសខ្ពស់ប្រពៃ ប្រទេសដទៃខ្លាចចេស្តា ។
ក្សត្រក្សាន្តបានរាជាភិសេក ជាឯកចមពង្សវង្សខត្តិយា
ជាបុត្រចម្បងមហាក្សត្រា ឡើងសោយរាជ្យប្រាស្នងព្រះអង្គ ។
រាជានុកោដិជាបិតា ករុណាអាណិតចិត្តស្លូតត្រង់

ហឫទ័យទន់ទោភ័ក្ត្រផូរផង់ ត្រូវតាមបំណងព្រះបិតា ។
កាលថ្ងៃក្សត្រថ្លៃបានបល្ល័ង្ក រាជវត្ដណំ កើតអស្ចារ្យ
ពពកដេរដាសអាកាស្សា បាំងចែកសុរិយាអាប់រស្មី ។
មេឃមីស្រទំភ្នំស្រទាប់ ត្រជាក់សាយសពភូមិផែនដី
ហេតុបុណ្យតេជៈព្រះចក្រី ស្ដេចមានបារមីជាប្រាកដ ។
ព្រះជន្មវស្សាហាពីរឆ្នាំ គេថាដឹងច្បាស់ព្រះរាជប្រវត្តិ
ព្រះកែវហ្វាវង្សពង្សមណីរ័ត្ន សមក្ដីព្រះនាមពង្សាវតា ។
ហៅព្រះស៊ីសុវត្ថិមុនីវង្ស ប្រសើរសមទ្រង់ព្រះរូបា
ស្ដេចមានជណយជោភលើលោកា ក្សត្រាឆើតឆាយព្រមទទួល ។
ព្រះរាជទាយាទពីមាតា និងព្រះបិតាស្រេចស្រួលបួល
រាឃ្លេផងគីកកងច្រើនខ្មៅឃ្មួល ជ្រើមជ្រួលថ្វាយពរសព្វសាធុការ ។
ក្រោយថ្ងៃកសត្រថ្លៃបានបល្ល័ង្ក រាជវត្ដណំស្រេចកាលណា
ទ្រង់ព្រះសណ្ដោសប្រោសមេត្តា ពួកសេវាកាមាត្យមន្ត្រី ។
ពីរនាក់ឡើងថ្នាក់ជាសម្ដេច ខ្ពង់ខ្ពស់សម្រេចលើកុង្សី
ផុតលេខថ្កើងពេកក្នុងលោកីយ ប្រុស-ស្រីខេមរៈដឹងជាក់ថា ។
១ ព្រះកែវហ្វានាម្នាជូន រូបល្អសមសួនទីឧកញ៉ា
ក្រុមព្រះរាជវាំងឃ្លាំងរចនា ស្រីស្នំបរិវារគាល់បម្រើ ។
ទី២ ឧកញ៉ាចក្រីប៊ុន រស្មីព្រះសីតុនគាប់ប្រសើរ
ក្រសួងមេសឹកថ្មីកគ្រាន់បើ ទ័ពដើររទេះសេះដំរី ។
ការពារប្រទេសនិវេសន៍វាំង រក្សារដ្ឋទ័ពផែនដី
សត្រូវខាងក្នុងក្រៅបុរី អមអង្គចក្រីម្ចាស់ជីវិត ។
ដល់ពេលខាងក្រោយដោយព្រះអង្គ មានព្រះចំណង់ដោយទសពិត

ព្រះចិន្តាភ្ញាក់លែលកគិត ថារាស្ត្រនៅជិតទាំងប៉ុន្មាន ។
សឹងស្គាល់ព្រះអង្គមិនចន្លោះ ទាំងអស់ជិតខាងទីប្រាង្គឋាន
រាស្ត្រនៅឆ្ងាយៗទាំងឡាយខាន ពុំបានស្គាល់ភ័ក្ត្រព្រះអង្គសោះ ។
ចង់យាងប្រទក្សិណនគរ ហឫទ័យសាទរដោយសប្បុរស
ចង់ឱ្យរាស្ត្រស្គាល់រាល់ចន្លោះ ទាំងអស់ក្នុងដែនអាណាចក្រ ។
ព្រះអង្គទ្រង់មានព្រះឱង្ការ ប្រាប់ប្រួតិតតូរ៉ាថាទ្រង់ស្ម័គ្រ
គិតយាងទតក្រុងគ្រប់ដំណាក់ ខេត្តក្រៅមែនជាក់ពិតប្រាកដ ។
លោកឡឺរ៉េស៊ីដង់ស៊ុប៉េរីយើ នាយកត្រួតលើកម្ពុជរដ្ឋ
គំរាស់ព្រះចក្រពត្តិ ប្រាកដថ្ងៃខែខ្មែរបារាំង ។
ផ្ញើទៅរ៉េស៊ីដង់ទីរួមខេត្ត បញ្ជាក់រឿងហេតុជាទីតាំង
កំណត់វេលាក្សត្រាជ្ញ យាងទតអស់ទាំងខេត្តនានា ។
ដល់ថ្ងៃក្សត្រថ្ងៃឡើងគង់យាង រថយន្តដែលមានក្រុមភ្នាក់ងារ
ហែរហមអមអង្គព្រះរាជា សម្ដេចចៅហ្វានាម្មាជូន ។
សម្ដេចចក្រីក្សុំខ្មែរ តាមហែទីនាំងវៀងរាល់ខ្លួន
ឧត្តមសេនីយ៍សក្តិបី-បួន ហែស្ដេចទតសួនស្រែចំការ ។
គ្រប់ទីរ៉េស៊ីដង់ទីរួមខេត្ត បុព្វហេតុឱ្យរាស្ត្រស្គាល់ភ័ក្ត្រា
ព្រះចៅចមពង្សវង្សខេមរា បរិវារគ្នាគននាគម ។
ប្រជាជនខ្មែរស្រែ-ចំការ ឧស្សាហ៍ដើរឆ្លងដងព្រៃភ្នំ
ប្រមូលសាច់ញាតិជាតិនិយម អ្នកផ្សារតូចធំគ្រប់កន្លែង ។
ស្រុកប៉ុស្តិ៍ចំណុះអាណាចក្រ បង្គំគារវៈស្ដេចតម្កែង
ណែនណាន់តាន់តាប់ស្ដាប់សូរសែង សូរសៀងស្ដេចថ្លែងព្រះឱង្ការ ។
ក្សត្រថ្លៃមុនីវង្សទ្រង់ធម៌១០ ប្រទានរាជទ្រព្យអ្នកសមណា

សមណៈជីព្រាហ្មអនាថា ទ្រង់ប្រោសមេត្តាមនុស្សកំសត់ ។
ក្រីក្រលំបាកតោកយ៉ាកខ្លាំង ចំណាយប្រាក់ឃ្លាំងបុរីរដ្ឋ
ប្រទានរាស្ត្រខ្មែរក្បែរជនបទ ទ្បេងទាត់ហូរហែរាល់ខែថ្ងៃ ។
នគរកើតសុខស្រុកថ្កុំថ្កើង លេចឡើងធនធានមានតម្លៃ
មាសពេជ្ររំលេចត្បូងចរណៃ សម្បូណ៌ពេកក្រៃកម្ពុជា ។
ស្រុកគ្មានប៉ះបោរចលាចល មូលដល់រុក្ខជាតិផងនានា
រាស្ត្រដាំព្រួសផ្សាំដាក់ពូជវា ផលស្រូវចាក់ធាជង្រុកក្រង់ ។
ស៊ីចាយមិនអស់របស់ទ្រព្យ អ្នកធ្លាប់ក្រប្រាក់គ្មានដាក់ផង
ត្រឡប់ជាមានហ៊ានខាតបង់ ទិញកង់ម៉ាកហ្វាសង្ហាដែរ ។
ព្រះបាទមុនីវង្សទ្រង់ចេស្តា ករុណាអាណិតជនជាតិខ្មែរ
ដាស់តឿនប្រារព្ធគ្រប់ឆ្នាំខែ ឱ្យរាស្ត្រគិតតែខំរកស៊ី ។
ធ្វើរបងផ្លូវស្រូវជំនួញ ចេញជួញថែមទៀតឆ្លៀតឆ្លងទី
កាប់ព្រៃរានដីមានជាតិជី ដល់ព្រះធរណីស្រែ-ចំការ ។
មិនតែប៉ុណ្ណោះព្រះអង្គឯង ទ្រង់បានសម្តែងព្រះប្រាជ្ញា
ឱ្យរាស្ត្រផងដឹងប្រឹងឧស្សាហ៍ ធ្វើស្រែ-ចំការឱ្យមាំមួន ។
អម្បាលព្រះអង្គជាស្តេចស្តែង ទ្រង់ស្វែងរកកាលក្រសាលសួន
ធ្វើចំការស្រែយ៉ាងថៃធួន រាស្ត្រខ្មែរចិនយួនសោតដឹងថា ។
ព្រះអង្គមានស្រែច្រើនពេកក្តាត់ នៅខេត្តពោធិសាត់ទិសឧត្តរ
តែងយាងចេញទតពួកកម្មការ ធ្វើស្រែ-ចំការចម្រើនណាស់ ។
១ឆ្នាំបានស្រូវរាប់រយថាំង ក្រុមលួងក្នុងវាំងទាំងក្មេងចាស់
មិនបាច់ទិញផ្សារក្រយាម្ចាស់ ព្រះញាតិប្រើប្រាស់ចាយមិនអស់ ។
ស្តេចប្រើឧបាយឱ្យរាស្ត្រយល់ ធ្វើតាមទសទាយមិនក្រសោះ

ដីច្រើនទូលាយឆ្ងាយកាប់គាស់ ភ្ជួររាស់ស្ទូងស្រូវរដូវភ្លៀង ។
របរធិការច្បារដំណាំ ដាក់ដាំរុក្ខជាតិឥតឃ្លាតឃ្លៀង
បានផលប្រាកដជាទាត់ទៀង អ្នកមាន .... មិនលើសដែរ ។
ព្រះអង្គទ្រង់មានក្តីស្នេហា អ្នកបុព្វជិត្តាលោកសង្ឃខ្មែរ
គ្រប់វត្តកំសត់ក្រុងឬស្រែ ឬមួយនៅក្បែរព្រះរាជវាំង ។
បានយល់ព្រះសង្ឃឱ្យកាន់តាម វិន័យព្រះហាមជាទីតាំង
សង្រួមឥន្ទ្រីទីបិទបាំង កុំបីភ្លេចភ្លាំងភ្លាត់ស្មារតី ។
ពុំគួរគោចរចូលផ្សារធំ អង្គុយឆាន់នំបាយចំណី
ក្នុងតៀមភៅចិនមិនគប្បី ប្រុសស្រីច្រើនជ្រៀតចង្អៀតគ្នា ។
ព្រះអង្គគ្រប់អង្គប្រាថ្នាល្អ អាក់ទានគោចរតាមផ្លូវថ្លា
ផ្សារក្រុងកុំលុងដែនភារា ខ្លាចព្រះរាជាស្តេចប្រកាន់ ។
មួយយ៉ាងសង្ឃសាងត្រៃសិក្ខា ត្រូវការគោរពច្បាប់សំខាន់
តាមក្រឹត្យបន្ទាត់បទកំណាន់ បួសហើយរន្ទាន់រៀនឱ្យសព្វ ។
ព្រះបាទមុនីវង្សទ្រង់បានសាង ទុកជាតំណាងព្រះកេរ្តិ៍គាប់
ក្នុងរាជប្រវត្តិកំណត់រាប់ រៀបរៀងចាំចប់ដឹងគ្រប់គ្នា ។
ទី១ ស្តេចតាំងក្រុមជុំនុំ ជួបជុំបណ្ឌិតប្រាជ្ញព្រឹទ្ធា
គ្រហស្ថបុព្វជិតគិតគណនា ប្រែបាលីជាភាសាខ្មែរ ។
គម្ពីរបិតកទាំងបីបទ ស្រង់កត់សេចក្តីបាលីប្រែ
ព្រះសូត្របាលីអភិធម្មេ ប្រៀបផ្ទឹមធួនថែព្រះពុទ្ធដិការ ។
មិនឱ្យខ្វះខាតបាតបាលី ព្រមទាំងសេចក្តីអត្ថៈ
បោះពុម្ពផ្សាយចេញពេញរដ្ឋា វត្តសង្ឃខេមរាអាណាចក្រ ។
សឹងមានសៀវភៅបិតកស្រាប់ បោះទុកជាច្បាប់ស័ព្ទវចនៈ

ពាក្យពុទ្ធោវាទស្អាតគ្រប់ថ្នាក់ គ្រហស្ថ.....បុគ្គលក្តី ។
ព្រះអង្គប្រកបព្រះបញ្ញា សទ្ធាមុតថ្លាដូចព្រះកែវមណី
យាងត្រូវតាមផ្លូវទាំងប្រាំបី សាងទានបារមីធំអស្ចារ្យ ។
ទី២ ស្តេចសាងព្រះដំណាក់ មួយល្អសមសក្តិអនេកា
នៅទីជ្រោយកែបបែបប្រាង្គប្រា ទិសទក្ខិណាច្រាំងសមុទ្រ ។
ក្នុងខេត្តកំពតមាត់កំពង់ ប្រៀបផ្តល់វែងវឹងភ្នំកំបុត
ទឹកមេឃក្រឡេកមើលមិនផុត វាយោបរិសុទ្ធសមុទ្រជ្រៅ ។
ទ្រង់យាងប្រថាប់រាប់ឆ្នាំខែ តាំងតែពីសោយរាជ្យព្រះចៅ
កសាងតម្រូវរដូវក្តៅ សមុទ្រទឹកខ្មៅខ្យល់ត្រជាក់ ។
ទីស្តេចសាងប្រាង្គប្រាសាទ មួយទៀតនៅក្តាត់ក្នុងទឹករាក់
ជាទីបែបប្រែធិន្តា តាមកិច្ចប្រាថ្នាព្រះភូបាល
តំណាក់ចំណតស្ពានហាល សាងតាំងពីកាលទ័យបឋម ។
តំណាក់មួយនៅកំពង់បាយ ទីជិតមិនឆ្ងាយខាងជើងធំ
ខាងកើតមាត់ព្រែកឯកស្ងួនសម មហាក្សត្រឧត្តមយាងប្រថាប់ ។
ឧត្តរផ្សារក្រុងបុងមាកសេ ដំណែលខត្តិយល្អចំណាប់
ដំបូលប្រក់ក្បឿងគ្រឿងប្រដាប់ រាជទ្រព្យសម្រាប់មហាក្សត្រា ។
ទី៤ ដំណាក់ត្រពាំងជង សាងបែបទំនងល្អអស្ចារ្យ
សម្រាប់ស្តេចយាងទតស្ងួនច្បារ នៅទីនាមថា ខេត្តពោធិសាត់ ។
គូលីរក្សាច្បារដំណាំ មាននៅប្រចាំប្រុងប្រយ័ត្ន
ធ្វើស្រែថែស្ងួនមាំមួនក្តាត់ ច្រូតកាត់បញ្ជូនស្រូវពាន់ថាំង ។
ទី៥ ទៀតមានស្ពានស៊ីម៉ង់ ធំវែងសាងគង់កន្លែងយាំង
ផ្លូវរថយន្តដើរប្រើកម្លាំង ម៉ាស៊ីនប្រេងសាំងដែកគ្រឿងចក្រ ។

ស្ពាននោះលោះទោះជ្រោយអាអោក រថយន្តទៅមកស៊ើរឥតអាក់
ឆ្លងកាត់ទន្លេឈ្មោះបាសាក់ ផ្លូវកម្ពុជៈព្រៃនគរ ។
នៅជាយខាងត្បូងក្រុងភ្នំពេញ ឯស្ពាននោះមិញរឹងជំហរ
បារាំងមេការសាទរ សាងថ្វាយភូធរម្ចាស់ផែនដី ។
ច្រើនតោនទម្ងន់ធ្ងន់អស្ចារ្យ ពួកជាងរចនាមានឈ្មោះល្បី
គ្រានៅពុយព្លិចសាងបុរី ថ្វាយព្រះចក្រីស្ដេចខេមរា ។
ស្ពាននោះកើតក្នុងរាជព្រះអង្គ ដង្វាយផ្ចិតផ្ចង់ប្រូតិតតូរ៉ា
ទំនុកបម្រុងក្នុងរដ្ឋា ប្រសើរថ្លៃថ្លាសក្តិសមទ្រង់ ។
បញ្ញត្តិនាម្នាជាកិត្តិយស ហៅឈ្មោះថាស្ពានមុនីវង្ស
ខ្សែទឹកទន្លេពីមេគង្គ ខែជន់លិចលង់ព្រៃព្រឹក្សា ។
ធ្វើពីស៊ីម៉ង់ដែកបង្កប់ មាំជាំក្រៃលែងវែងអស្ចារ្យ
សណ្ឋានស្រួចស្រោងកោងដៃស្ពា វារីឆាយាឥន្ទធនូ ។
ពួកឥន្ទនាំនាវាចក្រ កប៉ាល់បាសាក់ចេញចូលធូរ
ឆ្លងស្ពានឥតមានព្រួយគិតគូរ ផែនទីគំរូស្រុកបារាំង ។
ក្សត្រថ្លៃមុនីវង្សទ្រង់រាជា ព្រះជន្មាចមនាដ្ឋិ
ហុកសិបប្រាំបួនវស្សាន្ត មរណៈកម្មំសំខារា ។
សោយទីវង្គតរលត់ជាតិ វិញ្ញាណចេញឃ្លាតទៅកាលណា
គ្រោងកាយដូចអប់ខុសធម្មតា ផ្ទំលើយំនាឈើងសូន្យសោះ ។
ក្រុមព្រះរាជនុវង្ស ក្សត្រីក្សត្រាសោកស្រណោះ
កើតទុក្ខទឹកមុខស្ងួតក្រៀមក្រោះ ស្រីស្នំទាំងអស់សង្រេងក្រៃ ។
មន្ត្រីកុង្សីគ្រប់ក្រសួង ក្រុមភ្នាក់ងារលួងអម្ចាស់ថ្លៃ
ទុក្ខខ្លាំងពន្លឹកនឹកស្រមៃ គ្រប់ពេលយប់ថ្ងៃឥតស្រាកស្រាន ។

ក្នុងវាំងក្រៅវាំងទាំងអ្នកស្រែ ក៏សោយសោកដែរធន់ពុំបាន
រាស្ត្រក្នុងផែនដីបុរីដ្ឋាន សឹងបានកាន់ទុក្ខគ្រប់ៗគ្នា ។
បុណ្យព្រះមេរុថ្វាយអគ្គី ក្សត្រថ្លៃភូមីមុនីនា
ធ្វើតាមទម្លាប់សពរាជា ក្នុងទិភាភាភពផែនដី ។
រើសព្រះអដ្ឋិសិរីរៈ អញ្ជើញស្តេចដាក់ក្នុងកោដិថ្មី
ដាក់ព្រះរាមាព្រះចក្រី តាមពាក្យបាលីសេចក្តីថា ។
លួងខត្តិយសកោដិមុនីវង្ស ព្រះចៅចមពង្សស្តេចខេមរា
ទ្រង់ទីវង្គតផុតសង្ខារ ក្សត្រាសោយរាជ្យ ១៤ឆ្នាំ ។
ដូចបានបរិយាយរួចមកហើយ អស់លោកអ្នកអើយល្មមដឹងចាំ
អានរាជប្រវត្តិកត់ចំណាំ កុំឱ្យសាំញាំពេលវេលា ។
ឡឺរ៉េស៊ីដង់ស៊ុបប៉េរីយើ លោកគួរវេរណីជួយគាំពារ
ចូលមកជួបជុំក្នុងភារា ជំនុំព្រមគ្នាលោកកុង្សី ។
និងក្រុមប្រឹក្សាអាណាចក្រ ព្រមស្ម័គ្រលើករាជស្តេចផែនដី
ថ្វាយព្រះសីហនុរំពេចខ្មី សោយរាជ្យបុរីកម្ពុជា ។
គ្រិស្តមួយពាន់ប្រាំបួនរយ សែសិបមួយក្រោយគិតគណនា
ព្រះនរោត្តមគោត្រសោភា នាម្មាសីហនុវរ៍ន ។
ព្រះជន្មវស្សាម្ភៃឆ្នាំ គេចាំប្រវត្តិរដ្ឋសុវណ្ណ
ព្រះញាតិវង្សគង់ណែនណាន់ គាន់គាប់ច្រើនច្រៀតចង្អៀតគ្នា ។
ចូលថ្វាយព្រះពរវរៈវុឌ្ឍី តាមព្រះវេណីទីភារា
សូមឱ្យចម្រើនយឺនទីឃា យូរយារមួយរយម្ភៃឆ្នាំ ។
លោករ៉េស៊ីដង់ស៊ុបប៉េរីយើ លោកគួរវេរណីអមឆ្វេងស្តាំ
ក្សត្រថ្លៃចមពង្សគង់ប្រចាំ ព្រមព្រះមេរាំស្វេតឆ័ត្រ ។

លើព្រះទីនាំងបល្ល័ង្ករត្ន ដាំពេជ្រមរកតខៀវស្រងាត់
អភិសេកស្រោចទឹកថ្វាយមហាក្សត្រ ភក្រ្កាល្អក្តាត់ដូចដួងច័ន្ទ ។
លោកគួរវេរណីត្រូតតំបន់ ថ្វាយកូតភ័ណ្ឌព្រះខ័ន
ព្រះបាទសីហនុវរ្ម័ន មានបុណ្យសំខាន់ថ្កើងអស្ចារ្យ ។
បានទីអភិសេកឯកចមពង្ស ចមពោធិវង្សស្តេចខេមរា
ពេញវ័យម្តៃព្រះវស្សា ក្សត្រាឡើងសោយរាជ្យសម្បត្តិ ។
កំសួលចម្បាំងខ្លាំងលើសលុប ខាងទ្វីបអឺរ៉ុបមិនស្ងប់ស្ងាត់
អាល្លឺម៉ង់អ៊ីតាលីរានទឹកក្តាត់ វាយកាត់ឆ្លងដល់ក្រុងមូស្គូ ។
ជប៉ុនវាយចិនកិនមិនឈប់ ទាំងថ្ងៃទាំងយប់អង្វែងយូរ
ហិនហោចខ្លោចផ្សាការតស៊ូ ពួកស្គួលជាគ្រូការចម្បាំង ។
យ៉ាងធំចម្បងឆ្លងរានទី ដល់ទ្វីបអាស៊ីទីបូព៌ា
គ្រប់ស្រុកមិនសុខជ្រួលជ្រើមខ្លាំង សាយពេញទូទាំងទ្វីបលោកអាយ ។
គ្រិស្តស័កមួយពាន់ប្រាំបួនរយ សែសិបបីក្រោយមានចំបាយ
ចម្បាំងទី២រីករាលសាយ វែងឆ្ងាយដល់ស្រុកខ្មែរលាវយួន ។
ជប៉ុនដឹកទ័ពរាប់មិនអស់ ពលហោះជើងទឹកសន្ធឹកធួន
.....កប៉ាល់កង្ហារបួន ច្រើនពេញចំនួនកងសេនា ។
ចូលឥណ្ឌូចិនពិតពិភព ច្រើនក្រៃលើសលុបឥតឧបមា
ឆ្លងដល់ស្រុកសៀមគ្រៀមគ្រៀបត្រា វាយយកម៉ាល់កាស្រុកហុងកុង ។
កោះជ្វានាម្នាសុមាត្រា ហ្វូឡង់ឥស្សរ៉ាគ្រួតបម្រុង
សាំងហ្គាពួធានីអ៊ុយរីយ៉ុង នៅក្នុងកណ្តាប់ដៃអង់គ្លេស ។
និងស្រុកភូមាក្រុងរ៉ង់ហ្គូន ជប៉ុនវាយផ្ទួនដូចគេផ្ទេរ
យកបានទាំងអស់មិនយូរទេ ក្នុងមួយមាស្សេថែមកន្លះ ។

គ្រិស្តស័កមួយពាន់ប្រាំបួនរយ    សែសិបប្រាំក្រោយប្រាំបួនម៉ាស៊្យ
យប់ម៉ោង១៣យុទ្ធសាស្ត្រ    ជប៉ុនប្រកាសសង្គ្រាមស្ងាត់ ។
លើកទ័ពចេញចាប់ជាតិប្រាំងសេ    អាំងដូស៊ីណ្ណេដេញកំចាត់
ផ្តួលប្រូតិតតូ៉ារលាយបាត់    បារាំងខ្ចាយខ្ចាត់ដើរចេញឯង ។
ប្រគល់ឯករាជ្យរាជការថ្មី    ថ្វាយម្ចាស់ផែនដីគ្រប់កន្លែង
សាសន៍ខ្មែរលាវយួនអរក្រៃលែង    រួចពីតំណែងទាសកកម្ម ។
បម្រើប្រទេសរាជបារាំង    លំបាកយ៉ាងខ្លាំងអង្វែងឆ្នាំ
សំណាងបុណ្យក្រាសសាសន៍ទាំងប្រាំ    ស្បើយទុក្ខសោកសាំឆាប់ទាន់ចិត្ត ។
មិនយូរប៉ុន្មានសោះស្រាប់តែ    បានប្រាំពីរខែប្រែវិប្បរិត
អាមេរិកាំងទម្លាយល្ហោចល្អិត    គេឿកកិតអាងទ័ពរាប់កោដលាន ។
មូស្គូរុស្ស៊ីចិនទីបេ    បារាំងអង់គ្លេសចូលចងស្ពាន
សម្ព័ន្ធមិត្តមូលចូលរុករាន    ឈ្នះឈ្នានយកបានរោមបែកឡាំង ។
ជប៉ុនទ័ពគ្រុននៅម្នាក់ឯង    កណ្តែងកណ្តាលទីចម្បាំង
ស្លាប់ពាន់ចូលម៉ឺនព្រហើនខ្លាំង    ចូលយុទ្ធតាំងការពារខ្លួន ។
អាមេរិកាំងបោះគ្រាប់ប៉ារ៉ាម៉ាណូ    វាយក្រុងតូក្យូគ្រួតផ្ទួន២
ពីរគ្រាប់ស្លាប់រាស្ត្រអស់ចំនួន    ជាប់មួយលានបួនទ្រាំពុំបាន ។
ស្តេចស្រុកជប៉ុនសុំឈប់ច្បាំង    គ្រឿងយុទ្ធភណ្ឌទាំងប៉ុន្មាន
ប្រគល់ឱ្យគេឥតសល់ខាន    សូមរួចតែប្រាណពលសេនា ។
ក្រោយនោះអង់គ្លេសនិងបារាំង    ចូលមកស្រុកឥណ្ឌូស៊ីណេជា
ហូតយកអាវុធមុខមុតថ្លា    ប្រដាប់ប្រដាសឹកចម្បាំង ។
ពីទ័ពជប៉ុនគ្រប់ប្រទេស    អង់គ្លេសវិលទៅបារាំង
អាងពលទាហានមានរិទ្ធិខ្លាំង    ធ្លាប់គ្រួតស្រុកអាំងមកយូរយា ។

ដឹងថាជប៉ុនឱ្យឯករាជ្យ រករឿងជជែកស្រែកផ្ទុះ
ថាមហាប្រទេសគ្រប់ភាសា មិនយល់ព្រមគ្នាស្តាប់ផងទេ ។
ឯករាជ្យជាន់មុនជប៉ុនឱ្យ មិនត្រឹមត្រូវដោយខ្វះស៊ីញ៉េ
តួក្បួនបរាជ័យចាញ់គេ ហិនហោចពលរេទ្រាំមិនបាន ។
ជប៉ុនអាប់សូន្យអស់ឫទ្ធា ប្រទេសនានាអម្បាលមាណ
ក្នុងលោកដឹងព្វគ្រប់ដែនដាន កុំស្មានអាងគេយកជាគ្នា ។
អំណោយឯករាជ្យលាវខ្មែរយួន ក៏មិនមាំមួនតាមវេលា
បារាំងវិលមកជួយគាំពារ ក្រុងកម្ពុជាដោយមេត្រី ។
សហព័ន្ធមួយអន្លើ ការងារត្រូវធ្វើក្នុងបុរី
រួមគ្នាជាមិត្តគិតក្នុងបុរី ត្បិតអីបារាំងមិនដាច់ចិត្ត ។
ស្រឡាញ់រាប់អាននគរខ្មែរ សូមនៅជួយថែឯបដិតស្និទ្ធ
ការពារសត្រូវផ្លូវទុច្ចរិត តាមច្បាប់ក្រមក្រឹត្យព្រះមហាក្សត្រ
ខាងក្រៅខាងក្នុងប្រុងយុទ្ធភ័ណ្ឌ ឱ្យមានគ្រប់គ្រាន់ការប្រយ័ត្ន
លប់ប្លូតិតតូវ៉ាមួយម៉ាត់ ថ្វាយព្រះមហាក្សត្រម្ចាស់បុរី ។
ហៅថានគរសាខារដ្ឋ ជនបទបែកមែកស្លឹកខៀវខ្ចី
រាជការបារាំងចំណូលថ្មី កែប្រែសេចក្តីខុសញ្ញា ។
លប់ទីរ៉េស៊ីដង់ស៊ុបេរីយើ និងគូវេរណឺបុស្តិ៍ត្រួតត្រា
មិនឱ្យមានទេក្នុងសីមា តាំងគម្ម៉ីសែរិយ៉ាម្នាក់ឈរស្តី ។
ស្រុកខ្មែរមានគម្មិសែមួយ ឈរអែបជិតជួយប្រាប់កុង្សី
ឱ្យក្រុមទាហានពលសេនី រក្សាបុរីស្រុកខេមរា ។
ខេត្តមួយត្រូវតាំងបារាំងម្នាក់ យសស័ក្តិដំណែងទីប្រឹក្សា
អមចៅហ្វាយខេត្តជំនុំការ ទើសទាល់ត្រង់ណាត្រូវពិគ្រោះ ។

សួរក្រុមប្រឹក្សាកុំបង្អង់ គ្មានទីរ៉េស៊ីដង់ខេត្តចំពោះ
ក្រសួងដទៃមានច្រើនឈ្មោះ ត្រូវកិត្តិយសនាម៉ឺនខ្មែរ ។
ក្រោយនោះលួងម្ចាស់ព្រះករុណា ទទួចតវ៉ាសុំហូរហែ
រាជការបារាំងខ្លាំងពូកែ ព្រមប្រែសិទ្ធិសាខារដ្ឋ ។
ហៅថានគរស្វ័យរាជវិញ បំពេញព្រះទ័យព្រះចក្រពត្តិ
សហភាពផលដល់កំណត់ តាមក្រឹត្យបន្ទាត់បារាំងខ្មែរ ។
បារាំងមកពាំងធ្វើជិទាស់ ឯករាជ្យខូចអស់មិនត្រឹមតែ
ស្រុកកម្ពុជាលាវយួនដែរ សុទ្ធតែកើតទុក្ខមិនសុខចិត្ត ។
គៀសខ្លួនពួនព្រៃធ្វើឥស្សរៈ ដែលកម្ពុជៈទាំងប៉ុន្មាន
ទារយកសិទ្ធិរដ្ឋរាជស្ថាន ដោយចិត្តក្លាហានឥតកោតក្រែង ។
គ្រិស្តស័កមួយពាន់ប្រាំបួនរយ សែប្រាំបួនក្រោយឆ្នាំនេះឯង
បារាំងព្រមព្រៀងជៀងដាក់ស្តែង ប្រគល់ដីណែងឯករាជ្យខ្មែរ ។
ថ្វាយព្រះសីហនុអម្ចាស់ថ្លៃ ទាន់កាលសម័យតាមសុំដែរ
គ្រឿងសាស្ត្រាវុធមុតពូកែ មិនព្រមថ្វាយផ្តែថ្វាយតែស្រោម ។
ក្រុមខ្មែរឥស្សរៈមិនសុខចិត្ត ព្រោះត្បិតបារាំងធ្វើប្រលោម
ប្រឡំឱ្យតែខ្មែរយល់ព្រម នេះហៅចង្កោមនយោបាយ ។
គេកាន់កាំភ្លើងយើងកាំបិត តូចចិត្តហួងសៅក្តៅក្រហាយ
គ្រប់ខេត្តខ័ណ្ឌឃុំពុំរសាយ សោកស្តាយសិទ្ធិឯករាជ្យឫទ្ធិ ។
បារាំងមិនទៅនៅពេញពាស ដើរធ្វើបាបរាស្ត្រខ្មែរឆ្ងាយជិត
ប្រកាន់ថារាស្ត្រសមគំនិត នឹងឥស្សរពិតមែនប្រាកដ ។
លើកអស់ទាហានពុំមានឈប់ ទាំងថ្ងៃទាំងយប់គ្មានកំណត់
ចាប់ចងថងធាក់អ្នកជនបទ រាស្ត្ររត់ប្រាស់ព្រាត់ចោលគ្រឹះស្ថាន ។

ទាហានតាមខ្មាញ់បាញ់ពង្រុះ ខ្លះត្រូវខ្លះខុសរស់រួចបាន
ខ្លះបាក់ជើងដៃក្ស័យទាំងប្រាណ ទ្រព្យធនទាំងប៉ុន្មានវិនាសអស់ ។
ខ្មែរឯករាជ្យបារាំងឱ្យ ប្រែជាក្បត់ខ្សោយពុំគួរសោះ
ប្ដីព្រាត់ប្រពន្ធធនទ្រព្យ ស្ត្រីព្រាត់បុរសស្វាមីមិត្ត ។
គេតាមបាញ់ដូចប្រើស-ក្ដាន់ ចាប់ចងប្រកាន់បទទុច្ចរិត
ដូចពោលខាងលើធ្វើមិនពិត ប្រព្រឹត្តរករឿងមិនចេះចប់ ។
ព្រះបាទសីហនុវ័រ្មន ទ្រង់កាន់ទសពិតរាជធម៌ដប់
ហឫទ័យសង្កេតភេទមិនគាប់ ស្ងប់ស្ងាត់គានតឹងព្រះឱរ៉ា ។
ព្រះអង្គស្មោះត្រង់ស្រឡាញ់ជាតិ ខ្មីឃ្មាតទទូចចង់តវ៉ា
ទារយកសិទ្ធិរាជរដ្ឋា សម្បូណ្ណជាម្ចាស់ផែនដី ។
កាលឆ្នាំមួយពាន់ប្រាំបួនរយ សែប្រាំមួយដោយព្រះចក្រី
ចង់ឱ្យចម្រើនកើនសិរី ប្រែរបៀបថ្មីកម្ពុជា ។
បង្កើតឱ្យមានតំណាង រាស្ត្រតាមគួរយ៉ាងស្រុកនានា
ជួយកាន់ចង្កូតរាជភារា រួមកម្លាំងគ្នាកិច្ចករណី ។
ស្ដេចឡាយព្រះហស្តឱ្យបោះឆ្នោត ពិសោធសួរមិត្តអ្នកបុរី
ក្មេងចាស់ចំណាស់គួរកប្បី ស័្វគ្រលទ្ធិអ្វីថ្លែងយោបល់ ។
ប្រជាជាតិខ្មែរស្រែ-ចំការ ក្រុងក្រៃរដ្ឋាទាំងសាកល
ខេត្ត-ឃុំប្រជុំពុំមានសល់ ចូលផ្ទាល់បោះឆ្នោតច្រើនពេញពាស ។
តាមទីតំបន់ទាន់កំហិត ស្ម័គ្រចិត្តលទ្ធិប្រជារាស្ត្រ
ប្រជាធិបតេយ្យថ្លៃឱកាស រើសមនុស្សដែលឈ្មោះមានបញ្ញា ។
ហើយនឹងលទ្ធិសេរីភាព ជាលាភឧត្តមសមប្រាថ្នា
ត្រូវបានព្រះទ័យព្រះករុណា រាស្ត្រឆ្លើយឱ្យការណ៍យ៉ាងនេះឯង ។

អ្នកតំណាងរាស្ត្រហុកសិបប្លាយ ឧបាយប្រុងប្រៀបរៀបចាត់ចែង
ធ្វើច្បាប់កែប្រែគិតកោតក្រែង តាមទីដំណែងក្រសួងខ្លួន ។
រដ្ឋធម្មនុញ្ញល្អសោភា ដែលតំណាងរាស្ត្រគ្រប់ទិសបួន
តែងក្រិត្យបញ្ញាទុកជាក្បួន សមសួនជាច្បាប់សម្រាប់ជាតិ ។
ព្រះករុណាថ្លៃវិសេស ជាកេសមូលីមុនីនាថ
ការពារសម្បាចីវជទាយាទ គ្រប់គ្រងព្រះញាតិព្រះវង្សា ។
និងពួកប្រជាជនខេមរៈ ព្រះទ័យស្មោះស្ម័គ្រគុណករុណា
ទ្រង់ព្រះសណ្តោសប្រោសមេត្តា ពួកសេវកាមាត្យមន្ត្រី ។
ស្តេចមានជំនឿយ៉ាងអស្ចារ្យ ចំពោះសាសនាព្រះជិនស្រី
សទ្ធិន្ទ្រីយ៍តាំងស្មារតី ចក្រីបំពេញអភិនិហា ។
រាជាបនៈបណ្ឌិតពោ ក្សត្រថ្លៃសេដ្ឋោវង្សខេមរា
ទ្រង់ញាណគតិយ៉ាងក្សៀវក្លា វិយពោបញ្ញាឆ្លាតវៀងវៃ ។
មេធាវីជាទីអ្នកប្រាជ្ញធំ ប្រកព្រហ្មកំឡុងទីក្រុងជ័យ
វិសេសលើសលើប្រាជ្ញដទៃ ទ្រង់ភ្ញកមមៃដល់សាសនា ។
គ្រិស្តស័កមួយពាន់ប្រាំបួនរយ សែប្រាំពីក្រោយមហាក្សត្រា
លះបង់សម្បត្តិរាជឧត្តមា ស្រីសួំបរិវាររាំងដំណាក់ ។
ចមពៀរយាងទ្រង់ភេទបុព្វជ្ជា កសាងសម្មាធមិអរិយៈ
សីល១០ សច្ចំ សំវរៈ យាងកាន់ឧត្តមភេទថ្លៃថ្លា ។
គង់វត្តព្រះកេរ្តិ៍ព្វយកោ នរោត្តមោនាមឈ្មោះថា
ព្រះកែវមរកតអារាម្មា ខាងត្បូងប្រាង្គប្រាជាកំណត់ ។
ទ្រង់ផ្នួសបួសបានមួយវស្សា ស្តេចចេះទេសនាហ្មត់ចត់
មានគ្រហស្ថបុរសរដ្ឋ ព្រះសង្ឃគ្រប់វត្តជុំវិញក្រុង ។

ទាំងពួកឧបាសកសិកា សុវណ្ណធមិពិតពិនិត្យប្រុង
ស្តាប់ធមិភាជាឃ្លាដើមចុង ចិត្តមូលក្រឡង់ចាប់អារម្មណ៍ ។
រកធមិតម្កល់សមាធិ រាត្រីទិវិនដាក់ចិត្តចំ
ជឿជាក់គារវៈក្បត្រឧត្តម ខិតខំប្រយ័ត្នប្រតិបត្តិតាម ។
ផ្លូវលោកផ្លូវធមិរាល់អន្លើ សាងធ្វើទានសីលផ្ចិលគ្រឿងកាម
លះកម្មទុច្ចរិតត្បិតព្រះហាម ញៀនញោមក្លាយជាតិកំណើតខ្លួន ។
សុចរិតនាំសត្វទៅដោយសុខ ឆ្លងរួចចាកទុក្ខអបាយបួន
ធ្វើបាបបានបាបទៅមុខមួន ប្រទះជួបជួនពៀរវេរា ។
ព្រះអង្គទ្រង់ផ្ទួសហួសបីខែ តាំងតែប្រទានសេធម្មា
ឱ្យពួកបរិស័ទហាត់មនោទ្វារ ការពារជាតិមនុស្សលុះមគ្គផល ។
បច្ច័យបូជារាជសុន្ទរៈ ក្សត្រថ្លៃលក្ខណសម្តែងធមិ
ពាន់រយប៉ុន្មានពុំបានសល់ ទ្រង់គ្មានទុកដល់តិចតួចទេ ។
ទេសនាវត្តណាទុកវត្តនោះ ចំពោះអាចារ្យញោមវត្តគេ
ចំណាយកសាងអារាម ទ្រង់ឧទ្ទិសវេចាត់ចែងចាយ ។
ហេតុគួរសំណាលកាលយូរយារ ក្រុងកម្ពុជាដែនដីអាយ
ពុំដែលមានសោះអ្នកទាំងឡាយ ស្តេចចេះប្រាជ្ញប្រាយយ៉ាងនេះឯង ។
ព្រះបាទសីហនុវ្ស៊ន សំខាន់អស្ចារ្យយ៉ាងក្រៃលែង
ព្រះទ័យស្មោះសតអង្វែង ជាក់ស្តែងដល់រាស្ត្រទាសកម្មករ ។
ទ្រទ្រង់ព្រះពុទ្ធសាសនា ឧស្សាហ៍យ៉ាងយាតឃ្លាតលោចរ
ប្រទានវេទស្អាតបវរ ធម្មរសពិតល្អផ្អែមពិសារ ។
ស្តេចប្រោសប្រទានមនុស្សកំសត់ សាត់ព្រាត់ក្រក្រីស្រីប្រុសណា
មានរោគជំងឺឈឺវៀបផ្សា ទ្រង់ព្រះមេត្តាថ្នាំឱសថ ។

សម្បៀកបំពាក់សម្រាប់អ្នកក្រ ហប្ញទ័យស្មោះសដោយលំអិត
អនុគ្រោះចំពោះទីបំផុត ក្សត្រថ្លៃចមម្កុដទ្រង់ធម្មា ។
ទូលព្រះបង្គំសូមឱនកាយ ក្រាបថ្វាយបង្គំព្រះរាជា
ក្រោមល្អងធូលីព្រះបាទា សរសើរសម្ភារបុណ្យបារមី ។
ព្រះករុណាថ្លៃវិសេស ជាកេសកំពូលមូលសិរី
សូមថ្លែងប្រវត្តិព្រះចក្រី សង្ខេបសេចក្តីប៉ុណ្ណេះឯង ។
ប្រវត្តិសាស្ត្រខ្មែរលេខ៣២ រៀងទីតាមថ្នាក់ជៀងជាក់ស្តែង
អំពីបារាំងដែលប្រឹងប្រែង ខំជួយចាត់ចែងរៀបភារា ។
ឱ្យកើតធនធានមានកេរ្តិ៍ឈ្មោះ ខ្ពង់ខ្ពស់ថ្កុំថ្កើងឡើងសម្ភារ
ដូចបានសារស័ព្ទប្រាប់នាម្មា សក្តិជាបារាំងមកព្យាបាល ។
ទី១នាមឈ្មោះលោកមហូត៍ មានសុមនោគុណករុណា
លោកនេះបានធ្វើបាទចរា ពីខេត្តឈ្មោះថាកំពតពិត ។
ឆ្ពោះមុខទៅស្រុកលួងប្របាង អស់ព្រៃងសំណាងក្ស័យជីវិត
ដោយអត់អាហារការប្រព្រឹត្ត ឆ្ងាយណាស់មិនជិតក្រុងវៀងច័ន្ទ ។
ទី២បារាំងឈ្មោះលោកមិស ក្រុមសាសនាគ្រិស្តកត្តលិខន្ធ
មកជួយស្រុកខ្មែរឃ្លាតខ្ចីខ្ចាន់ រន្ធាន់ក្រាបទូលលួងស្តេចខ្មែរ ។
ព្រះបាទអង្គឌួងនរោត្តម បង្ខំពន្យល់ឱ្យស្តេចប្រែ
ទីពឹងបារាំងខ្លាំងពូកែ មកនៅប្របក្បែរម្ចាស់ជីវិត ។
ទី៣ ឌូដាដឺឡាគ្រេ ជាមេសង្គ្រោមដឹងទឹកពិត
លោកចេញដំណើរដើរពិនិត្យ អនុខេត្តឆ្ងាយជិតរបស់ខ្មែរ ។
ស្ទឹងបឹងទន្លេឈ្មោះមេគង្គ រង់វង់ព្រំដែនវៀងហូរហៃ
លោកអនិច្ចកម្មទៅទៀតដែរ ព្រោះតែជំងឺឈឺគ្រុនញាក់ ។

| | |
|---|---|
| លោកមិស និងលោកដឺឡាគ្រេ | ក្រាបទូលខត្តិយស្ដេចខេមរៈ |
| ព្រះនរោត្តមបង្គំស្ម័គ្រ | ឱ្យស្ដេចព្រមដាក់ផែនដីខ្មែរ ។ |
| ក្រុងកម្ពុជាឱ្យនៅក្នុង | ទំនុកបម្រុងសាសន៍ប្រាំងសែ |
| ទើបបានថ្កុំថ្កើងឡើងហូរហែ | ពន្យល់នាំណែលលួងអម្ចាស់ ។ |
| ទី៤ បារាំងឈ្មោះម៉ូរ៉ា | លោកសរសេរចារសៀវភៅក្រាស |
| តែងជារឿងរ៉ាវប្រវត្តិសាស្ត្រ | ជាតិខ្មែរច្បាស់លាស់គ្រប់ទីកន្លែង ។ |
| ហើយនិងមូលផលផ្លែមើមឈើ | លោកនេះបានធ្វើក្នុងតំណែង |
| ទីរ៉េស៊ីដង់លេខ១ស្ដែង | ត្រួតត្រាខែងរ៉ែងរាជការខ្មែរ ។ |
| ច្រើននិងច្រើនគ្រាជាយូរឆ្នាំ | ទី៥ លោកអាយម៉ូនីញ៉េ |
| ធ្វើទីរ៉េស៊ីដង់លេខ១ដែរ | ចេះដឹងបកប្រែអក្សរសាស្ត្រ ។ |
| ចារិកនៅថ្មនគរវត្ត | មើលបានប្រាកដពោលប្រកាស |
| រៀបរាប់ប្រាសាទស្អាតដេរដាស | ឱ្យខ្មែរដឹងច្បាស់ព្រះនាមស្ដេចពិត ។ |
| ៦បារាំងឈ្មោះ ប៉ាវី | ដើររុករានទីស្រុកជិតឆ្ងាយ |
| គូរប្លង់ផែនទីដោយពិនិត្យ | ត្រឹមត្រូវសក្ដិសិទ្ធិព្រំដែនខ្មែរ ។ |
| ទី៧ឈ្មោះលោកអ៊ូត្រេយ | ក៏គេដឹងស្គាល់រៀងហូរហែ |
| ធ្វើទីរ៉េស៊ីដង់លេខ១ដែរ | លុះយារយូរខែគ្រប់បីឆ្នាំ ។ |
| លោកនេះផ្ដើមធ្វើការយ៉ាងមាំ | រៀបចំថ្នល់ស្ពានមានឆ្វេងស្ដាំ |
| យ៉ាងច្រើនគីឡូម៉ែត្រប្រចាំ | មាននៅក្នុងកម្ពុជរដ្ឋ ។ |
| ទី៨ លោកបូឌូវ៉ាំង | ធ្វើរ៉េស៊ីដង់យូរប្រាកដ |
| ទីសុប៉េរីយ៉ឺគ្រប់កំណត់ | ដប់ពីរឆ្នាំស្ទាត់ប្រាជ្ញអស្ចារ្យ ។ |
| លោកបានកែប្រែរៀបចំ | មូនមាំប្លែកអនេកការ |
| ស្រុកខ្មែរចម្រើនកើនថ្លៃថ្លា | បង្កើតសាលាអក្សរសាស្ត្រ ។ |

ធ្វើស្ពានកំពតថ្មល់ឡើងភ្នំ កំចាយធាធំខ្ពស់ស្រឡះ
រថយន្តបើកបានថ្កានព្រៃក្រាស់ ធ្វើផ្ទះរាជការប៉ុងកាឡូ ។
បន្ទាយទាហានក៏មានព្រម បែបភាពសមល្មមលើបូកគោ
កន្លែងយកខ្យល់ដល់ជំនោរ ទីដេកបរិបូណ៌ផ្ទះសំណាក់ ។
ខ្មែរមិនត្រូវភ្លេចគុណបារាំង សែសដែលមកតាំង....
ជួយធ្វើការខ្មែរញើសសស្រាក់ គឺអ្នករាជការរដ្ឋបាល ។
មេការគ្រូពេទ្យគ្រូបង្រៀន ក្រុមមេទាហានគ្មានរាងចាល
គ្រុនចាញ់ឈឺចាប់ស្លាប់គ្រប់កាល ព្រោះរោគបណ្ដាលច្រើនសន្ធាន ។
បារាំងមេព្រៃប្រែសណីយ៍ កុំមីសៀសង់ត្រាល់អម្បាលម៉ាន
ផ្ទះបាំងឃ្លាំងប្រាក់ប៉ុរីឋាន ដែលបានតាំងនៅស្រុកក្រុងខ្មែរ ។
រ៉េស៊ីដង់រូមខេត្តស្មៀនភូឈ្មួយ សែបប៉ុស្តិ៍ជំនួយផែនដីស្រែ
គួរប្លង់តម្រង់ព្រំដែនខ្មែរ នឿយហត់គ្មានល្ហែគ្រប់រូបអើយ ៕

ចប់

# ១.

# ផែនទីបុរាណទាក់ទិននៅនឹង
# ភូមិសាស្ត្រជាប្រវត្តិសាស្ត្រ
# របស់ព្រះរាជាណាចក្រកម្ពុជា




១. ព្រះរាជាណាចក្រកម្ពុជា ខ្មែរដំបូង នាសម័យនគរភ្នំ ឬ ហ្វូណន ចុងសតវត្សរ៍ទី ៦ ដើម សតវត្សរ៍ ទី ៧ និង ព្រះរាជាណាចក្រ ចេនឡា និង មន ឬ ទ្វារវតី ដែលបានបង្កើតឡើងលើទឹកដីចាស់របស់នគរភ្នំ




២. ព្រះរាជាណាចក្រកម្ពុជា នាសម័យខប្បធម៌នគរភ្នំ ព្រមទាំងទីតាំងនៃរាជធានី បុរអន្តរមួយចំនួនទៀត កាលពីសតវត្សរ៍ទី ១ ដល់ ទី ៦ នៃ គ.ស មុន ការបង្កើតរដ្ឋ មន




៣. ផែនទីខ្មែរ នាឆ្នាំ ៩៦០ គ.ស មុនកំណើតនៃ
ប្រទេសថៃ លាវ និង វៀតណាមខាងត្បូង




៨. ព្រះរាជាណាចក្រកម្ពុជា ក្នុងរជ្ជកាល នៃព្រះបាទ ជ័យវរ្ម័នទី ៧ មុនស.វ ទី ១២ ដើមស.វ ១៣ នៃ ព.ស មុនការបង្កើតរដ្ឋថៃ, លាវ និងការបាត់បង់ទឹកដីកម្ពុជាក្រោម ដែលក្លាយទៅជាវៀតណាមខាងត្បូង




៥. ផែនទី ដែនដីសណ្តរនៅកម្ពុជាក្រោមដែលបានបាត់បង់ទៅចាប់តាំងពី ស.វ ១៧ ដែលក្លាយទៅជាវៀតណាមខាងត្បូង បច្ចុប្បន្ន




៦. ផែនទីនៃបន្ទាយលង្វែក គូរនៅឆ្នាំ ១៦៥២ ដោយជនជាតិ ហូឡង់



៧. ផែនទីនៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ១៨៣៨
ដោយព្រះសង្ឃបារាំង តាបែរ

# ២.

# ឯកសាររូបភាពព្រះឆាយាលក្ខណ៍
# នៃព្រះមហាក្សត្រ និង មហាក្សត្រីយានីខ្មែរ
# នៃព្រះរាជាណាចក្រកម្ពុជា

# រាជាធិបតេយ្យកម្ពុជា

## ព្រះរាជបច្ឆាញាតិនៃព្រះបាទអង្គឌួង



| | | |
|---|---|---|
| ព្រះបាទសម្ដេច ព្រះនរោត្តមសីហនុ (១៩២២-) | អ្នកម្នាងកាញ៉ុល (១៩២០-១៩៦៩) | - សម្ដេចន.បុប្ផទេវី (១៩៤៣-)<br>- សម្ដេចន.រណឫទ្ធិ (១៩៤៤-) |
| | ម្ចាស់ក្សត្រី ស.ពង្សានមុនី (១៩២៩-១៩៧៤) | - សម្ដេចយុវនាថ (១៩៤៣-)<br>- ព្រះអង្គម្ចាស់រវិវង្ស (១៩៤៤-១៩៧៣)<br>- សម្ដេចចក្រពង្ស (១៩៤៥-)<br>- ម្ចាស់ក្សត្រីសុរិយារង្សី (១៩៤៧-១៩៧៦)<br>- ម្ចាស់ក្សត្រីគន្ធបុប្ផា (១៩៤៨-១៩៥២)<br>- ព្រះអង្គម្ចាស់ខេមានុរក្ស (១៩៤៩-១៩៧៥)<br>- ម្ចាស់ក្សត្រីបុទុមបុប្ផា (១៩៥១-១៩៧៦) |
| | ម្ចាស់ក្សត្រីស.មុនីកេសន (១៩២៩-១៩៤៦) | - ព្រះអង្គម្ចាស់នរាធិពោ (១៩៤៦-១៩៧៦) |
| | អ្នកម្នាងម៉ានីវណ្ណ ផានីវង្ស (១៩៣៤-១៩៧៥) | - ម្ចាស់ក្សត្រីសុជាតាវឌ្ឍនា (១៩៥៣-១៩៧៥) |
| | ម្ចាស់ក្សត្រីយកនិដ្ឋា នរោត្តម នលក្ខណ៍ (១៩២៧- | |
| | សម្ដេចព្រះរាជអគ្គមហេសី មុនីនាថ សីហនុ (១៩៣៦- | - ព្រះករុណា សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី (១៩៥៣-) ១២<br>- ព្រះអង្គម្ចាស់នរិន្ទ្រពង្ស (១៩៥៤-២០០៣) |

# ព្រះឆាយាលក្ខណ៍នៃព្រះរាជវង្សានុវង្សខ្មែរ



ព្រះករុណា ព្រះបាទ សម្តេចព្រះអង្គឌួង សោយរាជ្យពីឆ្នាំ (១៧៩៦-១៨៦០)



ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម ទី ១ (១៨៣៤-១៩០៤)



ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម ពេលឡើង
សោយរាជ្យសម្បត្តិ (១៨៣៤-១៩០៤)



ព្រះករុណា ព្រះបាទ សម្តេចព្រះ ស៊ីសុវត្ថិ (១៨០៤-១៩២៧)



ព្រះករុណា ព្រះបាទ សម្ដេចព្រះស៊ីសុវត្ថិ



ព្រះករុណា ព្រះបាទ សម្តេចព្រះ ស៊ីសុវត្ថិ (ព្រះរូបសំណាកសំរឹទ្ធ)



ព្រះករុណា ព្រះបាទ សម្តេចព្រះស៊ីសុវត្ថិ



ព្រះករុណា ព្រះបាទ សម្ដេច ព្រះស៊ីសុវត្ថិ ជាមួយមន្ត្រីជាន់ខ្ពស់បារាំង
ក្រោយពីរាជពិធីរាជាភិសេក



ព្រះករុណា ព្រះបាទ សម្ដេចព្រះស៊ីសុវត្ថិ
ជាមួយមន្ត្រីបារាំងជាន់ខ្ពស់ សម័យអាណាព្យាបាលបារាំង



ព្រះករុណា ព្រះបាទ សម្តេច ព្រះស៊ីសុវត្ថិ
(១៨០៤-១៩២៧)



ព្រះករុណា ព្រះបាទ សម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស (១៨៧៦-១៩៤១)



ព្រះករុណា ព្រះបាទ សម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស (១៩២៧-១៩៤១)



ព្រះករុណា ព្រះបាទ សម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស (១៩២៧-១៩៤១)



ព្រះករុណា ព្រះបាទ សម្ដេច ព្រះស៊ីសុវត្ថិ ព្រះមុនីវង្ស (១៨៧៦-១៩៤១)



ស្ត្រីសំណាប់របស់ព្រះករុណា ព្រះស៊ីសុវត្ថិ



ស្ត្រីរបាំក្នុងព្រះបរមរាជវាំង



ព្រះអង្គម្ចាស់ ក្នុងសំលៀកបំពាក់បុរាណ



មន្ត្រីខ្មែរក្នុងសំលៀកបំពាក់បុរាណ



ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត នៅពេល ពិធី
ព្រះរាជាភិសេក ឆ្នាំ ១៩៤៦



ព្រះឆាយាលក្ខណ៍នៃ សម្តេចព្រះវររាជនីនាថ ស៊ីសុវត្ថិ កុសុមៈ(១៩០៤-១៩៧៥)
វររាជ វេទី ព្រះបរមរាជមាតា នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទ
នរោត្តម សីហនុវរ្ម័ន



ព្រះរាជអភិសេក របស់សម្ដេច ព្រះបាទនរោត្តម សុរាម្រិត និង សម្ដេច
ព្រះមហាក្សត្រីយានី នៅឆ្នាំ ១៩៥៦ (ក្បួនហែរ)



ព្រះឆាយាលក្ខណ៍នៃ សម្តេចព្រះវររាជជននីនាថ កុសុមៈ វរាជ រេធី ព្រះបរមរាជមាតា
នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះបាទ នរោត្តម សីហនុ វរ្ម័ន (១៩០៤-១៩៧៥)



ព្រះអង្គម្ចាស់ នរោត្តម សុរាម្រិត ពេលដែលមានព្រះជន្ម ១៨វស្សា



ព្រះឆាយាលក្ខណ៍របស់ព្រះអង្គ មុនពេល
ដែលព្រះអង្គសោយទិវង្គត (១៨៩៦-១៩៦០)



ការទទួលលោកប្រធានាធិបតី សូការណូ នៅឆ្នាំ ១៩៥៩ ដោយព្រះករុណា
ព្រះបាទ នរោត្តម សុរាម្រិត និង ព្រះមហាក្សត្រីយានី



ព្រះអង្គម្ចាស់នរោត្តម សីហនុ ជាមួយព្រះមាតា និង បិតា គឺ
ព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ កុសុមៈ និង ព្រះអង្គម្ចាស់ នរោត្ត សុរាមរិត



ព្រះឆាយាលក្ខណ៍ នៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះបាទ
សម្ដេចព្រះ នរោត្តម សីហនុវរ្ម័ន (១៩២២-)



ព្រះបរមឆាយាលក្ខណ៍កាលទ្រង់សាងព្រះផ្នួស នៅឆ្នាំ ១៩៤៧



ព្រះឆាយាលក្ខណ៍ ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ
ពេលឡើងសោយរាជ្យសម្បត្តិក្នុងព្រះជន្ម១៨ព្រះវស្សា



ព្រះឆាយាលក្ខណ៍ នៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះបាទ
សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន



ព្រះបាទ នរោត្តម សីហនុ ចលនាសាមគ្គីរំដោះប្រទេសជាតិ
ពីយៀកមិញឆ្នាំ ១៩៥៣



ព្រះឆាយាលក្ខណ៍ នៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះបាទ
សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន



ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ និង សម្តេច ព្រះរាជអគ្គមហេសី នរោត្តម
មុនិនាថ សីហនុ  ក្នុងព្រះពិធីច្រត់ព្រះនង្គ័ល នៅឆ្នាំ ១៩៦៩



ព្រះបាទ សម្តេច នរោត្តម សីហនុ និង ព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ
ព្រមទាំងព្រះរាជបុត្រទាំងពីរ គឺ ព្រះអង្គម្ចាស់ នរោត្តម សីហមុនី
និង ព្រះអង្គ នរោត្តម នរិន្ទពង្ស (១៩៥៤-២០០៣)



សម្តេច ព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ
ព្រមទាំងព្រះរាជបុត្រទាំងពីរ

ព្រះអង្គម្ចាស់ក្សត្រីយ៍
នរោត្តម សម្ដេច ព្រះរាម
បុប្ផាទេវី
១៩៤៣-





សម្ដេច ព្រះរាម បុប្ផាទេវី កំពុងបន្ទាត់រជាំព្រះរាជទ្រព្យក្នុងនាមព្រះអង្គជារដ្ឋមន្ត្រី
នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ នៅអាណត្តិទី ២ (១៩៩៨-២០០៤)



សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ អតីតជានាយករដ្ឋមន្ត្រី ទី១ នៃ
ព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នជាប្រធានរដ្ឋសភាជាតិ (១៩៨៤-)



សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក្នុងពេលសាងព្រះផ្នួស ដើម្បីបុព្វហេតុជាតិ



ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ក្នុងព្រះរាជពិធីជ័រថ្ងៃ ឆ្នាំ ១៩៦៦



ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា រូបថតអនុស្សាវរីយ៍
មុនពេលដែលព្រះអង្គឡើងសោយរាជ្យសម្បត្តិ (នៅពេលដែលព្រះអង្គកំពុងបង្ហាត់រាំ)



ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា រូបថតអនុស្សាវរីយ៍
មុនពេលដែលព្រះអង្គឡើងសោយរាជ្យសម្បត្តិ (នៅពេលព្រះអង្គកំពុងបង្ហាត់របាំ)



រូបថតអនុស្សាវរីយ៍ នៅទីស្នាក់ការ យូណេស្កូ ប៉ារីស កាលពីឆ្នាំ ២០០១
ស្តេចក្រមឃុន សីហមុនី (ស្តាំ) យាងចូលរួមប្រជុំសន្និបាតកំពូល លើកទី៣១
ក្នុងនាមព្រះអង្គជាព្រះអគ្គរាជទូត តំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំនៅ អង្គការ យូណេស្កូ នៅទីក្រុងប៉ារីស



ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី (១៩៥៣-)
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅពេលយាងឡើងសោយរាជសម្បត្តិ
ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤

មូលនិធិខ្មែរសម្រាប់ការសិក្សា ករុណាខ្មែរ